# មជ្ឈមណ្ឌលឯកសារកម្ពុជា

## ករណី ស្រេង ធី ភេទប្រុស គ្មានប្រវត្តិរូប
## មុខងារៈ កងទ័ព កងពលលេខ៥០២
## ជួបសម្ភាសផ្ទាល់ជាមួយ ស្រេង ធី អាយុ៤៧ឆ្នាំ
## នៅភូមិព្រែកខ្សេវ ឃុំរការខ្ពស់ ស្រុកស្អាង ខេត្តកណ្តាល
## ថ្ងៃទី២៨ ខែតុលា ឆ្នាំ២០០៣
## សម្ភាសដោយៈ ផាន់ សុជា និង អៀ ម៉េងទ្រី
## ភាគ១,២,៣

ម៉េងទ្រីៈ តាំងពីក្មេង តាំងពីអាយុយើងកើតជាលហូតៗមកដល់បែកយើង៧៩ លហូតម៉ោដល់ឆ្នាំ៨០-៨៥ទៀតណាពូៗជួយរៀបរាប់ម៉ាដំណើរដូចថាចាំប៉ុនណារៀបរាប់ប៉ុណ្ណឹង ដូចថាចាំបានប៉ុណ្ណាពូជួយរៀបរាប់មើលដូចថាជីវិតបស់ពូឆ្លងកាត់បទពិសោធន៍អ៊ី...តស៊ូ ឬក៏ជួរជត់បែបណាខ្លះពូសុំជួយប្រាប់ពួកខ្ញុំឲ្យបានដឹងផង ។

ធីៈ បាទ! ជីវិតបស់ខ្ញុំហ្អី?

ម៉េងទ្រីៈ បាទ!

ធីៈ ជីវិតបស់ខ្ញុំៗនិយាយមុនឆ្នាំ៧០មុនឆ្នាំ៧២និយាយមុនឆ្នាំ៧២ណា ខ្ញុំនៅជាមួយក្រុមគ្រួសារទាំងអស់ប៉ុន្តែដោយឡែកខ្ញុំអត់មានបងប្អូនបង្កើតទេគឺខ្ញុំកំព្រាតាំងពីអាយុ៥ឆ្នាំនោះ ហើយឪពុកខ្ញុំពីដើមឡើយគាត់ធ្វើទាហាន ដល់ក្រោយម៉ោឈប់ពីទាហាន តែមិនដឹងទាហានជំនាន់ណា ជំនាន់បារាំងមិនដឹងទេ ហើយគាត់មានប្អូនថ្លៃមួយទៀត ធ្វើគយនៅជ្រៃធំ ហើយដល់អីចឹងគាត់ទៅគយទៅម៉ោៗហើយខ្ញុំនេះមានឪពុកៗខ្ញុំច្រើនដើរចោលខ្ញុំៗច្រើននៅជាមួយជីដូនទេ ដល់ក្រោយពីកើតសង្គ្រាមឆ្នាំ៧០ហ្នឹងគាត់ម៉ោនៅទះវិញ ដល់ខ្ញុំនៅទះធ្វើចម្ការធ្វើអីជាមួយគាត់ទៅ ពេលហ្នឹងខ្ញុំនៅស៊ើរនៅរៀនសូត្រអីចឹងហើយខ្ញុំតែ២នាក់ឪពុកហើយនិងកូនហ្នឹង ។ ហើយដល់ឆ្នាំ៧២ទទួលគេឆ្នាំឆ្នាំ៧២ខែ៨ខែ៨ជិតចូលឆ្នាំខ្មែរណា ម៉ាចំហៀងជីរដោះម៉ាចំហៀងជីលន់ ណុល អីចឹងដល់គេប្រមូល

*កម្លាំងប្រមូលអីទៅដីរំដោះនោះ ហើយខ្ញុំក៏ចុះទៅជាមួយអ្នកនៅខាងដីរំដោះនៅឆ្នាំ៧២ ខែ៤ហ្នឹងទៅបានប្រហែលជាម៉ាឆ្នាំប្រហែលជា៧ខែ បានឪពុកខ្ញុំចុះទៅ ចុះពីដី លន់ណុល សូម្បីតែឪពុកគាត់ក៏នៅអំពេញដែរ បងប្អូនគាត់បង្កើតក៏នៅអំពេញដែរ ក៏គាត់តាមខ្ញុំនៅដីរំដោះដែរ ។ ដល់ឆ្នាំជិតចូលឆ្នាំ៧៣ក៏ខ្ញុំហ្នឹងចូលទៅទ័ព ដីៗ រំដោះហ្នឹងគឺខ្ញុំចូលទៅទ័ពទៅលីដែកប្រហោងដែកអីជាមួយហ្នឹងនៅកាលហ្នឹងគេហៅស្រុក២០នេះ ស្រុកស្អាងគេហៅស្រុក២០ទៅធ្វើទ័ពស្រុក២០ហ្នឹងដល់ធ្វើបានប្រហែលជា៤-៥ខែក៏គេទាញខ្ញុំចូលភូមិភាគពិសេស ។ ខ្ញុំនិយាយភូមិភាគពិសេសមានកងពលមានវាបើខ្ញុំចាំវាមាន៣កងពល មានកងពល១១ៗ កងពលខ្ញុំនៅផ្ទាល់ កងពល១២កងពលដែលតាណាត តាពីងហ្នឹង ដែលកងពល១១មាន* **តាពីង**, *តាសោម ដែលខ្ញុំនិយាយថា ផ្ទះតាសោម នៅទន្លេបាទីនេះ ហើយកងពលមួយទៀតខ្ញុំមិនចាំឈ្មោះទេ ប៉ុន្តែដល់ចប់ពីសង្គ្រាម៥ឆ្នាំហ្នឹងគេរំលាយកងពលហ្នឹងចេញទៅ កងពល១២ចូលអគ្គសេនាធិការភ្នំពេញហ្នឹង កងពល១១ខ្ញុំហ្នឹងគេរំលាយចូលទៅកងពល៥០២ ដែលកងអាកាសហ្នឹងនេះ ហើយកងពលមួយទៀត៨០១ហ្នឹងហើយទៅរតនគិរី មណ្ឌលគិរី ទៅប៉ែកខាងណោះទៅហ្នឹង៣កងពលគេរំលាយទៅ អីចឹងក៏គេរំលាយកងពលនៅភូមិភាគពិសេសហ្នឹងចេញ ប៉ុនអាក្រៅពីហ្នឹងចល័តទៅតាមកងពលណា ហើយខ្ញុំហ្នឹងនៅខាងកងពល៥០២ អីចឹងកងពល១១ទៅនៅកងពល៥០២ ប៉ុនកងវរសេនាតូចដែលខ្លួននៅហ្នឹងចាំរាល់ថ្ងៃគឺនៅប្រចាំកងវរខ្លួនឯងដដែលកាលហ្នឹងកងវរហ្នឹង១៣២ៗអីចឹងហើយខ្ញុំនៅកងវរ១៣២ ហើយកាលហ្នឹងខ្ញុំទៅនៅកងអាកាសបានប្រហែលម៉ានខែគេឲ្យចេញម៉ោ ទៅឆ័ត្រយោងៗបានម៉ានខែកន្លះឆ្នាំអីកាលហ្នឹងនោះ វាអត់ជាប់គេថា ខ្ញុំបញ្ឆាក់ពីសុខភាពអីចឹងណាកាលហ្នឹង រួចហើយបានទៅកងការពារគេហៅកងការពារដែនអាកាស ហើយដល់អីចឹងទៅបានខ្ញុំក្រោយម៉ោទៀត ខ្ញុំវា គេចាប់មេៗដែលគ្រប់គ្រងហ្នឹងហ្អា ចាប់ទាំងអស់ដែលឲ្យតែអ្នកណាគ្រប់គ្រងតំបន់២៥ម៉ាន អ៊ឺ...គេៗចាប់តឹងអស់ ។ ខ្ញុំទីតាំងខ្ញុំនៅ***វត្តគោកជាន់ៗ*** *ខាងជើងប៉ុស្តិ៍វិទ្យុស្ទឹងមានជ័យខាងត្បូងចោមចៅនេះ អាផ្លូវម៉ោចោមចៅ... ហើយនិងលបងខាងត្បូងពោធិចិនតុងវត្តចំបក់ៗ ខ្ញុំនៅតាហ្នឹងកាលរៀនហ្នឹងណា ដល់គេចាប់អីចឹងទៅ អើគេចាប់មេៗពួកខ្ញុំតូចតាចសក្តិប៉ុណ្ណឹងក៏គេអត់ចាប់ដែរដល់តាម៉ានទេ*

ដូចខ្ញុំ៧៦ខែម៉ាននេ ខែ...ដែលអី...ដឹកប្រឡាយជំនាន់៧៦ហ្នឹង ខែដឹកប្រឡាយ លើកទំនប់សាលា...ពីអាពតហ្នឹងអត់ចេញពីក្រុងទេ នៅក្បែរៗក្រុងហ្នឹង ក៏គេ...ដូចខ្ញុំប្រាប់ប្អូនឯងព្រឹកមិញថា មាន់អត់មេអត់កើយគឺយើងវាណែនាំអីចឹងដើម្បីចាប់ ប៉ុនមិនមែនចាប់អីចឹងទេ គឺប្រមូលហ្នឹងអ្នកដែលមានឈ្មោះម៉ោកន្លែងគេហៅស២២ហ្នឹងណាហ្នឹងហើយគេចាប់នៅកន្លែងទីតាំងស២២ហ្នឹងនៅអាកន្លែងទឹកល្អក់មុខសាលារៀនទឹកល្អក់រាល់ថ្ងៃហ្នឹង អាសាលារៀននៅខាងកើតៗផ្លូវប៉ុនមានអាផ្លូវចូលទៅខាងលិច ទៅខាងនោះខាងលិច គេហៅស២២ ប៉ុនអាហ្នឹងគេហៅអូបែកក្អមទេ ប៉ុនតែកន្លែងហ្នឹងគេដាក់មន្ទីរគុកបស់កងពល៥០២ហ្នឹងណា គេចាប់កន្លែងហ្នឹង ។ អើគេចាប់ហ្នឹងនិយាយទៅគេវៃដាក់ឈ្មោះដាក់អីកាលហ្នឹងប៉ុនកាលហ្នឹងតាំងពីឈើរហូតដល់បាត់ឈើ ប៉ុនតែកាលហ្នឹងយើងនិយាយពីកម្មផល ពួកអ្នកភូមិៗកម្រឃើញរូបណាស់ ប៉ុនតូចៗដូចខ្ញុំៗកាលហ្នឹងមានតួនាទីមួយតាមមេកើយសមរភូមិទេដល់អស់មេកើយសមរភូមិដល់ចូលក្នុងអំពេញ អីចឹងខ្ញុំមានតួនាទី១គឺប្រធានក្រុមកាំភ្លើងការពារដែនអាកាស ម៉ាក្រុមហ្នឹង ហើយមិនមែនតាខ្ញុំទេ អាទាប់ហ្នឹងណា វាមាន**អាពេក** ដូចខ្ញុំបញ្ជាក់អីចឹងណាមានវាមួយ មានអាឡៀប នៅក្រាំងយូវនេះ ហ្នឹងហើយមានវាហ្នឹងដែរប៉ុន្តែដល់គេចាប់វាគេអត់ចាប់ទេចាប់តាខ្ញុំហើយមានមិត្តភក្តិផ្សេងៗទៀត ប៉ុនអាអ្នកនៅក្បែរៗខ្ញុំអត់មានអ្នកណាចាប់វាទេ វានៅអគ្គភាពជាមួយគ្នា ហើយនៅទះជាមួយគ្នា អត់មានអ្នកណាចាប់វាបានទេចាប់តាខ្ញុំហ្នឹងណា ។ អីចឹងបានថា ដល់ចាប់ទៅវាមិនដឹងទោសកំហុសដែល...មិនដឹងទោសកំហុសយ៉ាងម៉េចទេនេះ មិនដឹងគេចាប់ទៅមានទោសអីទេណាៗ គេចោទថាក្បត់បដិវត្តន៍អីចឹងម៉ាជំនាន់គេថាក្បត់បក្សក្បត់អីចឹងទៅមិនដឹងមានទោសអីទេ ហើយបើមេៗដែលត្រឹមថ្នាក់កងពលចាប់វរសេនាធំ វរសេនាតូចអី មិនដឹងថាមានទោសអីទេ គេចោទថាក្បត់ពីបក្សរហ៏វៃបក្សអីចឹងណា ហើយដល់ខ្ញុំតូចៗអីមិនដឹងថា គេចោទពីក្បត់វៃៗអីគេចោទគេមិន...ពុតាមខ្យល់គេនិយាយអីចឹងប៉ុនខ្លួនអត់ដឹងកំហុសអីដែរ ។ ប៉ុន្តែខ្ញុំនេះទោសវាស្រាលដែរ កាលហ្នឹងជាប់ណា ជាប់ប្រហែលជា...បើនិយាយតឹងឃុំខ្លួនតឹងចាប់នោះប្រហែលជា៧ខែនោះបានគេឲ្យចេញម៉ោក្រៅវិញ ។ ក្រោយកទៅដាក់អាកន្លែងមុខអាស២២វិញនេះប៉ុនវាធូរខ្លួនឲ្យចាំងស្មៅចាំងអីចឹងណា លហូតដល់គេថា ខ្ញុំកសាងខ្លួន

បានក៏ឲ្យខ្ញុំដឹកប្រឡាយអាអ្នកទោសហ្នឹង ទោសស្រាលៗណា គេឲ្យទៅដឹកប្រឡាយតាម៉ាងៃទេ មានងៃមួយងៃជិតចេញពីកំពង់ឆ្នាំងនេះ ទៅដឹកប្រឡាយខ្ញុំនិយាយថា មិត្តភក្តិដែលខ្ញុំនិយាយមិញហ្នឹងទៅឱប-កគេពីក្រោយគេមិនស្ដីរកផង គេថា ខ្ញុំហ្នឹងខ្លាចនិយាយបំពាក់បំប៉នកូនចៅគេហ្នឹង តែមិនដឹងបំពាក់បំប៉នយ៉ាងម៉េចទេ បើន័យនយោបាយខ្ញុំមិនដឹង ។ បានឃើញគេចាប់ទៅម៉ាជំនាន់ហ្នឹងហើយមានមិត្តភក្តិខ្លះគេយកមិនហ៊ានឲ្យដំណឹងម៉ោផ្ទះទៀត បុិនគេបានឪពុកខ្ញុំផ្ញើថ្នាំជក់ផ្ញើស្ករយកឲ្យទៅៗដល់អាកន្លែងអាឃុំខ្លួនទៀត ព្រោះកន្លែងឃុំខ្លួនហ្នឹងគេឲ្យចេញម៉ោចាំងស្មៅដូចអាដេញយើងអ្នកទោសយើងសព្វថ្ងៃ ចេញម៉ោធ្វើការអីតិចតួចអីចឹង ចុងឆ្នាំ៧៦ដែរទេ បានគេឲ្យទៅវៃថ្មនៅព្រលានយន្តហោះកំពង់ឆ្នាំង ។ បានគេឲ្យទៅវៃថ្មនៅព្រលានយន្តហោះកំពង់ឆ្នាំងហ្នឹងទៅវៃមិនទាន់បានម៉ានខែផង គេថា ខ្ញុំហ្នឹងកសាងខ្លួនបានធ្វើទ័ពធ្វើអីវិញទៅណា គេបើកកាំភ្លើងឲ្យវិញ បើកកាំភ្លើងបើកអីឲ្យវិញអីចឹងទៅបានគេថា ចាប់ភាន់ច្រឡំ ឬមួយជឿតាមក្បាលម៉ាសុិតួចតាចថា ខ្ញុំក្បត់អីចឹងអាហ្នឹង គេសុំទោសសុំអី ឲ្យកសាងប្រវត្តិរូបឡើងវិញគឺលើសពីប្រវត្តិខ្មែរ ខ្សែអុងអីចឹងទៅហើយទាមទារដីយួននៅព្រៃនគ ខេត្តនេះហៅខេត្តនេះ អីចឹងវាមានឈ្មោះតឹងអស់ខេត្តនៅនេះ អូហ៎ប្រមូលខ្ញុំហ្នឹងចរិតមួយឲ្យតែគេនិយាយអីចេះចង់តែជឿតាម អីចឹងបានគេឲ្យកាន់កាំភ្លើងហ្នឹងឡើងវិញ បាន៤-១០ងៃកន្លះខែហ្នឹងបានគេបញ្ជូនទៅខាងស្វាយរៀងជ្រៅដែរប៉ុនខ្ញុំចាំបានខ្លះ បើសាច់ខ្ញុំដើរ២ងៃអាហ្នឹង បើគេដើរអត់ជិះឡានណា ទ័ពវាតិចណា ទ័ពខ្មែរយើងចូលដីយួនតិចណាស់ ប៉ុន្តែចេះតែលូនចូលជ្រៅទៅដល់យួនផ្ចិតចុងក្រោយម៉ោវិញហ្នឹងបានជាប់នៅហ្នឹង បុិនមិនមែនជាប់យាំងជិតទេ ។ វាទុកភ្នំ២ហ្នឹងសម្រាប់ដាក់អាវរថក្រោះបាញ់អា១២ក្បៀសហ្នឹងឲ្យខ្មែរយើងដក បុិនគ្រាន់ថាដកម៉ោយួនចាប់...ចេញពីយួនចូលម៉ោអីចឹងយើងនិយាយងៃបន្តបន្ទាប់អីចឹង យួនចូល...ចូលអំពេញ តាមយួនបញ្ចេះម៉ោវិញចូលអំពេញហ្នុង ។ ហើយខ្ញុំចាំងៃ១ សុន សេន នេះគាត់ក្រសួងការពារប្រទេស សុន សេន ហ្នឹងគឺបញ្ជាឲ្យអាហ្នឹងយួនជិតចូលដល់អ្នកលឿងហើយៗគឺឲ្យឡានចូលដឹកទ័ព៥០គ្រឿងហើយឲ្យរថក្រោះចេញពីអគ្គសេនាធិការហ្នឹង៥០រថក្រោះទៀត អើដល់ចេញទៅ យួនចូលដល់អ្នកលឿងយួនចូលដល់ត្រឹមហ្នឹងត្រើយខាងកើតណា ។ ចូលខ្មែរយើងចុះចេញទៅ...

ប្រកូកប្រកាសដែល...មិនទ័ពខ្មែរយើងម៉ោជាមួយយួនដែរកាលហ្នឹងក៏មានដែរ អីចឹងឲ្យទ័ពខ្មែរហ្នឹងទៅទះទៅសម្បែងទៅ ឬក៏ចូលទ័ពដើម្បីអ៊ី...គិតគូរពីខ្មែរទៅ ដូចថា ប៉ុល ពត កាប់សម្លាប់ខ្មែរ ចិត្តសាស្ត្រម៉ោ ពីយួនហ្នឹងក៏គេលួបស់គេដែរនិយាយខ្មែរប៉ៃឡាំៗហ្នឹង ចាក់មេក្រូ ដាក់មេក្រូ ស្រែកនៅឡាននៅលើឡានលើអីចឹងដែរ ។ ខ្លះក៏នៅទ័ពហ្នឹងទៅ ខ្លះក៏ទៅរកស្រុកទេសរៀងខ្លួន ស្អែកឡើងម៉ោង១២បានម៉ោដល់អំពេញ ។ អីចឹងបានថា ម៉ារាជហ្នឹងវាមិនដឹងយ៉ាងម៉េចទេ បុិនឃើញហៃ...ខ្ញុំជួបមិត្តភក្តិខ្ញុំខ្លះក៏គេម៉ោដល់៧៩ៗ គេទះនៅស្រុកទេសហ្នឹង ខ្លះទើបម៉ោកាលគេចរចារជាមួយសម្តេចព្រះករុណាហ្នឹង គេឲ្យតាមជិរំម៉ោក៏ម៉ោអីចឹងទៅ ខ្លះក៏នៅជិរំជាប់ទៅខ្លះក៏ម៉ោតាំងពី៧៩ហ្នឹងគេ ។ កាលជិនាន់៧៩ខ្ញុំមិនហ៊ានថា គេសិទ្ធតាអ្នកបេះបើម្នាក់ៗបើនិយាយទៅគេសិទ្ធតែបញ្ញាវ័ន្តជាន់ខ្ពស់ មើល ខៀវ សំផន ណាមួយមិនល្បី ប៉ុល ពត ណាមួយមិនល្បី សិន សេន ណាមួយមិនល្បី សាលាស្រុកខ្មែរលហួតសាលាស្រុកគេ ថ្នាក់បណ្ឌិតជាន់ខ្ពស់ហើយ អីចឹងអ៊ី...និយាយពីសង្រ្គាមសម្លាប់ខ្មែរគ្នាឯងវាហួសវានឹកស្មានមិនដល់ណា បុិនដល់ក្រោយពាក្យចចាមអ៉ាមយកយួនមកដាក់ខ្លួនអីចឹង អានេះយួន អានោះយួន មិនគេគិតយ៉ាងម៉េចទេ ប៉ុន្តែខ្ញុំអ្នកធ្វើផ្ទាល់ជាមួយវា ក្នុងអំពេញនេះ ខ្ញុំអ្នកលុយលុកតឹងអស់ ណាម៉ារាជហ្នឹងខ្ញុំជាអ្នកតូច នៅក្នុងក្រុងដែរហ្នឹងព្រោះទ័ពកាលហ្នឹងគេឲ្យនៅក្នុងក្រុងប្រជុំនៅក្នុងស្តាតអូឡាំពិករាល់ថ្ងៃនេះកន្លែងទ័ពប្រជុំហើយពហុកីឡាដ្ឋាននេះ កុំអីផ្ទុះតាំងពី៧៦នោះកុំតែវាគេចាប់ពួកអ៊ី...ហ៊ូ យន់, ហ៊ូ នឹម, សោ ភឹម ក្បាលម៉ាស៊ីនម៉ាជាន់មុនជាមួយ កុយ ធួន។ សោ ភឹម មិនភូមិភាគបូព៌ា លេខាភូមិភាគបូព៌ា ។ កុយ ធួន ឧត្តរ ហើយឈ្មោះ ធុច មួយទៀត ហើយ យ៉ា នោះភូមិភាគពាយ័ព្យ ហ្អេះច្រើនភូមិភាគណាស់គេចាប់ម៉ាហឹកហ្នឹងនិយាយឲ្យចំអត់តាម៉ុកមួយខ្ញុំនិយាយព្រឹកមិញហ្នឹង ។ ហ្នឹងអត់តា តាម៉ុក មួយទេ ហើយតាម៉ុក ហ្នឹងកូនប្រសារគាត់ឈ្មោះ តាវ៉ែនៗ សិទ្ធមេទ័ពមេអីទៀតណា ម៉ាហឹកតាម៉ុកហ្នឹងគាត់កាន់លេខាទូតទៀតណា បុិនយើងនិយាយពីរបបកុម្មុយនិស្ត លេខាបក្ស...គេហៅសមាជិកមជ្ឈឹមបក្សហើយៗដូចថា ភូមិភាគហ្នឹងសិទ្ធសមាជិកហើយ ដែលប្រជុំសំងាត់ៗហ្នឹងសិទ្ធមានមុខគេ ចូលរួមហើយ បុិននិយាយពីតាម៉ុក នោះ ថ្នាក់ទូច គេមាន៤,៥ ជាន់ទៅមុខទៀតនោះក៏គេមាន៤, ៥ជាន់ បុិន

សម័យប៉ុល ពត នោះហ្នឹង...អាថ្នាក់ត្រឹមវរសេនាតូច ត្រឹមកងពលមិនបាច់ដល់រដ្ឋមន្ត្រីទេ មានរដ្ឋមន្ត្រីខ្លះអត់ហ៊ានដាច់ខាតដូចពួកហ្នឹងផង ខ្លះសុខចិត្តចូលព្រៃណា ខ្លះសុខចិត្តបាញ់ខ្លួនឯង ដឹងតែចាញ់គេហើយនាំទ័ពចូលព្រៃ ដូចជាធ្វើជាចោរព្រៃ បន្តទំនាស់អីចឹង ។ ហ្អេ និយាយឲ្យត្រង់ៗហ្នឹងទៅព្រោះខ្ញុំអ្នកដើរលុកលុយកន្លែងហ្នឹងដែរ ។ ប៉ុនដល់និយាយសម័យឥឡូវខ្លះក៏និយាយត្រូវ ខ្លះគ្រាន់តែព្នាតាមគេហ្នឹងនិយាយទៅ ហើយខ្ញុំនិយាយខ្ញុំអ្នកកាន់អាកាំភ្លើងហ្នឹងហើ ។ ម៉ាស្រុកខ្មែរជំនាន់អាពតណា មានកាំភ្លើងការពារដែនអាកាសហ្នឹងមានតែកងពល១២ហ្នឹងទេ មានតែ៣វរទេ ៣វរ ។ វរ១៣២គឺវរខ្ញុំ ។ វ៉ែន វរ អាលឹម នៅជិតខ្ញុំរាល់ថ្ងៃនេះ ខ្ញុំនិយាយឱប-ក វរ១៣៦ មានវរ១២៨ ។ ម៉ាវរមានតែ៣វរហ្នឹងទេ ដែលមានកាំភ្លើងធំការពារដែនអាកាស អីចឹងវាមាន១០០លីបាញ់យន្តហោះហ្នឹងផង មានអា៣៧ផងមានអា៥៧ផង ។ បើ១០០លីខ្ញុំនិយាយហ្នឹងដូចអត់មានទេនៅស្រុកខ្មែរ រាល់ថ្ងៃហ្នឹងអត់ឃើញទេ ឃើញអាកាំភ្លើងភ្លោង១៣០ណា ប៉ុនកាំភ្លើងហ្នឹងស្រដៀងគ្នាកំពស់កំព ប៉ុនគ្រាន់វាមានកង់៤ អ្នកគ្រប់គ្រង អ្នកកាន់ផ្ទាល់ម៉ាដើមគេកាន់៧នាក់ ហើយគ្រាប់នោះវាមានសញ្ញាកំណត់ផ្ទុះរបស់វា បាញ់យន្តហោះវាមានអាម៉ាស៊ីនបញ្ជាវានោះវាវាស់ល្បឿនយន្តហោះ ហើយកំពស់យន្តហោះ ហើយល្បឿន ។ វាគិតអាល្បឿនគ្រាប់ ហើយម៉ាគ្រាប់វាហ្នឹងពេលដែលផ្ទុះទៅហ្នឹងវាមាន**៦០០អម្បែង** ហើយគេកំណត់ទៀតបើវាស់ទៅគេថាអ៊ី...៣៥០០ម៉ែត្រអីចឹងគ្រាប់នោះរត់ទៅ៣៥០០ម៉ែត្រត្រូវផ្ទុះ មិនបាច់បុកក៏ផ្ទុះទៅដល់កន្លែងហ្នឹងគឺផ្ទុះហើយព្រោះម៉ាស៊ីនបញ្ជាបស់វាសម្រាប់វាស់ហ្នឹង វាវាស់ល្បឿនយន្តហោះនិងវាស់ល្បឿនគ្រាប់ ហ្នឹងវាគិតស្អាត់មុខយ៉ាងម៉េច ហើយអា៥៧ហ្នឹងប៉ុន៥៧អីចឹងដែរប៉ុនអត់មានសញ្ញាកំណត់ផ្ទុះទេ ៥៧ដូចកាំភ្លើងយើងអា១២ធំៗណាទាល់តែបុកបានផ្ទុះអស់ខ្យល់បានផ្ទុះមានតែអា១០០លីទេ ដែលកំណត់បស់វាបាន ។ ហើយបើបាញ់ថ្មើរជើងក៏អីចឹងដែរ វាវាស់ថ្មើរជើងដល់ត្រឹមម៉ានគេវាស់ខ្នាតគេឧទាហរណ៍ចំណុចកណ្តាលវាត្រឹមហ្នឹងអាគ្រាប់ហ្នឹងវាផ្ទុះជំវិញអីចឹងហ្នង ។ អត់មានចាំបាច់ទៅបុកទេ ទៅដល់ហ្នឹងផ្ទុះយកហ្នង សាចយកហ្នង ខ្ញុំបាញ់សាកមើលហើយ ខ្ញុំហាត់ចប់ទៅបាញ់នៅត្រពាំងក្រឡឹងដែលគេ...កាលហ្នឹងសម្បូរ...កាលហ្នឹងសឹទ្ធតែមកពីចិនតឹង

អស់យើងនិយាយទៅ ចិនហ្នឹងសីទ្ធតាមានអាយន្តហោះតូចដូចយន្តហោះក្រដាស ប៉ុនយើងបញ្ជាបានអាប្រើម៉ាស៊ីន ដូចម៉ាស៊ីម៉ូតូអាម៉ូបីឡែតយើង គេបញ្ជាបាន គេសែងគ្នា ២នាក់គេសែងទៅ គេបង្ហោះម៉ាស៊ីនវាហោះទៅ ប៉ុនគេមានប្រដាប់បញ្ជាគេនៅដៃនេះ សម្រាប់អ្នកកាន់កាំភ្លើងដែលខ្ញុំនិយាយមិញនេះ កំពុងហាត់ ឬមួយគេទម្លាក់អាឆ័ត្រយោងតាមយន្តហោះហ្នឹងដែលវាដាក់ធុងសាំងដាក់ស្មៅដាក់ដីហ្នឹងណា ឲ្យបាញ់ៗអីចឹងទៅគេចង់សាកកាណុងថាកាណុងហ្នឹងវាខ្លាំងណាស់គ្រាប់ហ្នឹងវាខ្លាំងសូម្បីខ្ញុំនេះហៀរឈាមនិយាយឲ្យចំអាអ្នកកាន់កាប់មានម៉ានឆ្ងាយកណ្ដាស់ត្រចៀកតឹងអស់ លើកលែងតាអ្នកឆ្ងាយ១០០-២០០ម៉ែត្រពីកាណុង ។ ត្រឹមតា៤-៥ម៉ែត្រពីកាណុងគឺធ្លាប់ត្រចៀកតឹងអស់ហើយផ្ទះដែលធ្វើពីស័ង្កសីអីចឹងគឺឲ្យដកតឹងអស់កែវទឹកអីចឹង គ្រាន់តែវាមិនបែកខ្ទាយវាគ្រាន់តែស្រាំខ្ទាត់ខ្ទែងវាអន្ទះគ្រាប់ហ្នឹងវាព្ទែកណា ខ្លាំងពេក ហើយខ្ញុំចាំទៀតពេលដែលយួនជិតចូលប្រហែលជា៥-៦ខែយួនចូលកាំភ្លើងហ្នឹងគេដាក់នៅអារ៉ៃខ្សាត់ដាក់នៅអារ៉ៃខ្សាត់មួយចំនួននិងអូសទៅខាងគីរីវង្សខាងតាកែវ មានអូសទៅម៉ាក្រុមប៉ុនមិនដឹងក្រុមម៉ានទេ គេហ្នឹងគេចាប់ខ្ញុំទៅណា ប៉ុនដល់ខ្ញុំចាប់ធ្វើទ័ពចុងក្រោយវិញណាបានខ្ញុំជួបមិត្តភក្តិដែលធ្វើទ័ពចាស់ៗជាមួយខ្ញុំនេះគេថា គេនៅអារ៉ៃខ្សាត់ហែបានខ្ញុំទៅមើលទៅអារ៉ៃខ្សាត់ ជិះឡានទៅទ័ពទៅជាមួយគេហ្នឹង គឺនៅគ្រប់ចោលហ្នឹង ។ ធំៗណាស់កាំភ្លើងឡានវាឡានប្រវ៉ាក់អូសបានរួច ខុសពីឡានប្រវ៉ាក់អូសអត់រួចទេកាណុងវាខ្ញុំនិយាយភរចុះកាំភ្លើងហ្នឹងបាំងដើមត្នោតបាត់ណា ខ្ពស់ៗណាស់ គ្រាន់តាវាសារ៉េចេះទៅ ដើមត្នោត...សឹងកំពស់៥-៦ម៉ែត្រនោះ បាំងដើមត្នោតកាំភ្លើងធំៗណាស់ យើងគិតមើល គ្រាន់តែតួកាណុងមួយ៥ម៉ែត្រហើយគ្រាន់តែតួកាណុង៥ម៉ែត្រហើយនៅលើៗជើងវាទៀត ជើងវាកង់៤ ។ នេះឡាននេះក៏នៅតូចជាងតួជើងវាដែរនិយាយរួមបើអូសវិញណាអូសប្រហែលជាអាឡានស្ស៊ីដាក់អូសសម្រាប់ដាក់...ស្រដៀងគ្នា ព្រោះគេឲ្យឡានមួយសម្រាប់រត់អាវុធហ្នឹងម៉ាដើម កាលហ្នឹងគេមានកំភ្លេៗរបស់គេហើយ ។ ខ្ញុំចាំថា អាវុធហ្នឹងទៀត កាល៧៩ខ្ញុំអ្នកម៉ោស្រុកដែរ ខ្ញុំអ្នកដើរលើចូលទុកទួលស្លែងដែលខ្ទួនស-២២ខ្ញុំម៉ោចូលវិញតឹងអស់ចូលឃើញស្លាកស្នាមប៉ុនចម្លែកអាពតចេះ សង្កុមវាមួយចម្លែកខ្ញុំធ្លាប់អ្នកធ្វើសង្គ្រាមធ្វើសឹកធ្វើអីហ្នឹងគេលាក់ទោះបីជាខ្ទួនត្រឹម

ត្រូវមិនត្រឹមក៏ដោយគេលាក់ប្រវត្តិរូបណា  រឿងអីដូចឧទាហរណ៍គេចាប់ខ្ញុំគេក្រុងខ្ញុំអីចឹង នេះយកបិទអីចឹងនេះហើយសម្លាប់ក៏វាលែងសរសេរទុកបិតតាបឡូតាបអីដូចៗចុះដឹង ថាខ្លួនឯងចាញ់គេដែរ សមដែរអ្នកធ្វើគ្រប់គ្រងប្រទេសមើល មិនដឹងខ្លួនឯងចាញ់ មើលៗមិនមែនយួនម៉ាខេត្តវៃចូលណាប្រហែលជាព្រះកុរណា គេឲ្យចេញមុន ពេលដែលយួនវៃចូលដល់ជិតអ្នកលឿងឲ្យព្រះកុរណាចេញទៅមុនហើយ មិនដឹងថាចាញ់គេ ហើយចុះម៉េចឯកសារមិនបំបាត់ភស្តុតាងទុកអីសមបាត់ទេ  សឹទ្ធតាថតៗហើយដាក់ផែសម្លាប់ទៀត  អូនឯងមានដែលចូលគុកទួលស្លែងទេ  ថត...ព្រោះអាឡូវខ្ញុំអត់ដែលបានចូលតែពីមុនខ្ញុំធ្លាប់ចូលគុកទួលស្លែងមានដាក់ផែសម្លាប់មនុស្សណា  ហែអាខ្មោះអាស្អីហ្នឹងអ៊ី...អាស្អី  អាតាយ៉ូវដើងស៊ូកហ្នឹងគេដាក់គរចោលហើយអានិយាយអាឈាមជ័រនៅលើគ្រែវាបាត់អស់ក៏មិនដឹងប៉ុនកាលខ្ញុំចូលពី៧៩-៨០គត់  ចូល៧៩-៨០គត់នៅតឹងអស់ណាគេឲ្យចូលដែរមានផែគេឲ្យចូលរឿងអីវាទុកអាហ្នឹងសម្រាប់ឲ្យយើងឬវាទុកអួតថាវាបានសម្លាប់ប៉ុនណេះអ្នកអីចឹងវាចម្លែកខ្ញុំឃើញវា...សូម្បីតែខ្ញុំធ្វើទ័ពសូម្បីតែខ្ញុំធ្វើអ៊ីដែលវាមិនសមរម្យក៏មេៗប្រើឲ្យកប់ចោល២-៣កន្លែងខ្លាចអ៊ី...សត្រូវឬអ្នកម្ខាងចាប់ភស្តុតាងហ្នឹងបានអីចឹងណា  ហែអានេះអត់ទេ  វាទុកៗតឹងអស់ដែលជារូបភាពដែលថតដែលអ្នកគេត្រូវចាប់ដែលអ្នកសម្លាប់បើប្អូនឯងទាន់ម៉េចមិនដឹងទេពី៨០គត់  ៨១,  ៨២,  ៨៣ហ្នឹងគេឲ្យយើងចេញចូលហ្នឹងព្រោះផែអាទិត្យមានផែមួយបើកឲ្យចេញចូល  ព្រោះ ខ្ញុំចូលតាំងពី៧៩-៨០គត់ចូលកន្លែងដែលខ្ញុំស្គាល់ហ្នឹងចូលវិញ  ហើយឃើញនៅសំណាកហ្នឹងតឹងអស់មានដែរវាថតរូបវាបិត  អ្នកសម្លាប់លោកនេះ  លោកនោះអីចឹងហ្អា  ហែសឹទ្ធចម្លែកៗហើយសម័យអាពតនេះ  អីចឹងបានថា  រឿងឆ្ងល់វាអ្នកចេះប៉ុនហ្នឹងរឿងអីវាសម្លាប់មនុស្សដូចៗឆៅៗអីចឹង  ហើយវាសម្លាប់នេះវាដូចថា  សម្លាប់នេះវាដូចស្រួលរបស់វាហើយ  ហែវាសម្លាប់អត់ពិបាកទេ  តែយើងម្នាក់ៗវាភ័យៗចេះថាថ្ងៃណាមួយគេហៅទៅប្រជុំ  អាពាក្យទៅប្រជុំហ្នឹងច្រើនវាយកទៅវៃចោល  ពិសេសដូចអ្នកនៅស្រុកហ្នឹងវាមានកោះ...គេហៅគុក០៨អីចឹងណាអីចឹងបងប្អូនដែលយើងធ្វើទំនប់ប្រឡាយហ្នឹងណា  មើលទៅថាឆ្កួងអានេះខុសអានោះខុសវាចាប់យកទៅហើយ  យកទៅវាចាប់យកទៅហើយយប់ហ្នឹង  តាវាចាប់ណាហើយគ្មានបានមកវិញទេដូចថា  ១០០វាអាច

មាន១មាន២អីចឹងប្រហែលជាអាចរួចម៉ោវិញប៉ុន្តែភាគច្រើនគឺគេយកទៅវៃៗចោល អីចឹងហើយទ័ពពួកខ្ញុំនៅក្នុងកងពល៥០២ហ្នឹងក៏អីចឹងដែរ បើនៅៗអ្នកតូច ច្រើនតែអ្នកតូចអ្នកតាចអីចឹង បើមេៗសឹទ្ធតាទៅគេចប់បស់គេហើយហៃខ្ញុំមានចៅហ្វាយនាយកាលហ្នឹងថ្នាក់តូចៗហើយកាលហ្នឹងគេ ត្រឹមប្រធាន...គេអ្នកអីគេ...កាលហ្នឹងឈ្មោះ ម៉ន អារ៉េត នៅវត្តស្អី...ខាងជើងប៉ុស្តិ៍វិទ្យុស្ទឹងមានជ័យនេះ គេរកចាប់វា ប៉ុនចាប់អត់ទាន់វារត់រួចណា ប៉ុនការរត់ហ្នឹងគេចាប់បានឬមិនបានមិនដឹងទេប៉ុន្តែ ឈ្មោះ តាហ៊ីៗហ្នឹងគាត់ម៉ោគ្រប់គ្រងថ្មីដល់អីចឹងក្នុងថ្នាក់ជាប្រធាន...ហ្នឹងគេអត់ទាន់ចាប់...រកចាប់ តាហ៊ីហ្នឹងចង់វៃចោលណា ប៉ុន តាហ៊ី ហ្នឹងគេហៅម៉ោប្រជុំលើ...បាត់ទៀតទៅប៉ុនមិនដឹងកន្លែងណា ទេដល់អីចឹងអង្គរក្សតូចៗសឹទ្ធតែយកកុមារដាក់ហ្មងទៅកាលហ្នឹង ។ ហៃដល់អីចឹងក៏អាកូនៗតូចៗដែលនៅជាមួយតាហ៊ី ហ្នឹង វាថាបងឯងម៉ោធ្វើអី ថាម៉ោរកបងកាលហ្នឹងគេឲ្យទ័ពបំបែកពីកន្លែងម៉ាវរហ្នឹងម៉ាគរកន្លែងយើងនៅជាមួយហ្នឹងណា មានម៉ាក្រុមទៅធ្វើស្រូវនៅអន្លង់ក្ងាន ប្រាំងបាក់ៗអន្លង់ក្ងាន កន្លែងចាមនៅរាល់ហៃហ្នឹងនេះម៉ាក្រុមនៅធ្វើអីហ្នឹង ធ្វើស្រែកាលហ្នឹងធ្វើស្រែនៅស្អីទេ ធ្វើស្រែ មុំសឹទ្ធតែបឹងទៅធ្វើស្រែហ្នឹង ហើយបានអាកន្លែងហ្នឹងសម្រាប់បោកអាក្មេងៗហ្នឹងថាម៉ោខ្ចីម៉ូតូបង ហៃម៉ូតូកាលហ្នឹងសុទ្ធតែសេអ៊ិល ហៃដល់អីចឹងក៏ចាក់សាំងឲ្យគេជិះទៅបាត់ៗប្រហែលជាម៉ោង៥បានតាហ៊ីហ្នឹងម៉ោវិញៗបានបាត់ម៉ូតូៗបងម៉ន់យកទៅតាមនៅអន្លង់ក្ងាននោះ អ៊ឺ...ដល់ទៅគេតេអូសួរអ្នកនោះថាអត់ឃើញទេស្រាប់ឌុបតាម៉នហ្នឹងនិងអារ៉េតហ្នឹងរត់ ។ ដល់អីចឹងទៅតាមបាត់ម៉ាយប់ស្អែកឡើងអ៊ឺ...គេថាអ៊ឺ...វាហក់ម៉ោវិញហ្នឹងរួចទៅគេចាប់បានអីលិចនេះៗគេចាប់បានណាហ្អេ ប៉ុនកាលហ្នឹងក៏ងាយរត់ដែរបើរួចណាសឹទ្ធតាព្រៃឲ្យតែត្រឹមផ្សារថ្នល់ទទឹងនេះ ខាងលិចព្រៃតឹងអស់នៅម៉ាជួរថ្នល់ទេដែលអត់ព្រៃណា ចុះតាម៉ាគីឡូពីរគីឡូទៅក្រោមសឹទ្ធតាព្រៃទាំងអស់ស្រួលរត់ណាស់ ។ ប៉ុន្តែយើងកាលហ្នឹងម្នាក់ៗដូចវាមិនដាច់ខាតណាៗ អីចឹងបានថា ទ្វីបហ្នឹងដូចវាចាញ់រាសីអាពតហ្នឹង អីចឹងបានថានឹកឃើញថាសំណាងអ្នកពីម៉ាជំនៀរស្គន់ហ្នឹងម៉ោខាងបូព៌ាខាងស្វាយរៀងព្រៃវែងដោយសារអី ដោយសារពួកនោះនៅកៀកយួន អីចឹងមួយចំនួនវាចូលទៅជាមួយវៀតណាមបានម៉ោជាមួយវៀតណាមវិញកាលហ្នឹងវាមានវាសនាខ្ពស់ៗអីចឹងទៅ ហៃដល់ក្រោយៗ

ម៉ោទៀត ខ្ញុំមិនដឹងយ៉ាងម៉េចទេ ប៉ុន្តែខ្ញុំនៅជាមួយអាពតហ្នឹងវាធ្វើហួសហេតុអីចឹង និយាយទៅវាពិបាកមែនទែនទៅណា វាសម្លាប់មនុស្សដូចសម្លាប់ងាយសម្លាប់ពេក ថាសម្លាប់អ្នកមិនឈឺឆ្អាលក្នុងសង្គមវាទៅ អ្នកឈឺឆ្អាលក្នុងសង្គមវាក៏វាសម្លាប់ដែរ អាហ្នឹងមិនដឹងជានយោបាយកាលហ្នឹងវាមិនដឹងទៅយ៉ាងម៉េច រឿងអីខ្ញុំឮសួរគេបកស្រាយឮថាមានអ្នកលំអៀងលើអាពត ថាអ៊ីៗលើគំនិតយួនតឹងអស់ ហីរឿងអីយួននៅស្រុកគេសោះ ហើយនិយាយតែខ្មែរស្មានអ្នកទាំងអស់ស្គាល់ថាយួនបែរមុខទៅណា ទាំងគេទាំងមានស្គាល់យួនឯណា ហើយកើតម៉ោដឹងក្តីម៉ោនៅស្រុកខ្មែរហៃរំដោះ១៧មេសា ហើយម៉ោនៅស្រុកខ្មែរ អីចឹងគ្រាន់រំដោះហើយ ចុះអ្នកដែលធ្វើសង្គ្រាមធ្វើរដ្ឋប្រហារកាលជិនាន់ លន់ ណុល លីដែកប្រហោងលហូត ទីបញ្ចប់ថាស្លាប់ក្នុងជំនាន់លីដែកប្រហោងវ៉ៃជិនាន់ លន់ ណុល ចុះ ស្លាប់ចប់ទៅហើយនិយាយអាខ្លះគ្នាដូចថា រួចៗពីដែលសង្គ្រាមរួចពីអាជាតិម៉ាសេរហើយសម្លាប់យកគ្នាទៅសម្លាប់ចោលទៀត មែនខ្ញុំស្តាយអ្នកតស៊ូរាជហ្នឹងណាស់ៗ បើសិនការហ្នឹងការគ្រប់គ្រងគ្នាអប់រំគ្នា រកខុសរកត្រូវអីចឹងណា ខ្ញុំថាប្រហែលជាគ្មានអាណាហ៊ានលូកស្រុកខ្មែរយើងនិយាយទៅថា ស្រុកខ្មែរយើងអ្នកធ្វើការសម័យដែលអ៊ី...កាលវ៉ៃ ជំនាន់លន់ ណុល អីហ្នឹងសិទ្ធអ្នកល្ងង់ទាំងអស់លើកលែងតែត្រឹមក្បាលម៉ាស៊ីនកងពលឡើងទេ អាហ្នឹងបានអ្នកហ្នឹងថ្នាក់គ្រូបង្រៀនថ្នាក់កាសែតថ្នាក់ចាងហ្វាងកាសែតអី អាថ្នាក់តូចៗនិយាយទាំងគេទាំងខ្ញុំអ្នកកាយដីអាអ្នកស្ទូងស្រូវអីហ្នឹង ហើយរាជនោះ ប្អូនឯងជឿចុះមិនខុសប្លែកសព្វថ្ងៃហ្នឹងទេ ឲ្យទៅលីដែកប្រហោងអាអ្នកចេះដឹងអ្នកដែលគេមានជីវភាពធូរធារគេកម្រទៅលីដែកប្រហោងណាស់មានតែអ្នកល្ងង់ៗហ្នឹងណា បានទៅលីដែកប្រហោងអីចឹងបានស្តាយប្អូនៗជំនាន់ទ័ពសម័យក្រោយអីចឹងហើយឮសួរថាគេរំសាយអាសង្គមគេអីចឹងហើយធ្វើម៉េចត្រូវតាមសង្គមអីចឹងណា ចុះរំសាយអ្នកលីដែកប្រហោងខ្លះក៏ទៅសមស្របចឹងទៅ ខ្លះក៏ទៅឈឺចិត្តអីចឹងទៅៗ ខ្ញុំស្គាល់មិត្តភក្តិខ្ញុំម្នាក់នោះសក្តិ៥ដែររំសាយអាហ្នឹងរំសាយក្នុងឆាកល្ខោនមិនដឹងកាលអ៊ុនតាក់ចូលពីឆ្នាំ៩៣ណា ខ្លះក៏បាញ់ខ្លួនឯងទៅ ថាធ្វើអីមិនចេញជីវិតបដិវត្តន៍ខ្លួនអ្នកតស៊ូម៉ោ ឈាមបើនិយាយទម្រាំបានសក្តិ៥ហ្នឹងណាមិនមែនបានដោយសាររៀនសូត្រចេញពីសាលាឯណា អីចឹងចេះតែឡើងៗទៅដល់ទីចុងបញ្ចប់គេចាប់គេរំសាយ

អីចឹងទៅ  ប៉ុនប្រទេសជាតិគេរំសាយអីចឹងហើយប៉ុន្តែរកប្រឡោះដាក់ឲ្យបងប្អូនអី  ឲ្យធ្វើអីសម្រាប់ដល់ខ្លួនចាស់  អាត្រែតអីចឹងណា  ឲ្យគ្នាអស់ចិត្តណា  ព្រោះមើល  ខ្លះអស់តឹងកាយវិការ  អស់តឹងអវៈយវៈខ្លួនអស់អាលីងថ្មីត្បិតតែគ្នាអត់ចេះមែន  ប៉ុន្តែសាច់ឈាមអីយកទៅក្រាលៗដែនដីតឹងអស់  ហៃអ្នកម៉ោសម័យអាឡូវហ្នឹងបានពួកគេទាំងអស់  ប៉ុល  ពត  អាណាធ្វើអីកើត  ប្អូនឃើញស្រាប់ហើយ  សង្គ្រាមលហូត  ខ្ញុំតាមដានហ្នឹងខ្ញុំអាយុ៥០ដែរហើយហ្នឹង  សឹទ្ធសង្គ្រាមលហូត  ហើយប្រទេសយើងមិនមែនឈ្នះដោយបោះឆ្នោតទេណា  ឈ្នះដោយចុងកាណុងណា  ហើយដល់ក្រោយម៉ោរំសាយទៀតដូច  ប៉ុនបើរំសាយទ័ពរកការងារស៊ីវិលៗឲ្យធ្វើអីចឹងទៅវាអស់ចិត្ត  អាខ្លះរំសាយហើយម៉ោទាក់មងហើយអាខ្លះទៀតអត់ស្គាល់...ៗ  ជួនកាលបាន៣ខែមិនបានវាដឹកផងម៉ាយប់ផង  អីចឹងបានថាអ្នកដឹកអាណិតគ្នាអ្នកអីចឹងបានខ្ញុំទៅអំពេញឃើញអ្នកពិការសុំលុយអ្នក...លក់អាទឹកក្រឡុកចិញ្ចើមផ្លូវគេឲ្យដោយទើសចិត្តទើសអីអាខ្លះក៏សុំស្រួលទៅ  អាខ្លះអាអ្នកលក់ក៏អត់សូវចំណេញដែរយើងគិតមើលទៅយើងមានបងប្អូនដែលធ្លាប់លក់ដូរហើយ  ងាកសុំៗតែវាសុំមិនមែនយកទៅចិញ្ចឹមប្រពន្ធកូនឯណា  យកទៅលេងល្បែងយកទៅផឹកអីចឹងទៅណា  អាខ្លះឲ្យដោយទើសទាស់  អាខ្លះផឹកស្រាស្រវឹងដូចថា  រកគិតអីមិនយល់វាវ៉ៃអាតុក្កុយទាវវ៉ៃអាធុងទឹកកកអីគេចោលក៏មាន  អាហ្នឹងហេតុអីហេតុតែរឿងសង្គ្រាមហ្នឹងណា  ហេតុដែលឈឺចិត្តហ្នឹងខ្ញុំជឿថាវាអីចឹង  ហើយខ្ញុំឆ្នាំណានោះធ្លាប់ជួបអ្នកពិការម្តងដែរ  និយាយវ៉ៃហើយគាត់ទឹកភ្នែកណា...ដើម្បីអនាគតគ្នាផង  និយាយទៅវាអង្វរៗអ្នកបងៗដែលធ្វើសព្វថ្ងៃហ្នឹងឲ្យអាណិតគ្នា  ដើម្បីកុំឲ្យមានសង្គ្រាមតទៅទៀត  អីចឹងខ្ញុំតូចចិត្តដែរដែលមានបាយស៊ី  បើតូចវាខ្ញុំចប់អីចឹងបាននៅស្តាយវានិយាយទៅបងៗដែលធ្វើម៉ោទល់សព្វថ្ងៃ ។  ខ្ញុំអាណិតណាស់  ព្រោះខ្ញុំអត់បានរៀនសោះព្រោះរឿងអី  និយាយឲ្យខ្លីចេះឆាប់ចប់ដូចចាញ់បោកសង្គមអីចឹងដូចចាញ់បោក  បើគេថាគេមិនចាញ់បោកមើលទៅដូចហាំៗ  បើឯងអ្នកចាញ់បោកអីចឹងទៅដូចសំរាមអីចឹង  ហើយគេអ្នកមិនចាញ់បោកអីចឹងទៅដូចហាំ  អូនឯងពិចារណាមើល  អ្នកខ្លះដូចអត់មានជាតិបូវក្នុងខ្លួនអីតិច  ប៉ុនវាសនាគេខ្ពស់  ឡើងហាំៗ  ហើយអាអ្នកដែលល្ងង់ៗដូចពួកខ្ញុំអីចឹងយូរៗខ្លះក៏វិនាសខ្លួនបាត់ទៅខ្លះក៏នៅ  អាខ្លះក៏មានខ្សែស្រឡាយធ្វើការធំអីចឹងទៅស្ទូកតាមប្រកល្អកអីចឹងទៅ

ខ្លះក៏អត់ចប់ ហើយដូចខ្ញុំអីចឹងទៅចប់ៗ បើមានអ្នកស្គាល់ចេះតែទៅតាមគេទៅ អីចឹង ហើយដូចខ្ញុំក្តីប្អូនក្តីចេះតែអាណិតអ្នកពិការ អាណិតអីចឹងទៅអ្នកខ្លះអស់ ខ្លះក៏ត្រូវអធ្យាស្រ័យ...យូរៗបើគិតវែងអត់អីទេ បើគិតខ្លីឆៅៗ...គួរណា តែរកការងារឲ្យគ្នាធ្វើដើម្បីចិញ្ចឹមជីវិត ព្រោះខ្ញុំឆ្អែតពេក អាពត ថាវាឆ្អែតទៅ ហើយសម័យយើងអាឡូវហ្នឹងទុកមិនធ្វើការធំដំកំប៉ិចកំប៉ុកហ្នឹងដូចថា វាឆ្អែតកាលសម័យដែលកាលហ្នឹងខ្ញុំរៀនរហូត រៀននយោបាយបង្ហាត់គេអីហ្នឹងគេឲ្យទៅរៀនប៉ិនមិនបានមានមុខមាត់អីធំដំអីចឹងទេណា ខ្ញុំរៀនកំប៉ិចកំប៉ុកនៅតាមខេត្តអីចឹង ហើយសមតែគេត្រូវគ្នាអីចឹងទៀត អ៊ុ...សឹងតាដាច់ការងារ ប៉ុនតែចេះតែនៅយូរៗ...ខ្លះក៏គេឈប់ហើយ មានធ្វើអីទេ មានតែធ្វើស្រែខ្លះ ហើយធ្វើហ្នឹងនិយាយឲ្យចំទៅកុំអីឈប់ដែរហើយនិយាយឲ្យអស់ ធ្វើសម្រាប់អ្នកអ្នកប្រឆាំងខ្លះទេបើតាមគំនិតខ្លួនប៉ុន្តែអ្នកខ្លះនោះគេចេះតែនិយាយចេះនិយាយចុះ ចង់ធ្វើអីចឹងដែរ ក៏ធ្វើ ហ្អែងអស្ចារ្យជាងអញម៉ានទៅបើហ្អែងអត់ដែលធ្វើផង ចេះគិតអាគំនិតផ្តាញ់ផ្តាល បើយើងនៅធ្វើជាប់អីចឹងណា អីចឹងបានថា ខ្ញុំមិនគិតគណបក្សណាទេបក្សណាក៏ដោយ ឲ្យតែមានគំនិតស្នេហាជាតិ ជឿលើសង្គមជាតិកែលម្អកុំមានគំនិតផ្តាញ់ផ្តាលគ្នាឲ្យសោះ ខ្ញុំឃើញពាក្យខ្លះរកតែឲ្យវាស្រួលសុខអី...អូនអើអ្នកធ្វើសង្គ្រាមខ្លះគរឃ្លាចដាក់ខ្លួនទៅតាមអាធម្មជាតិពីកំណើត...មានមិត្តភក្តិខ្ញុំច្រើនណាស់ ខ្លះហួសចិត្តទៅយូរៗទៅផឹកស្រាៗហ្នឹងវាកាត់សាយ ខ្លះផឹកទៅងាប់ខ្លួន ខ្លះឡានបុកក៏មានអីចឹងទៅ...បានខ្ញុំស្តាយមែនទែន ស្តាយដូចថា ណាមួយមិនត្រូវការបញ្ចប់សង្គ្រាមមិនអីចឹង ហែតាមានសង្គ្រាមកូនខ្មែរយើងហូបតិចតួចណាស់ ឲ្យទៅធ្វើទ័ពហើយពេញចិត្តក៏ទៅ មិនពេញចិត្តហាក់ដូចជាបន្ទំហើយ មិនបន្ទំមិនកើតព្រោះសង្គ្រាមវាកើតហើយអីចឹងបានថាបានជាអស់លោកចូលម៉ោសិទ្ធតែអ្នកចេះៗទុកតែយ៉ាងម៉េចពាក្យសម្តីយ៉ាងម៉េចអត់ធ្មត់ទៅ ធម្មតាទេ អីចឹងបានថា បានខ្ញុំនិយាយចេះ ខ្ញុំមិនដឹងប្អូននៅខាងបក្សណាទេ ប៉ុនមូលហេតុដែលខ្ញុំមិនដើរចោលគណបក្សប្រជាជនដោយមូលហេតុដូចខ្ញុំនិយាយអីចឹង វាពិបាកពេញចិត្តថ្មីតែវាមិនជឿនលឿន ហើយអ្នកធ្វើការគណបក្សប្រជាជនភាគច្រើនមិនមានតំរិះវិជ្ជាដូចជាថ្នាក់បណ្ឌិតអីចឹងគឺអត់មាន ប៉ុនតែគេត្រួសត្រាយចេះតែមានដំណើរៗគ្រាន់តែគេមិនយកអង្ករយកម៉ោដាក់ពាងឲ្យយើងមែនប៉ុនតែខួរក្បាលយើង

បើយើងថា យើងមានគំនិតអាក្រក់គេដើរខោក ៗ កាលពីដំបូងដែលយើងដើរស៊ីពោតសំឡីស៊ីអីដំបូងក៏ងាប់អស់ដែរ កុំឲ្យថាមានគំនិតអីចឹង ៗ វាអត់សុខគ្នាទេ ។

សុជា: អីចឹងបានថា ខ្ញុំចង់សួរពូពីដើមវិញណា ពូកាលហ្នឹងពូចូលបដិវត្តន៍ឆ្នាំណាដែរ?

ធី: បើនិយាយទៅ បើខ្ញុំចូលទ្រង់ទ្រាយតូច ៗ តាំងពី៧២ខែ៤ចូលឆ្នាំខ្មែរហ្នឹងនេះ ប៉ុន្តែបើនិយាយពីលីដែក...តាំងពីហ្នឹងទៅ តាំងពីដីរំដោះអត់ទ័ពនោះនៅឈ្លបនោះ ប៉ុន្តែពីទ័ពវៃទាហាន លន់ ណុល ស្អិតរមួតណាដើមឆ្នាំ៧៣ ចុង៧៣ខ្ញុំវៃអស់ហើយតាំងពីទន្លេបាសាក់ហ្នឹងធ្លាក់ម៉ោផ្លូវជាតិលេខ២...ម្តុំអីនេះ អីឃ្លាំងមឿន ឃ្លាំងអីសៀមរាប ត្រាំខ្នាត្រាំអី ដល់កញ្ជរដល់អី សឹទ្ធតែទឹកដីខ្ញុំលីដែកប្រហោងហើយនិយាយឲ្យអស់បានថាវាស្គាល់រស់ជាតិសង្គ្រាមហ្នឹងវាដោះអាវម៉ោវាចេញផ្សែងគ្រាប់ទាំងអស់ហ្នឹង ។ អីចឹងបានថា ដល់ចប់១៧មេសាហើយអីចឹងទៅដល់រាជអាពតដែលអត់ឃើញសង្គ្រាមណាដល់ក្រោយម៉ោ៧៩ហ្នឹងអូហ៏ដូច...ប៉ុន្តែមិនមែនសង្គ្រាមក្នុងប្រទេស តាជាយ ៗ ដែនហ្នឹងដូចថាខាងត្រីភាគីព្រះករុណាអីនៅខាងណោះស្អីក៏នៅខាងណោះអីណោះអីណោះ ចោទនៅយួនចោទស្អីហ្នឹងអាហ្នឹងខ្ញុំវាមិនដឹងនយោបាយវាយ៉ាងម៉េចតែ ប៉ុន្តែអាហ្នឹងមិនសង្គ្រាមអ្នកនៅណោះមិនប្រឆាំងជាមួយយើងមិនត្រូវខាងទ័ព អីណោះអ្នកកាច់ចង្កូតប្រទេសជាតិខាងណោះមិនត្រូវការទ័ព ហើយបើមិនត្រូវការទ័ពបានអីច្បាំងគ្នា ហើយសមកាលយួននោះគេឲ្យដក កាលយួនហ្នឹងគេមិនសូវរើសទ័ពម៉ានទេ ដល់៧៩ដាច់អស់ចាប់ក៏ខ្លាំងរើសក៏ខ្លាំងចុះអស់អ្នកតាមិនស្រួលហ្នឹងប៉ុល ពត ម៉ោនៅវិញអាដែលហើយមិនរើសទ័ព ៗ ហើយក៏បន្ទំទៀត សូម្បីតែសិស្សសាលាក៏ពិបាករៀនសូត្រដែរយើងនិយាយម៉ាម៉ាត់ក្មេងរៀនក៏ពិបាករៀនសូត្រដែរ បានថាវា... ។

សុជា: ចុះពូកាលចូលបដិវត្តន៍ហ្នឹងមុននឹងចូលពូមានបានរៀនបានសូត្រអីក្នុងភូមិហ្នឹងទេ?

ធី: អត់ទេ អត់រៀនសូត្រអីទេ ។

សុជា: អត់?

ធី: បេះ សង្គ្រាម៥ឆ្នាំហ្នឹងវៃលន់ ណុល ហ្នឹងខ្ញុំប្រាប់ប្អូនឯងអត់មានសាលាទេ ។

សុជា: ចុះមុននឹង៧០មុនឆ្នាំ៧០?

ធី៖ ខ្ញុំនិយាយមុនឆ្នាំ៧២ហ្នឹងហ្អា ខ្ញុំនៅរៀននៅសាលាបឋមនាយអាយនៅនឹងដីលន់ ណុល ហ្នឹងដែរនិយាយឲ្យឃើញទៅ ប៉ុន្តែដោយរាជហ្នឹងវាមានសង្គ្រាម ដល់មានសង្គ្រាមទៅក៏ខ្ញុំហ្នឹងទៅខាងដីរំដោះៗខាងគ្រួសារខាងឪពុកខ្ញុំនៅខាងដីអំពេញដីខាងលន់ ណុល ហ្នឹងហៃដល់ក្រោយម៉ោបានគាត់ចូលទៅតាមក្រោយហ្នឹង ។

សុជា៖ ពូរៀនៗសាលាណា?

ធី៖ ឈូង លាប នេះ ។

សុជា៖ ឈូង លាប ហ្អី?

ធី៖ បាទ! ឈូង លាប អាគារខ្ពស់ខាងជើងនេះ ។

សុជា៖ ពូរៀនបានថ្នាក់ទីម៉ានដែរ?

ធី៖ កាលហ្នឹងបាន ថ្នាក់ទី៨ហ្នឹង ។

សុជា៖ ចុះពូថា កាលរៀនៗក្នុងដីរំដោះទេ ហ្អាដីលន់ ណុល ចុះដល់ពេលហេតុអីបានពូចូលទៅដីរំដោះវិញ?

ធី៖ រឿងចេះ កើតសង្គ្រាមហ្នឹងគេមិនវៃ លន់ ណុល ដីរំដោះគេវៃរំកិលៗអីចឹងហៃខាងដីរំដោះហ្នឹងក៏គេមានគោលនយោបាយម៉ោដីន៍លន់ ណុលនេះ អីចឹងក៏គេប្រមូលអ្នកស្រុកខ្លះក៏គេកៀរទៅ ខ្លះក៏គេហៅ ហៃអាខ្លះក៏គេពេញចិត្តទៅៗឃើញនយោបាយខាងខ្មែរក្រហមវាល្អហើយសមព្រះករុណាហ្នឹងមិនស្រែកពីប៉េកាំងម៉ោហើយឲ្យដែលកូនចៅចូលព្រៃម៉ាកគី ហើយយើងតាមកាលហ្នឹងគ្មានអ្នកណាចង់ធ្វើសង្គ្រាមទេ ចង់បានតែឪ ដូចថាមានគំនិតចូលគ្រប់គ្នាចង់បានតែព្រះករុណា ចូលស្រុកមិនអីចឹង ចៃដន្យដល់១៧មេសាហ្នឹងទៅជាប៉ុល ពត កាន់អំណាចកាន់អីវិញអីចឹងកាលហ្នឹងធ្វើសង្គ្រាមដើម្បីព្រះករុណាឆ្គួតតឹងខ្ញុំឆ្គួតតឹងគ្រូដែលចុះទៅដីរំដោះហ្នឹងណា ហៃទៅជួប ខៀវ សំផន នៅសាលាស្រុកកោះធំនោះកាលហ្នឹង ខៀវ សំផន ម៉ោសាលាស្រុកកោះធំ កាលហ្នឹងសាលាស្រុកកោះធំដីរំដោះដែរ ហើយតែដីលន់ ណុល តែត្រឹមព្រែកតូចនេះ ត្រឹមផ្សារព្រែកតូចនេះម៉ោលើដីលន់ ណុល ខ្ញុំនិយាយឲ្យអស់ត្រឹមហ្នឹងទេណា ។

សុជា៖ ហ្នឹងក្នុងឆ្នាំ៧២ហ្នឹង?

ធី៖ ៧២ដីលន់ ណុល តាត្រឹមផ្សារស្អាង ។

ម៉េងទ្រី: ខែម៉ាន.?

ធី: ហ្អេ ខ្ញុំអ្នកចុះទៅត្រឹមខែ៨ប៉ុន្តែដីហ្នឹងក៏ខ្ញុំចុះទៅប្រហែលជា៨-៩ខែទេ បានៗរំកិលចូលម៉ោះបេះទៀត ។ ប៉ុនខ្ញុំចាំជាងត្រឹមអ្នកចេញពីនេះ ដីអាការពោតទៅដីរំដោះហ្នឹងខែ៨ ។

ម៉េងទ្រី: ចុះពេលដែលចេញទៅឪពុកម្តាយគាត់នៅតឹងហ្នឹង?

ធី: នៅតឹងអស់ ។

ម៉េងទ្រី: ចុះពូទៅតែម្នាក់ឯង?

ធី: ទៅតែម្នាក់ឯងទៅដោយខាងជីដូនមាមីងខាងម្តាយខ្ញុំណា ជីដូនមួយខាងម្តាយខ្ញុំ ។ គេទៅទាំងគ្រួសារទៅដីរំដោះហ្នឹងណា ។ កាលហ្នឹងបើយើងនិយាយឲ្យចំគេជម្លៀសទាំងហូរអីចឹងទៅ កៀរចូលព្រៃហ្នឹង វត្តមួយៗគេច្រើនអ្នកស្រុកទៅនៅវត្តហ្នឹងដែរ គេចល័តកម្លាំងគេចុះទៅធ្វើ...ប៉ុនតែខាងៗហ្នឹងទ័ពគេនិយាយទ័ពខាងហ្នឹងគេអត់ចាប់ទេគេឲ្យយើងស្ម័គ្រចិត្តណា ប៉ុន្តែដីរំដោះមានទ័ពយួនដីរំដោះម៉ាហឹក៧១-៧២ហ្អខ្ញុំចុះទៅក៏មានទ័ពយួននៅដែរ ប៉ុនយួនហ្នឹងណា គេហៅយួនវៀៗយួនខាងជើង...ហាណូយ ហើយដល់គាពេលខ្ញុំចូលបានម៉ាវរៈៗនៅតំបន់២៥នេះ ចាប់គេឲ្យយួនចេញ...បើយួនចេញបើមិនចូលឆ្នាំ៧២ ដើមឆ្នាំ៧៣យួនចេញអស់ហើយពួកខ្ញុំទៅបានតារវាងតា៨-៩ខែអស់យួនដែរក្នុងដីរំដោះ ប៉ុន្តែយួននៅគ្រូៗបង្ហាត់ដោះមីនបង្ហាត់អីមានគ្រូយួន ព្រោះបានខ្ញុំនិយាយថាខ្ញុំធ្វើទ័ពហ្នឹងអត់មានគ្រូបង្ហាត់ច្បាំងទេ ប៉ុន្តែបើសិនណាវៃទៅកន្លែងណាដែលចាញ់ទាហានលន់ ណុល ខាងស្ទីដែលមិនឈ្នះ ឬបាក់បស់ទាហានលន់ ណុល អីណា កាលហ្នឹងគេយកអាផែនការហ្នឹងម៉ោស្រាវជ្រាវនៅដីរំដោះអន្តភាពយួន ចាញ់គេៗហេតុអីបានចាញ់គេ ហើយបើឈ្នះគេក៏ធ្វើម៉េចបានឈ្នះគឺគេបំប៉ន ទ័ពនៅពេលហ្នឹងណា អាហ្នឹងហើយដែលក្បួនទ័ពដែលខ្ញុំធ្វើទ័ពនៅសម័យ ប៉ុល ពត កាលនោះ គឺអត់មាននយោបាយអីក្រៅពីហ្នឹងទេ ។

សុជា: ចុះពូៗចុះទៅដីរំដោះហ្នឹងពូទៅនៅភូមិណា?

ធី: នៅៗដំបូងទៅនៅភូមិកោះខែលៗដល់ឪពុកខ្ញុំនេះចុះទៅដែរបានម៉ានខែ ក្រោយទៀតព្រោះកោះខែលហ្នឹងគេអត់ឲ្យយើងនៅទេ ព្រោះកៀកដីលន់ ណុល ណា ព្រោះស្រុកស្អាងម៉ាចំហៀងដី លន់ ណុល ស្រុកស្អាងម៉ាចំហៀងនៅ...ដីរំដោះប៉ុន្តែបើអ្នកចាស់បាន

គេឲ្យនៅ បើអ្នកថ្មី...គេចេះប្រាន...ប៉ុនកាលហ្នឹងខ្ញុំទៅដំបូងនៅជីកោះខែលកាលហ្នឹងខ្ញុំថា ឡើងមើលៗផ្លូវមើលអី...គឺចិត្តមួយចង់ម៉ោស្រុកវិញដែរព្រោះឪពុកអត់ទៅ ព្រោះកាលហ្នឹងខ្ញុំនៅស៊ើរៗដែរអាយុទើប១០-២០អីដែរ កាលហ្នឹងចង់ម៉ោស្រុកវិញព្រោះនឹកផ្ទះ ប៉ុន្តែបានម៉ាន៤-៥ខែបានឪខ្ញុំគាត់ចុះទៅ ។

សុជាៈ ទៅទាំងអស់គ្នា?

ធីៈ ទៅតាគាត់ហ្នឹងដែរ ។ គាត់ចោលឪពុកគាត់នៅអំពេញនេះចោលទៅៗតាមហ្នឹង ទៅបង្អួសកោះធំបានចុះទៅអឹតគាត់បាន២-៣ខែក៏វិអាព្រែកតូចនេះ អាផ្សារស្អាងនេះ បែរជាឡើងទៅនៅសំបូរៗ គឺខ្ញុំហ្នឹងបែកពីឪពុកខ្ញុំត្រឹមហ្នឹងព្រោះកាលហ្នឹងខ្ញុំដើរជាមួយ ចៅហ្វាយស្រុកដីរំដោះនោះព្រោះកាលហ្នឹងគេមានស្រុកមានអីដែរ ហ្នឹងហើយកាលហ្នឹង លីដែកប្រហោងធ្វើឈ្លបស្រុកឈ្លបអីណា ហើយដល់អីចឹងគាត់ចូលម៉ោនៅនេះវិញ ខ្ញុំក៏ គេឲ្យទៅភូមិភាគពិសេស គេឲ្យទៅភូមិភាគពិសេសលែងស្គាល់អាស្រុកព្រែកតូច ស្រុក ជួរទន្លេបាសាក់ផ្លូវជាតិលេខ២ផ្លូវជាតិលេខ៤ ប៉ុន្តែដូចថ្នល់ជាតិលេខ៤អីទាហានទៅតាម ថ្នល់លហូតណា ប៉ុននៅព្រៃៗហ្នឹងគ្រាន់តាយប់ឆ្លងកាត់តាមថ្នល់បានប៉ុនតាយប់យើងនៅ តាមព្រៃៗឆ្ងាយពីថ្នល់ហ្នឹងប្រហែលម៉ាគីឡូហ្នឹង ឬគីឡូ ។

សុជាៈ ចុះពូចូលទៅដំបូងពូចូលទៅភូមិណាៗចូលទៅបដិវត្តន៍?

ធីៈ កោះខែល ។

សុជាៈ កោះខែល ទៅក្នុងកងអីដែរ?

ធីៈ គេហៅស្រុក២០អត់ទាន់មានអី...នៅស្រុក២០បានម៉ានខែបានចូលទៅតំបន់ ។ បាន៥-៦ខែបានចូលទៅភូមិភាគពិសេស ។

សុជាៈ ចូលដំបូងចូលនៅស្រុក?

ធីៈ នៅស្រុក ។

សុជាៈ ស្រុកហ្នឹងក្រោមការគ្រប់គ្រងរបស់ពីណាគេដែរ?

ធីៈ កាលហ្នឹងរាជហ្នឹងខ្ញុំនិយាយទៅ ក្រោមការគ្រប់គ្រងរបស់ បងម៉េង...អាហ្នឹងទ័ពទេណា ហើយបើ...អ៊ុ...អាហ្នឹងចៅហ្វាយស្រុក តាប៉ិត ចម្រើន តាសុខ បញ្ជាការតំបន់ ហើយ ចៅហ្វាយស្រុកខ្ញុំមិនចាំទេ មិនដឹងឈ្មោះអីទេ...ដូច តាក្នុងមិនដឹង ប៉ុនចាំជាងគេអ្នកកាន់

ទ័ព មាន បងស្រអែម, ម៉េង ហុង ស្អីពនាក់ទៀត ជាសមាជិកហ្នឹងក្បាលម៉ាស៊ីនគ្រប់គ្រងទ័ពម៉ាស្រុកហ្នឹងណា ។ ខ្ញុំស្គាល់តាប៉ុនហ្នឹងទេ ចៅហ្វាយស្រុកដែលគេវិលវិញដូចជាមិនហ៊ានថាច្បាស់ទេ ដូចជា តាដុង១ ព្រោះកាលហ្នឹងចៅហ្វាយស្រុកកាលហ្នឹងប៉ុនខ្ញុំវាមិនសូវស្គាល់ៗជាងគេគណៈតំបន់ហ្នឹងអាសារម៉ោមើលទ័ពដូចថា ទ័ព...ជប់លៀងជប់អីគណៈតំបន់ម៉ោចូលរួមព្រោះគណៈតំបន់កាលហ្នឹង៥នាក់ណោះ មាន អាវ៉ន ។

សុជាៈ វ៉ន អី?

ធីៈ កាលហ្នឹងគេហៅ វ៉ន វ៉េត១ ។ ប៉ុនក្រោយម៉ោគាត់ឡើងលេខាភូមិភាគពិសេសទៀតប៉ុននិយាយពីសង្គ្រាមណាមាន តាវ៉ន, តាសុខ, ហួត សេ, តាជ័យ, នង សួន...ហ្អេនង សួន ដូច តាវ៉ន ហ្នឹងហើយ ឈ្មោះខុសគ្នា ម្នាក់ៗច្រើនមានឈ្មោះ២ ។

សុជាៈ នង សួន ហៅ ជ័យ?

ធីៈ ហ្នឹងហើយ ត្រូវហើយ ។

សុជាៈ ចុះការងារយើងចូលដំបូងគេឲ្យធ្វើអីខ្លះទៅ?

ធីៈ មានធ្វើអីទេ គេឲ្យលីដែកប្រហោងម៉ាមុខហ្នឹង តាលីដែរប្រហោងម៉ាមុខហ្នឹង ។ អូសកាំភ្លើងចូល ។

សុជាៈ គេឲ្យធ្វើអីអាការងារលីហ្នឹង?

ធីៈ ដែកប្រហោងគេឲ្យធ្វើឈ្លបឡើងម៉ោឆ្មក់តាមបន្ទាយហ្នឹង តាមអីដូចថាឧទាហរណ៍ខ្ញុំថាព្រែកតូចអីចឹងណា អីចឹងគេឲ្យនៅយាមអាកន្លែងព្រែកតូចម៉ាគីឡូខ្មាចទាហានវ៉ៃចុះទៅក្រោមជីកត្រង់សេអីទុកអីចឹងណា សម្រាប់ចុះចល័តអីតាមហ្នឹងទៅជួនកាលលបម៉ោឆ្មក់រំខាន កាលហ្នឹងបច្ចេកទេសអ្នកប្រយុទ្ធទី១រំខានទាហានមិនឲ្យដេកបាន ទី២ អាបន្ទាយហ្នឹងអត់វ៉ៃទេ នាំទ័ពកេវកុងអីចឹងម៉ោវ៉ៃខាងលើ បន្ទាយធំនៅព្រែកតូច អីចឹងបន្ទាយតូចៗនៅចល័តតាមព្រែកម៉ាកន្លែង៤-១០នាក់ ៤-១០-២០នាក់អីចឹងណា ជួនកាលអត់វ៉ៃព្រែកតូចទេ នាំទ័ពម៉ោវ៉ៃ**ព្រែកប្រសព្វ** ខ្លះក៏វ៉ៃតាខ្មៅហ្លួងទៅព្រោះទាហាន តាមថ្នល់ហ្នឹងហៃដូចទួលក្រសាំងៗទើបនឹងមានផ្លូវអាឡូវតើពីដើមសិទ្ធតាវាលស្មោ វាស្រែ បានថាអាអ្នកទ័ពវាដើរអីចឹងវាដើរបើកផ្លូង ព្រោះកាលហ្នឹងទ័ពសិទ្ធតាមានដែនទីអ៊ី...គ្រាន់តាថាកើតមិនកើតអីអាដែនទីដាក់ស្ដេងន៉ែ ឡើងទៅស៊ើបភូមិម៉ានតិចម៉ោ អានោះទៅស៊ើប

គូសតិច ហើយដុំដែនទីគូសយប់ហ្នឹងក្រុមអ្នកឯងឡើងវៃកន្លែងណាឡើងឆ្នក់កន្លែងណាមិនបាច់វៃយកឈ្នះទេ វៃគ្រាន់តារំខានអីចឹងហៃដល់ផែនការវៃយកឈ្នះបានគេមានផែនការដូចថា រដូវប្រាំងអីចឹងបានគេមានផែនការវៃយកឈ្នះដែរណា ហៃអាផែនការឆ្នក់ដូរកម្លាំងឡើងម៉ាយប់អីចឹង គ្រាន់តែថាបើមិនបន្ទាយនេះបន្ទាយនោះៗអីចឹងទៅ ។

ម៉េងទ្រី៖ ពូអ៊ុ...មូលហេតុសំខាន់អីខ្លះដែលធ្វើឲ្យពូចូលរួមក្នុងចលនាខ្មែរក្រហម?

ធី៖ វាចេះដូចខ្ញុំធ្លាប់និយាយជាមួយប្អូនឯងម្ដងហើយ ខ្ញុំម៉ោតាម ហ៊ូ នឹម, ហ៊ូ យន់, ខៀវ សំផន ហើយសមព្រះករុណាស្រែកពីៗ ប៉េកាំងម៉ោផងឲ្យចូលព្រៃម៉ាកគី ហើយ ខៀវ សំផន ណាមួយមិនល្បីថា ខៀវ សំផន មណ្ឌលព្រែកអំបិល តំណាងរាស្ត្រអ្នកស្អាតស្អំអីចឹងណា ហើយគាត់អ្នកឆ្លាតវៃក្នុងព្រៃ ប៉ុល ពត នេះទើបម៉ោពុក្រោយទេ អ្នកណាមិនល្បី ខៀវ សំផន, ហ៊ូ នឹម, ហ៊ូ យន់ សូម្បីតែចម្រៀងក៏គេតែងដែរ រៀមច្បង...សូម្បីតែចម្រៀងពីជីវំដោះហ្នឹងក៏គេតែងអីចឹងដែរទើបម៉ោអ៊ុ...៧៧ហើយបានពុប៉ុល ពតហ្នឹង ។

ម៉េងទ្រី៖ ចុះពូមានពូមានដឹងពីគោលដៅនៃបដិវត្តន៍ហ្នឹងទេ?

ធី៖ អត់ដឹងទេ ដឹងតែអីចេះម៉ាមុខ ថាអ៊ុ...ដូចជាចូលព្រៃម៉ាកគីអីចឹងទៅថ្ងៃក្រោយបដិវត្តន៍យើងស្អាតស្អំគ្មានអ្នកមានគ្មានក្រអីចឹងណា សូម្បីគេលើកឧទាហរណ៍អ្នកធ្វើចៅហ្វាយស្រុកហ្នឹងបណ្ដោះអាសន្នទេ គេនិយាយអីចឹង ដល់ថ្នាក់តំបន់នេះក៏បណ្ដោះអាសន្នដែរប្រធានរោងចក្រអីហ្នឹងសិទ្ធបណ្ដោះអាសន្នទេ ដល់យើងធ្វើសង្គ្រាមចប់បានគេចម្រាញ់គឺយកអ្នកឆ្លាត យកអ្នកចេះអត់ធ្លុត អ្នកឆ្លាតអ្នកប្រសប់ អ្នកអត់ធ្លុត់ ព្រោះអ្នកអត់ធ្លុត់វាឆ្លាតហ្នឹងម៉ោពីអ្នកលីដែកប្រហោងហ្នឹងហើយអត់ធ្លុត់ ចេះអត់បាយព្រោះទ័ព អូនអើយខ្ញុំនិយាយមួយម៉ាត់ ខ្ញុំនេះអត់បាយ៥ថ្ងៃក៏មានដែរ ច្បាំងណា គេវែកបាយអត់ឲ្យគេយកទៅវៃជិតចូលអំពេញនេះវៃអាចិតរើសនេះ ជិតដីថ្មីទេពប្រណមនេះដាច់បាយម៉ាអាទិត្យអាខែ២-៣ខែទៀតបែកអំពេញនេះ២-៣ខែទៀតបែកអំពេញខ្ញុំអត់បាយណាទាហានព័ទ្ធជាប់ ខ្ញុំអត់បាយ៣ថ្ងៃងាប់ក៏នៅហ្នឹងស្អុយឡប់ខ្មែហ្នឹងទម្រាំតែដោះស្រាយវៃយកប្រឡោះចេញវិញណា អាហ្នឹងអត់បាយអត់ស្គាល់ជាតិបាយ កន្លែងខ្លះអត់ម៉ាថ្ងៃកន្លែងខ្លះស៊ីបាយដួម ព្រោះយើងមិនមែនទៅដាំបាយណាស៊ីមានតែគេវែកឲ្យពីជីវំដោះ

ទៅចម្ងាយ៧-៨គីឡូ គេវែកពីហ្នឹងទៅដល់វែកពីហ្នឹងទៅបាយ គេយកឲ្យតាម៉ាពេលទេ អ្នកយកឲ្យនិយាយឲ្យចំទៅឲ្យ២ស្លុគ្រៗ ស៊ីយកទៅឲ្យយប់ហ្នឹងហៃទុកម៉ាស្លុគ្រទៀត ព្រឹក ទម្រាំតែគេដោះស្រាយយកបាយមកឲ្យ គ្រាប់អីចឹងដែរ គ្រាប់មានតែម៉ាចង្កេះៗ ហើយ មានតែ១ស្លុគ្រទៀត ប៉ុន្តែគេឲ្យដោះស្រាយឲ្យបានម៉ាថ្ងៃហើយ ឲ្យបានម៉ាយប់ដឹងគេ គម្រោងច្បាប់ទ័ពកាលហ្នឹងណា ព្រោះគេបញ្ជូនអីបានតែយប់ហើយដើរទៀត អត់មាន ឡានទេ អត់ស្គាល់ជាតិឡានទេ កាលហ្នឹងអត់ស្គាល់ជាតិឡានទេ ទៃអង្ករគឺម៉ាទៃៗកាល ចូលសមរភូមិហ្នឹងក៏ទៃអង្ករទុកកន្លែងវរសេនាធំកន្លែងគេអ្នកដាំបាយនោះទេ ហើយលី ដែរប្រហោងចូលអីចឹងទៅអត់មានទៅដាំកន្លែងសមរភូមិបានទេមានអ្នកដាំក្រោយយកទៅ ឲ្យហើយ អ្នកដាំដូចខ្ញុំប្រាប់ប្អូនឯងអីចឹងម៉ោង៧-៨យប់បានគេយកទៅឲ្យទាន់ៗ ស៊ីយប់ ហ្នឹងហៃទុកម៉ាស្លុគ្រមួយទៀតព្រឹក ហើយជួនកាលអាផែហ្នឹងយកទៅឲ្យអត់បានទេ ដាប់ ដៃៗកំពុងវ៉ៃគ្នា ដាច់ខ្សែត្រៀមជួនកាលអាយួនហោះទម្លាក់ត្រូវគ្រាប់អាអ្នកយកទៅឲ្យ គ្រាប់ផ្លោងទម្លាក់ អត់បាយផែហ្នឹងម៉ាផែជួនកាលអត់ដល់ស្អែកហ្នឹងទៀតក៏មានដែរ ។ ប៉ុនកាលហ្នឹងវាចេះតែរស់ទៅ អត់មានស្អីទេ ស៊ីនិយាយឲ្យចំទៅស៊ីរើសត្នោតទុំ បើមាន ត្នោតទុំនៅជិតអាហ្នឹងរួចម៉ាផែ២ផែអាហ្នឹងបន្ត ហើយអាហ្នឹងនៅមានកម្លាំងដូចគ្នាអីចឹង ។

ម៉េងទ្រី: ពូកាលសង្គ្រាមខ្មែរក្រហមវ៉ៃឈ្នះ លន់ ណុល ហ្អូពូគិតថាពីខាងណាដែលវាវ៉ៃទៅខ្លាំងជាងគេហើយដែលអាចធ្វើឲ្យខ្មែរក្រហមឈ្នះបាន?

ធី: ខ្ញុំតាមមើលខ្ញុំ...ដែលអ្នកធ្វើគេស្តអ្នកវ៉ៃផ្ទាល់ដៃដូចជាខុសត្រូវតាម៉ាម៉ោង២ម៉ោង ដែល ពួកខ្ញុំខាងភូមិភាគពិសេសហ្នឹងវ៉ៃចូលតាមហ្នឹងនេះ តាមផ្លូវហ្នឹងនេះកាត់ទៅកន្លែងរោងចក្រកែវ ឡើងតាខ្មៅ អត់មានវ៉ៃឡើងតាខ្មៅទៀតទេ ព្រោះកងពល១២វ៉ៃខាងផ្លូវជាតិលេខ១ឡើងម៉ោហៃគឺទុកប្រឡោះហ្នឹងឲ្យពួកកងពល១២ ម្តុំព្រែកជ្រៃរោងចក្រកែវ កន្លែងប៉ុស្តិ៍វិទ្យុមិនមានរោងចក្រកែវឡើងពីហ្នឹងម៉ោវិញ ហើយពួកតាម៉ុក ប៉ែកនិរតីហ្នឹង បានចូលទៅដល់ត្រឹមពោធិចិនតុងទេ ហើយពួកខ្ញុំចូលដល់មុនគេ ប៉ុនគ្រាន់តែចូលទៅដល់ ហ្នឹងឃើញពួកបូព៌ហែលទឹកសំពោងពេញមុខវាំង គេហែល...កាលហ្នឹងដូចជាត្រូវគ្នាដែរ ព្រោះកាលហ្នឹងចូលអំពេញចូលទាំងអស់គ្នា ដល់ពេលគ្រាន់តែពួកខ្ញុំចូលដល់ស្ទឹងមានជ័យ អីណោះ ។ តាមពិតបើយើងមិនដឹងវានៅញោចខាងណោះញោតខាងណោះណា ដូច...

គ្រាន់តែពួកខ្ញុំវើចូលដល់ស្ពាតអូឡាំពិកស្រាប់គេឲ្យការណ៍ថា ពួកបូពាំហែលទឹកដល់វាំងដែរហៃពួកខ្ញុំហ្នឹងជិះរថក្រោះចូលដែរ កាលហ្នឹងចាប់បានរថក្រោះនៅបន្ទាយស្ទឹកបន្ទាយអីខាងជើងពេទ្យរុស្សីមានបន្ទាយទាហានមួយ ពួកខ្ញុំជិះលើរថក្រោះហ្នឹងមានទាហានបង្ហាត់ទៀតបង្ហាត់ឲ្យបេះបើក ប៉ុនបើកខុសខ្លះត្រូវខ្លះអីហ្នឹង ហើយចូលតាមហ្នឹងទៅ ពួកមែនតើបាញ់គ្នាឯងទៅ ពួកនោះឃើញពួកខ្ញុំជិះរថក្រោះចេញពីស្ទឹងមានជ័យគល់ស្ពានស្ទឹងមានជ័យបត់ពីពេទ្យរុស្សីទៅ ហើយពួកនិរតីម៉ាឈូរណាមានម៉ាឈូរនៅៗពោធិចិនតុង ប៉ុនម៉ាឈូរលុកម៉ោដល់ៗគេនៅទៅដល់ព្រៃសរនេះ គេម៉ោដាក់ពួកខ្ញុំចូលប្រហែលមុនម៉ា ម៉ោង៧ ម៉ោងដាក់ពីកែងដូចថាផ្សារដើមគរម៉ាជ្រុងផ្សារដើមគរពីនោះម៉ោ បាញ់បេបាញ់អីដូចផ្សងម៉ោទម្រាំតែដឹងគ្នាហ្នឹង....ៗ

ម៉េងទ្រី: ផាប់ខ្លះ?

ធី: អត់ផាប់ទេ ប៉ុនផាប់តែអ្នកស្រុកកាលហ្នឹងអ្នកស្រុក១៧មេសាហ្នឹងអ្នកស្រុកច្រើនណាស់និយាយទៅវាមូលមីពេញហ្នឹងហើយទ័ពតិចហ្នឹងៗ ហើយកាលហ្នឹងខ្ញុំនិយាយសរសើរចុះសរសើរត្រង់ថា ទាហានហ្នឹងក៏គេដាក់ខ្លួនអស់ បើសិនមិនដាក់អាវុធទេ ទ័ពរំដោះចូលតិចៗហ្នឹងមិនចូលច្រើនឯណា ឧបមាចូល១០នាក់ទាហាននេះរាប់រយអ្នកក៏មានដែរ ប៉ុន្តែវាដាក់ខ្លួនលែងតលែងអីទម្លាក់អាវុធគ្រាន់តែស្រែកឲ្យ ខ្ញុំនិយាយនេះនិយាយករចុះបើតាមខ្ញុំនិយាយប្អូនឯងថា ករពីឡើងទៅដល់ប៉ុស្តិ៍វិទ្យុម៉ោខ្ញុំលែងដើរហើយខ្ញុំជិះរ៉ឺម៉កៗហើយអត់ស្គាល់ដីអំពេញផង ប៉ុន្តែប្រាប់អ្នករ៉ឺម៉កបត់ទៅពេទ្យរុស្សីគ្រាន់តែឃើញពេទ្យ ឃើញខាងជើងពេទ្យរុស្សីមានបន្ទាយស្ទឹកមួយ រថក្រោះ៥-៦ហើយឡានទ័ពហ្នឹងរៀបចេញម៉ោជួយៗម្តុំចាក់អង្រែនេះកាលហ្នឹងបើចាក់អង្រែហ្នឹងវើម៉ាប្រកទៀតមិនលន់ ណុលចាក់អង្រែខាងត្បូងក្បាលថ្នល់ហ្នឹងមិនចេញម៉ោហ្នឹង ពួកខ្ញុំហក់ពីលើអាម៉កៗធាក់ជើងទ័ពស្រីក៏មានដែរកាលហ្នឹងមាននារីមានអីលីអាបេ៣-៤ដើមលត់ជន្លុងភ្លង់លើថ្នល់ហ្នងថាឲ្យដាក់អាវុធអីចឹងណា ហើយចុះចេញទៅផ្ទះទៅសម្បែងស្រុកនៅណា ទៅៗទុកគាអាវុធទុកអីហ្នឹងទៅ ស្រែកប្រាប់អីចឹងខ្លះក៏អារថក្រោះឡានគេបញ្ចេះហើយរត់ទៅទះរកប្រពន្ធកូនអីចឹងទៅ ប៉ុនខ្លះក៏មានអាដាច់ខាតអីដែរមិនមែនតឹងអស់ទេ ដូចថា១០០មាន១មាន២អត់ទៅណាទេនៅភ្លឹងដូចព្រះថ្មក៏មានដែរចាំលបបាញ់លបអីបោកគ្រាប់បែក

គ្រាប់អី ។ ខ្ញុំនិយាយទៅណាដីភ្នំពេញហ្នឹងចាប់ផ្ដែដាច់១៧មេសាហ្នឹងម៉ោនិយាយស្ងប់សង្គ្រាមមិនមែនសង្គ្រាមអីទេ គឺបោកគ្រាប់បែកអីចឹងហ្នូងប្រហែលជា៣-៤ខែបានបាត់ព្រុបោកគ្រាប់បែកបើអីចឹងបើមិនបោកជ្រុងនេះបោកជ្រុងនោះផ្លោងចូលទះថ្មម៉ោ ហើយប្អូនឯងមើលចុះអាកន្លែងអាឡូវគេធ្វើថ្មីៗអស់ហើយខ្ញុំវង្វេងដែរ អាផ្សារដើមគរនោះមានជ្រុងទះចេះមួយអាជ្រុងនោះ បាញ់ចេញតាប្រឡោះហ្នឹងប៉ុនព័ទ្ធឡើងលើមិនឃើញមិនដឹងជាទៅខាងណាទេឆ្លងទះ១ទៅទះ១ក៏មិនដឹងណា គ្រាន់ទេបាញ់ចេញទៅប៉ុនគ្មានត្រូវទ័ពទេ ត្រូវតែអ្នកស្រុក ។ ហើយ អ្នកស្រុកយើងចេញពីអំពេញហ្នឹងមិនទាន់ចេញអស់ទៀត ២-៣ខែបានចេញអស់ទៀត ប៉ុនបោកគ្រាប់បែកហ្នឹងប្រហែលជា៤-៥ខែបានអស់ស្ងប់ ។ ទាល់តែគេឆែកទះអីប្រមូលសម្ភារអីកឆែកទះអស់អីចឹងទៅប្រហែលជា៤-៥ខែបានអស់បោកគ្រាប់បែក ។

សុជា: ពូអ៊ុ...កាលពូវៃចូលទីក្រុងភ្នំពេញហ្នឹងកាលហ្នឹងក្រោមការដឹកនាំបស់ពីណា?

ធី: អាហ្នឹងតាមកងពលមួយៗ ។

សុជា: ប្រធានកងពលហ្អី?

ធី: ហ្នឹងហើយអាហ្នឹងខ្ញុំនិយាយកងពលខ្ញុំ យើងគោរពកងវរសេនាធំវរសេនាតូចដែលគេចុះផ្ទាល់ជាមួយថ្មើរជើងយើងហ្នឹងមានអ៊ុ...វរសេនាតូចនិងអនុសេនាធំទេដែលគេចុះផ្ទាល់ៗបើកងពលគេនៅតែក្រោយៗទេ ហើយខ្ញុំចាំអើយកាលហ្នឹង ហ្នឹងហើយមានតែកងពលចូលដល់ប្រហែលជាម៉ោម៉ោកងពលចូលផ្ទាន់ៗដែរមិនមែននៅយូរទេកន្លែងខ្លះកន្លះម៉ោងអីចឹងទៅបានមានអាហ្សីបអាជីយើង អាហ្សីបអាមេរិចកាំងប៉ុនគេយកបានខ្លះពីមុនម៉ោខ្លះក៏ទើបយកបានក្រោយអីចឹងណា ។ យើងឡានអាហ្សីបបើចូលម៉ោ បើមានអាហ្សីបៗសឹទ្ធតាកងពលហើយប្ដុវរសេនាធំហើយ ។

សុជា: ចុះពេលដែលជួបជាមួយទាហាន លន់ ណុល អីហ្នឹងយើងធ្វើយ៉ាងម៉េច?

ធី: តដែរហ្នឹងប៉ុនគ្រាន់តែថា តវ៉ាម៉ាឆាវៗវាមិនតជាប់ណា គឺនិយាយទៅទាហានគ្នា ឈប់បាញ់ចេញមុខត្រឹមបើនិយាយទៅត្រឹមតាខ្មៅ ហើយពីលិចត្រឹមរោងចក្រកែវហ្នឹងឈប់វៃចេញមុខហើយបើថា ទ័ពនៅអីចឹងទៅគឺខាងដីរំដោះចូលវៃម៉ាប្រាវទេនោះក៏រត់អីលើកទង់ជ័យអីចឹងទៅណាគេកំណត់យកទង់ជ័យសនោះលើកដើម្បីអាហ្នឹងគេហៅចុះចូល

ហើយ ។ នៅខាងក្នុងនេះ ព្រោះខ្ញុំឃើញគេខ្វះរត់ម៉ោឱបម៉ោអីចឹងទៅ អាងថា ដីរំដោះមានបូពាំមានអីនៅធ្វើភូមិភាគហ្នឹងដែរខ្វះចេញៗទៅគេថាមានបងប្អូនគេនៅដីរំដោះហ្នឹងដែរណា ។

# ភាគទី២

សុផា: ចុះពូអ៊ី...ពេលដែលពូចូលអំពេញដំបូងពូនៅកន្លែងណាដែរ បោះទីតាំងអីណា?

ធី: កាលហ្នឹងទីតាំងទ័ពអត់កំណត់អស់ហើយម៉ាអាទិត្យយូរបំផុត អស់ហើយ៣ថ្ងៃម៉ាអាទិត្យហ្នឹងខ្ញុំប្រាប់ប្អូនឯងឲ្យចំណា ខ្ញុំមុនដំបូងបែកគ្នាប្រហែលជា៣-៤ថ្ងៃទ័ពបែកគ្នា ដូចថា...វាបែកមិនមែនបែកតិចទេ បែកម៉ាក្រុមទៅណោះម៉ាក្រុមទៅណោះម៉ាក្រុមទៅណា ធ្លាប់តាដេកតាពីសតាពាសតាមផ្ទះថ្មហ្នឹងដែរណាបាញ់តាគ្នាឯងទម្រាំតែឃើញគ្នាឯង ប៉ុនគេកំណត់បេះទ័ពរំដោះច្រើនពាក់ខោអាវខ្មៅ ទ័ពបូពាំច្រើនតែពណ៌ខៀវ ប៉ុនគេកំណត់ទៀតមួរដៃម៉ាចំហៀងណា ឬបៃដន្យមានស្លឹកឈើហើយទាហានហ្នឹងគឺអត់មានទេ ហើយអីចឹងបើសិនជាជ្រុលដៃជ្រុលជើងបាញ់ក៏ដោយបើឃើញគ្នាមួរដៃហើយលើកកាំភ្លើងទៅលើឬក៏មែកឈើអីក៏ត្រូវតែឈប់បាញ់...ប៉ុនម៉ាប្រាវមុនដំបូងពួកទាហានហ្នឹងខ្វះក៏ឈ្លើយដែរខ្វះយកឡានទាហានបានយកឡានទាហានជិះ ឃើញរថក្រោះក៏យករថក្រោះជិះ ហើយអាគេម៉ោម៉ាប្រកៗនោះដល់តាមេៗទៅទាន់ផ្សះផ្សាគ្នាបានឈប់មានរកាំរកូស ហើយខ្ញុំវង្វេង២យប់ក៏មានដែរនៅម្តុំស្ទឹងមានជ័យអាកន្លែងគេហៅអាបន្ទាយ...កន្លែងខាងជើងស្តាត...ពេទ្យរុស្សី ហ្នឹងហើយខ្ញុំច្រើនដេកនៅហ្នឹង ។

សុផា: ពេលពូចូលដល់អំពេញភ្លាមពូមានដឹងថា ហេតុអីបានមានការជម្លៀសប្រជាជនកើតឡើង?

ធី: ខ្ញុំក៏វាមិនដឹងដែរប៉ុនអាហ្នឹងវា...មេៗគេត្រូវតែឲ្យជម្លៀសអីចឹងហ្នុងមានផែនការ...ខ្ញុំនិយាយក្អួយតាវ៉ែន បង្កើតណា មេឃុំខ្លួនឯងបង្កើតណា...ខ្ញុំក្អួយ តាវ៉ែន អាខ្វះគេថា កូនតាវ៉ែន អាខ្វះកូនតាជ័យក៏មានដែរ ប៉ុនអត់ស្តាប់ទេមេៗខាងហ្នឹងគេអត់ឲ្យស្តាប់ទេ កូនៗពីណាក្អួយពីណា ដាច់ខាតដេញចេញ ចុះខ្វះអាងៗមេកើយនៅណោះ ខ្វះឪឯងបង្កើត

មានឯងបង្កើតខ្លះអត់ចេញទេ   ប៉ុន្តែមុខសញ្ញាណាចូលដល់នោះជម្លៀសចេញមេហ្នឹង បញ្ជាក់អត់ឲ្យយល់យោគ ។

ម៉េងទ្រី: ការទទួលបាននូវជ័យជម្នះទទួលបាននៅពេលណា?

ធី: អ៊ឺ... ។

ម៉េងទ្រី: មុននឹងវៃទៀតមុននឹងវៃចូលដល់អំពេញឬក៏ពេលចូលដល់អំពេញហើយវៃភ្លាម?

ធី: អត់ទេ  ផែនការមុនទៅហ្មង ។  ដឹងហើយព្រោះយើងអ្នកចូលសមរភូមិរំកិលរហូតហើយ ចាំមើលវៃត្រឹមសំបូរនេះទ័ពហ្នឹងដាច់ពីគ្នា   ដល់គាត្រឹមដល់គាខ្មៅទ័ពសល់ហើយចាប់ទ័ព ហ្នឹងសល់  ចុះយើងនៅ...គឺគេពុះអីចេះ  ត្រឹមទន្លេមេគង្គទៅខាងកើតខាងតំបន់២៤ភូមិ ភាគបូព៌ាត្រឹមទន្លេមេគង្គម៉ោខាងលិចម៉ោយើងហ្នឹងណា   គេឲ្យភូមិភាគពិសេស២កងពល ហើយត្រឹមបឹងហ្នឹងទៅលិចគេឲ្យខាងនិរតីអីចឹងទ័ពតិចតាពីនេះដូចថាទ័ពវៃចូលនិយាយចំ ម៉ាខែទៀតចូលសល់ៗទ័ពដូរគ្នាវិលអាខ្លះដើរលេងក្រោយវាសល់លេងៗចូលសមរភូមិ ព្រោះទ័ពវាសល់ណា  ទ័ពសល់ហើយត្រឹមវៃចូលដល់គាខ្មៅទ័ពសល់ហើយ ។

សុជា: កាលពូទទួលបញ្ជាឲ្យជម្លៀសប្រជាជនចេញទទួលបានពីខាងណាម៉ោ?

ធី: អ៊ឺ...គឺគេមានផែនការពីណាមិនដឹងទេ   ប៉ុនមេកើយយើងដែលនៅផ្ទាល់យើងមិនអាចនៅ ជិតកងពលបានទេ  មានតែប្រធានវរ  វរសេនាតូច  អនុសេនាធំអីទទួលផែនការគត្នា គេហ្នឹងត្រឹមយើងគ្រប់គ្រងត្រឹមប្រធានក្រុមឬអនុសេនាតូចទេ   ដែលយើងនៅថ្មើរជើង ណេះយើងក្តាប់គាប៉ិនហ្នឹងទេ ។

សុជា: ពូព្រនៅពេលណា?

ធី: ព្រកាលចូលអំពេញហ្នឹង   ព្រកាល១៧មេសាហ្នឹងម៉ាអាទិត្យមុនហ្នឹង ។   អត់ទេពួកខ្ញុំគេទៅ យកមុនប្រហែលម៉ាអាទិត្យគេណែនាំ ។

សុជា: គេៗមានហេតុផលអីបានគេប្រាប់ថាឲ្យជម្លៀស...ប្រជាជន?

ធី: យើងអត់ដឹងទេ  អត់ដឹងហេតុផលអីទេ  គ្រាន់តែដឹងថា  ចូលដល់ត្រឹមម៉ានជម្លៀសប្រជា ជនត្រឹមហ្នឹង ។

សុជា: ចុះពូខ្លួនឯងមានឆ្ងល់ថា  ហេតុផលអីត្រូវកៀរប្រជាជនចេញពីទីក្រុងភ្នំពេញ?

ធី: អត់ដឹង ។

ម៉េងទ្រី: ចុះពេលវ៉ៃទៅដល់តាខ្មៅហ្នឹងមានជម្លៀសប្រជាជនចេញទេ?

ធី: ចេញៗប៉ុនត្រឹមតាខ្មៅហ្នឹងខ្លះក៏ចេញខ្លះក៏ចេះតែរត់ៗមូលទៅលើ អាខ្លះក៏ចុះម៉ោក្រោម បើផ្លូវ...អីហ្នឹងទ័ពក៏ជូនដំណើរម៉ោដែរ ។ កាលហ្នឹងដូចថា ទ័ពរំដោះក៏ស្រួលដែរមិនជាយោរយៅអីទេ ប៉ុន្តែកុំតៗអត់បានទេ តបាញ់ចោលក៏មាន ប៉ុនដូចថាចេះតែម៉ោវាឲ្យចេញម៉ោចេះតែម៉ោ ។

សុជា: ពូដែលឃើញ ការបាញ់មនុស្សចោលអីតាមផ្លូវទេ ឧបមាថាអ្នកជម្លៀសម៉ោមានដែលឃើញគេបាញ់អីទេ?

ធី: អ៊ុ...ខ្ញុំអ្នកៗលីដែកប្រហោងអីចឹងបាញ់ហើយប៉ុនគ្រាន់ថា អាតដៃគឺបាញ់ហើយគ្រាន់ថាឲ្យបាញ់ផ្ទាល់ៗអីចឹងគឺអត់ដែលមានទេ ប៉ុន្តែកន្លែងណា ដូចទាហានកន្លែងខ្លះវានៅក្រាញនិយាយឲ្យចំទៅណា ត្រឹមអាៗបត់តាយ៉ូវវាម៉ាកងវាណា ខ្លះក្រាញណាៗផ្ទុះអាវុធម៉ាប្រាវហ្នឹងធម្មតាទេម៉ាប្រាវហ្នឹងដែលពួកខ្ញុំដែលពួករំដោះនេះវាភ្លឹតភ្លឺនទឹងជ័យជម្នះ គឺថាអត់បានទប់ខ្លួនផាប់ម៉ាពេលហ្នឹងក៏...និយាយឲ្យចំផាប់ច្រើនដែរតើ ត្រូវគ្រាប់ច្រើនដែរ និយាយឲ្យចំអាងខាងណោះចាញ់ហើយចូលទៅអីចឹងដើរចំហអីចឹងទៅប៉ុនដួនកាលអាបន្ទាយវាតអាទេះបន្ទាយវា៤-៥រយបន្ទាយមួយ ២០០-៣០០ម៉ែត្របន្ទាយមួយ កាលហ្នឹងតអាទេះ តកាលហ្នឹងមមាញឹកណាស់ ដែលតទៅដល់អំពេញហ្នឹង ទាល់តែត្រឹមនេះបានអស់បន្ទាយ ប៉ុនខ្ញុំវាមិនចាំខាងចាក់អន្រ្តែខ្ញុំចាំដែលម៉ោពីស្វាយជ្រៃៗខាងលិចវេងចក្រកែវណា ម៉ោដល់ខាងកើតប៉ុស្តិ៍វិទ្យុស៊ឹងមានជ័យហ្នឹងបានអស់បន្ទាយម៉ោបន្ទាយភូមិហ្នឹងនៅបន្ទាយស្ទឹកអ៊ុ...ខាងជើងៗពេទ្យរុស្សីណា បន្ទាយធំក្រៅពីហ្នឹងអស់បន្ទាយហើយ ។ ហើយតៗតាមដំបូលទះថ្មបាញ់ចេញពីដំបូលទះថ្មម៉ោទេ ។

សុជា: ចុះពូៗទៅនៅ៥០២ឆ្នាំណា?

ធី: ៥០២ ១៧មេសា បែកអំពេញហើយ ។ ព្រោះពីសង្គ្រាមខ្ញុំនៅកងពល៦០៥ កងពល ១១និយាយឲ្យចំ ប៉ុនភាគច្រើន៦០៥ ប៉ុនលេខគេហៅវាលំដៃគេហៅកងពល១១ៗ ហ្នឹងរំលាយកងពលត្រឹម១៧មេសាហើយ ។

សុជា: ចុះពេលរំលាយហើយគេកាត់ទៅហ្នឹង?

ធី៖ កាត់ទៅខាងដូចខ្ញុំបញ្ជាក់ថា កងពល១២នេះទៅខាងទ័ពជើងការ ហើយកងពល១១ចូល ៥០២ ប៉ុន្តែកងពលម៉ាវរសេនាធំខ្ញុំហ្នឹងណា ចូលទៅម៉ាក្រុមដូចគេដាក់ដូចទំនើបរបស់គេដែរខ្លះគេក៏ទៅឆ័ត្រយោងអីទៅខ្លះក៏ទៅខាងការពារដែនអាកាសអីចឹងទៅខ្លះក៏ទៅខាងយន្តហោះខ្លះៗក៏ទៅចិនពួកហ្នឹងទៅចិនច្រើនណាស់ មិនដឹងទៅរៀនខាងអីទេ ប៉ុន្តែគេឲ្យទៅចិនប្រទេសចិនណា ។

សុជា៖ ឆ្នាំណាដែលគេ ខែណាដែរដែលគេចាត់ចែងឲ្យ...?

ធី៖ អ៊ឺ...ខ្ញុំវាមិនចាំច្បាស់ខែណាៗទេ ចាំជាងគេគឺថា វានៅរៀបរយប្រហែលជា៤-៥ខែក្រោយហ្នឹងគេចាប់អ៊ី...គេថាស្ងប់អស់អ្នកក្រុងភ្នំពេញ អស់ពី...ប្រហែល៦-៧ខែហ្នឹងអស់ហើយ ។

សុជា៖ ចុះពីណាគេប្រធានកងពល៥០២ហ្នឹង?

ធី៖ តាម៉េត...តាលវ៉ៃ ជាមួយ តាលវ៉ៃ ហ្នឹងនិយាយអាឌីនៗ តាលវ៉ៃហ្នឹងមាឌធំ ហើយនិងផល ។ ផល ហ្នឹងក៏អនុកងពល១២ដែរប៉ុន្តែដល់គេស៊ុកចូលគ្នាទៅបង ផល ហ្នឹងទៅជាអនុកងពល៥០២ ហើយ អាម៉ៅ ប្រធានវរសេនាធំកងពល១១ក៏ឡើងអនុកងពលដែរ ពេលហ្នឹងប្រធានវរសេនាធំដែលខ្ញុំនៅហ្នឹងកងពល១១ណា ក៏ឡើងកងពលពេលហ្នឹងដែរប្រធានវរសេនាធំ ឈ្មោះ ម៉ៅ អីចឹងប៉ុន្តែអត់ទាន់ឡើងបានម៉ានខែ មិនបានម៉ានឆ្នាំទេតាមមើលក៏គេចោទ តាលវ៉ៃ អី ចោទបងផលហ្នឹងក្បត់ចោទដែល ម៉ៅដែល...ពួកហ្នឹងច្រើននៅតំបន់២៥កាលហ្នឹងអ៊ី...ខាងហ្នឹងក្បត់ទាំងអស់ដល់ក្បត់អីចឹងទៅអីគេចោទថាក្បត់ចាប់យកមិនដឹងចាប់ទៅណាទេវាបាត់វាចោទថាក្បត់ៗ ។

សុជា៖ ពូនិយាយដំបូងថាមានប្រលងបើយន្តហោះដែរហ្អី?

ធី៖ ប្រលងប៉ុន្តែពួកខ្ញុំប្រលងហ្នឹងមានម៉ាចំនួនជាប់ទៅ ដូចថា ១០ជាប់បាន៣បាន២អីចឹងណាហើយអ្នកណាអត់ជាប់អីចឹងគេត្រូវចម្រាញ់ទៅខាងឆ័ត្រយោងទៀត ខ្ញុំចូលឆ័ត្រយោងទៀតប្រហែលជា៣ខែទៅ៤ខែ ។

សុជា៖ អីចឹងអ្នកដែលប្រលងជាប់ខាងបើកយន្តហោះគេឲ្យទៅរៀននៅណា?

ធី៖ នៅចិន ។

សុជា៖ នៅចិនហ្នឹងហ្អី ។ ពូមានចាំអ្នកដែលទៅជាប់ជាមួយពូហ្នឹងអ្នកដែលជាប់យន្តហោះ...?

ធី៖ ទេ ខ្ញុំចាំច្រើនណាស់ ប៉ុនអាឡូវបាត់ខ្លួនម៉ោដល់អាឡូវហ្នឹងណោះ ជាប់ផ្ទុះខ្ញុំរំលងផ្ទុះខ្ញុំ អាពាង១នេះ ហើយមួយអាធំៗប៉ុនទៅនៅជំរំនៅប៉ៃលិន នៅម៉ាឡៃអាឡូវហ្នឹង ប៉ុនវាម៉ោលេងផ្ទុះវាម្តងវាមានប្រពន្ធកូនវានោកាលហ្នឹងដីខ្មែរក្រហមអីចឹងនេះ នៅទើសសព្វថ្ងៃ ហើយ អាពាង នេះបាត់ខ្លួនឈឹងបែបនាប់ហើយតាមមើល អាពាងនេះរំលងផ្ទុះខ្ញុំ១នេះ ។

សុជា៖ គាត់ធ្លាប់ទៅរៀននៅចិនប្រហែលម៉ានឆ្នាំបានគេឲ្យម៉ោវិញពូចាំទេ?

ធី៖ ខ្ញុំវាមិនច្បាស់ដែរពួកហ្នឹងអត់ច្បាស់ទេ ខ្លះថា ទាក់ទងអីចឹងទៅម៉ាជំនាញហើយ ខ្លះក៏វិទ្យុទាក់ទង ខ្លះក៏រ៉ាដាៗធំៗណា ទៅខ្លះក៏ជំនាញបើកបរ ពួកអាកងពល៥០២វាគ្រប់គ្រងទាំងអស់ម៉ារ៉ាដាអារ៉ាដាធំៗ៤០០គីឡូទូទាំងប្រទេសនោះក៏មានទៅអារ៉ាដាហ្នឹង អ៊ឹ...ខ្លះក៏អាវិទ្យុទាក់ទង ខ្លះក៏ទៅអាជំនាញទៅខាងបើកបរ ខ្លះក៏ឆ័ត្រយោង ខ្លះក៏ក្រសួងការពារដែនអាកាស ៧-៨មុខសញ្ញានោះដែលវាៗទៅនោះ ។

ម៉េងទ្រី៖ ចុះពេលដែលពូទៅហាត់ឆ័ត្រយោងហ្នឹងគេធ្វើយ៉ាងម៉េចចំពោះអ្នកហាត់នេះ?

ធី៖ បេះខ្ញុំនិយាយឲ្យអស់ចុះខ្ញុំធ្លាប់ចូលឆ័ត្រយោង សម័យអាឡូវវាខុសគ្នា ឆ័ត្រយោងសម័យនោះគឺគេគ្រាន់តែឲ្យឡើងលើយន្តហោះទេ ចិនគេអ្នកលោតខ្លួនគេតឹងអស់ណាគេគ្រាន់តែឲ្យមើលគេ ហើយគេមានទ្រឹស្តីមួយចំនួនហៃនិងបត់ឆ័ត្រៗហ្នឹងអត់មានអ្នកណាបត់ឲ្យទេកាលនៅជំនាន់អាពត កាលហ្នឹងឆ័ត្រខ្លួនឯងរៀនបត់ខ្លួនឯងអាហ្នឹងអាពតណា ហើយមុននឹងលោតឆ័ត្រណា គេអត់ឲ្យយើងទៅលោតឆ័ត្រហ្នឹងហ្មងទេ៣-៤ខែមុនដំបូងឲ្យយោលទោង អាវត្តៗចំបក់ដែលជាប់របងពោធិចិនតុងរាល់ថ្ងៃនេះ ប៉ុនអាខាងណោះអាខាងជើងវត្តចំបក់ហ្នឹងណាគឺកន្លែងហ្នឹងមានជណ្តើរឡើងលើមានកៅអីគេអង្គុយអាហ្នឹងដូចថា យើងខ្យល់គ អីក៏អត់ធ្លាក់ងាប់ដែរមានខ្សែក្រវ៉ាត់គេទាក់ព្រលែងម៉ោហ្នឹងចុងត្នោតជាគ្នា ព្រលឹងហ្នឹងប្រហែលជារត់ចោល...ហើយអ្នកហាត់កាលហ្នឹងណា ស្គមតឹងអស់អត់មានណាធាត់មួយទេ អ្នកហាត់ហ្នឹងហើយក៏គេលេងសាច់រឿងកុនដែលសូវៀតវ៉ៃជាមួយអង់គ្លេសវ៉ៃជាមួយចិនឲ្យមើលឃើញអីចឹងពីសង្គ្រាមពីអីលោតឆ័ត្រយោងអីចឹងណា អាខ្លះក៏ជាប់អាខ្លះក៏អត់ជាប់ ។

សុជា៖ ហើយហេតុអីបានពូអត់ជាប់?

ធី: ឈឺៗស្គមដេកពេទ្យសឹងរាល់ថ្ងៃ អ៊ឺ...អត់ដាប់ទេ ។

សុជា: ចុះដល់ពេលការជ្រើសរើសហ្នឹងចិនគេអ្នកម៉ោជ្រើសរើស?

ធី: ថាម៉េច?

សុជា: ចិនគេអ្នកម៉ោជ្រើសរើសផ្ទាល់ហ្អីបើយន្តហោះ?

ធី: អត់ៗចិនទេ អាយើងទៅពីអង្គភាពហ្នឹងមេៗទេ ប៉ុនតែអាម៉ោធ្វើគេស្តមួយៗចិន ។

សុជា: ចិន?

ធី: ហ្នឹងហើយ ។ សូម្បីតែខ្ញុំទៅហាត់កាំភ្លើងធំការពារដែនអាកាសអីចឹងដែរអាកាំភ្លើងធំខ្ញុំនិយាយមិនណាចិនគេម៉ោបង្ហាត់ផ្ទាល់ចិនហ្នឹងខ្ញុំមិនស្គាល់ច្បាស់ទេខ្ញុំដើររាប់ខែរាប់ឆ្នាំទៀតចិន ។

សុជា: ស្គាល់ឈ្មោះទេពូ?

ធី: អត់ស្គាល់ឈ្មោះទេ មានបកប្រែ មានចិនកំពតម៉ោបកប្រែ ។ ប្រធានក្រុមរៀនឆាប់ចេះដោយសារគេធ្វើផ្ទាល់ណា ចិនមានក្រុមមួយម៉ោអ្នកទី១គេធ្វើអាវិលកង់សម្រាប់រាវរកគោលដៅហ្នឹងគេហៅអ្នកទី១ហ្នឹងគឺ...ចិនមានអ្នកទី១ម៉ោអ្នកទី២គឺកំណត់ខ្ពស់ទាបអាមុំយើងកំណត់ខ្ពស់ទាបហ្នឹងមានអ្នកទី២ម៉ោ អ្នកទី៣ដែលអ្នកផ្តល់គ្រាប់នៅលើក្បាលម៉ាស៊ីនលវ៉ៃខ្សែការពារហ្នឹងក៏មានអ្នកក្នុង៧ហ្នឹងណា ក្នុងកាន់កាប់អ្នក៧នាក់ហ្នឹងក៏មានចិនម៉ោ៧នាក់ដែរ ហើយអាម៉ាស៊ីនបញ្ជា៥នាក់នោះមានគឺចិនម៉ោទាំង៥នាក់ហ្នឹងរ៉ាដាសម្រាប់អូសកាំភ្លើងវាស់កាំភ្លើងវាស់មើលចម្ងាយព្រោះរ៉ាដាកាំភ្លើងចាប់បាន៧០គីឡូ ហើយម៉ាស៊ីនបញ្ជាដែលអូសកាំភ្លើងនោះចាប់បាន៤០គីឡូ ៤-៥នាក់ហ្នឹងចិនម៉ោទាំង៤-៥នាក់កំភ្លេប៉ុនតែមូលហេតុនោះគេឲ្យរៀនម្តងម្នាក់ៗចល័តតឹងអស់ហ្នឹងដល់ស្ទាត់ម៉ាក្រុមហ្នឹងស្ទាត់ណាគឺម៉ាស្ទាត់...ចិនជាគ្រូ...អាខ្មែរៗហ្នឹងអ្នកចេះហ្នឹងបង្ហាត់ខ្មែរគ្នាឯងទៀតយកកាំភ្លើងវាមាន៣ក្រុមប៉ុន្តែចិនបង្ហាត់តាម៉ាក្រុមទេ ដល់ម៉ាក្រុមចេះអីចឹងទៅគឺ...បង្ហាត់ទី២ទី៣ទៀតទៅ អ្នកចេះបង្ហាត់អ្នកចេះអីចឹងទៅ វគ្គទី១អីចឹងទៅ ។

សុជា: ចុះពូវគ្គទី១ឬអី២?

ធី: វគ្គទី២ ។ ទី១កងវរសេនាតូច១២៨ៗខ្ញុំ៣១វគ្គទី២ហៃ៣៦មាន៣វរសេនាតូចកាលហ្នឹងនោះ ។

ម៉េងទ្រី៖ ពូអ៊ុី...កាលពូចេញពីកងកាំភ្លើងធំហ្នឹងទៀត ថាពូត្រូវបានគេចាត់ទុកថាជាអ្នកទោស?

ធី៖ ហ្នឹងហើយ បានចាំមើលខ្ញុំដល់និយាយអីចឹងគេថាខ្ញុំអ្នកទោសអីចឹងគេយកកាំភ្លើងហ្នឹងបញ្ចូលឃ្លាំងនៅវត្តចំបក់ហ្នឹងជាឃ្លាំងកាំភ្លើងធំហ្នឹងអីចឹងគេឲ្យទៅជីកខ្សែគ្រាប់អីនៅព្រៃសរហ្នឹងណាក្នុងរយៈពេល១ខែ២ខែហ្នឹងគេចាប់ៗហើយ ។ នៅក្នុងកងហ្នឹងគ្រាន់ថាកាំភ្លើងហ្នឹងគេលែងឲ្យយើងរៀនបន្លាត់ អ្នករៀនចេះហើយសូម្បីតែកាំភ្លើងក៏ទៅហាត់រាល់ថ្ងៃដែរបើកកេះបើកម៉ាស៊ីនភ្លើងបញ្ឆេះរាល់ថ្ងៃដែរប៉ុនតែដល់ពេលគេជិតចាប់យើងហ្នឹងគេឈប់ឲ្យយើង...ដាក់ខ្ញាញ់គោដាក់អីប៉ុនគ្រាន់ថា យប់គេម៉ោឲ្យយាមកាំភ្លើងហ្នឹងដដែលថ្ងៃគេឲ្យយើងទៅជីកព្រែក ឈប់ឲ្យហាត់កាំភ្លើងហើយអ្នកដែលទ័ពមានកាំភ្លើងធំយើងក៏មានអាការអាវុធដែលណាម៉ាដើមៗម្នាក់ទៀត អីចឹងយើងក៏មានកាំភ្លើងអាការប្រចាំខ្លួនម៉ាដើមៗម្នាក់គេដកអស់ហើយ អីចឹងដល់យើងទៅជីកប្រឡាយជីកអីហ្នឹងយើងស្មានប្រហែលជា៣-៤ខែក្រោយម៉ោអាពេលដែលខែច្រូតហើយណា ប៉ុនខ្ញុំមិនចាំទេមិនដឹងខែណាទេ ។

សុជា៖ ឆ្នាំណាអ៊ំ?

ធី៖ ឆ្នាំ៧៧ បើមិនខែ៣ទេ ខែ៤ ។ វាចាប់ៗខ្ញុំហ្នឹងណា ប៉ុនចាប់ខ្ញុំហ្នឹងបានជាប់នឹងគេនឹងឯងហ្នឹងប្រហែលជា៤-៥ខែ ។

សុជា៖ ចុះពូៗមានដឹងមូលហេតុទេ ហេតុអីបានគេចាប់ពូហ្នឹង?

ធី៖ ដូចខ្ញុំបញ្ជាក់អីចឹងអត់ដឹងមូលហេតុទេ គ្រាន់តែគេចោទថាក្បត់ ប៉ុនបើយើងមិនដឹងខ្លួនឯងក្បត់ពីកាលដែរ ។

សុជា៖ ចុះពូមានបានមើលអ្នកដែលធ្លាប់គ្រប់គ្រងពូពីមុនៗម៉ោគេមានចាប់ទេ?

ធី៖ អត់ៗគេចាប់អស់ហើយ ។

សុជា៖ គេចាប់អស់ហើយ?

ធី៖ ប៉ុនដូចខ្ញុំនិយាយអីចឹងណាទ័ពហ្នឹងខាងភាគនិរតី ព្រោះពួកខ្ញុំហ្នឹងខាងភូមិភាគពិសេសខាងតំបន់២៥នេះ គឺទៅចូលខាងភូមិភាគនិរតីអាកងពល៥០២បើនិយាយទៅវាចំណុះអគ្គសេនាធិការដែរប៉ុនចេញពីប្រភពពីនិរតីគឺងអស់ ពួកហ្នឹងសឹទ្ធចេញពីប្រភពនិរតីគឺងអស់

គ្រាន់តែពួកកងពល១១នេះគេរំសាយទៅៗបញ្ចូលនៅ៥០២ណា ឲ្យខ្សែតំបន់២៥ចាប់តាតឹងអស់មេៗចាប់អស់អាលីញគ្មានសល់មួយទេ ។

សុជាៈ ចុះកាលហ្នឹង វ៉ន វើត ដែលប្រធានភូមិភាគពិសេសហ្នឹងគេចាប់មុនទៀតហ្អី?

ធីៈ អូហ៏! គេចាប់មុនទៀត ។

សុជាៈ ពូមានដឹងទេ ដែលគេចាប់ វ៉ន វើត ចាប់អីហ្នឹង?

ធីៈ អត់ដឹងទេ ។ គេថាក្បត់ហ្នុង ។

សុជាៈ តែដឹងថាគេចោទថាក្បត់ហើយ?

ធីៈ បាទ! គេចោទថាក្បត់ហើយ ។ ចាំខ្ញុំប្រាប់ប្អូនឯងសាយស្តាប់ ដល់គេចាប់លហួតអង្គភាពខ្ញុំនៅណាវាអស់ៗអាលីញអស់ៗ យើងនិយាយទៅនៅត្រឹមវរសេនាតូចចុះម៉ោទេ ត្រឹមប្រធាន...ឡើងទៅគេចាប់អស់ហើយខ្លះក៏រត់ដូចខ្ញុំនិយាយថាអា២នាក់ដែលគេចងហ្នឹង **ប្រធានគ** ហើយប៉ុនរត់ទៅបាត់ហើយនៅតែប្រធាន...ចុះម៉ោដល់តាអីចឹងវាដូចដាច់ដៃដាច់ជើងអស់អីចឹង អាប្រធានខហ្នឹងដាក់ខ្លួនសាមញ្ញជា...សក្តិប៉ុនគ្នាអប់រំអាណានិយាយដាក់គ្នាយ៉ាងម៉េចៗក៏គេឈប់និយាយទៅៗ ហើយកន្លែងហ្នឹងហើយដែលគេចាប់ៗណាប៉ុនមិនមែនគេចាប់ភ្លូង់ចាប់ភ្លាមៗទេច្រើនហៅទៅប្រជុំពិភាក្សារឿង...គេហៅទៅប្រជុំ ។

ម៉េងទ្រីៈ ចុះពេលដែលគេចាប់ពូដំបូងហ្នឹងគេធ្វើម៉េចខ្លះទៅ ដូចថាគេហៅយើងទៅហ្នឹង គេទម្រាំតែចាប់យើងចាប់អី?

ធីៈ អាហ្នឹងគេប្រជុំម៉ោង៨កន្លះទៅ៩គេហៅទៅប្រជុំទ័ពទាំងអស់ទៅដឹកប្រឡាយដឹកអីហ្នឹងប្រជុំណា ប្រជុំអីចឹងទៅគេណែនាំ ។ នេះមិនមែនម៉ោចាប់ម៉ោអីទេ គេនិយាយថាក្បាលម៉ាស៊ីនយើងនៅហ្នឹងសក្តិប៉ុណ្ណេះអត់មេអត់កើយដូចថា កូនវា...មាន់ វាអត់មានមេអត់មានអីចឹងណាហើយយើងកុំបារម្ភណ៏ក្បាលអាណាសក់អាហ្នឹងអីចឹងអាណាក្បត់ៗតាវាទៅហើយអាណាអត់ក្បត់យើងប្រឹងតែធ្វើការទៅយើងស្រឡាញ់តែបក្សយើងទៅកុំមានគំនិតបែកឆ្វេងតាមមេតាមកើយ ។ ប៉ុនវាគ្មានតែក្បត់អីទៀតទេគ្នាយើងតូចតាចវាអស់អ្នកក្បត់អស់អីចឹងណា កុំបាច់លើកហើយមេៗនោះវាលើកពីបញ្ហាចេះថា អូនឯងមើលមិត្តឯងមើលយើងនៅជាមួយវាដឹងហើយយើងធ្វើសង្គ្រាមជាមួយវា ដើរតាមវាអត់ដឹងថាវាក្បត់ទេ វាធ្វើបាបប្អូនឯងយ៉ាងម៉េច អាអ្នកដែលម៉ោចាប់យើងហ្នឹងវា

ណែនាំដូចថាឲ្យយើងមានកំហឹងជាងអាអ្នកដែលមេៗយើងដែលវាចាប់ទៅបាត់អីចឹងណា វាណែនាំយើងអើធម្មតាយើងនៅជាមួយមេទ័ព ក៏ខ្វះក្បាលកាំភ្លើងខ្វីស្វាយកាំភ្លើងហ្នឹងក៏មានដែរដូចថាការគ្រប់គ្រងហ្នឹងវាមិនខុសប្លែកពីការចិញ្ចឹមកូនដែរ អាកូនខ្វះក៏វាល្អអីចឹងទៅអាកូនខ្វះមិនត្រឹមត្រូវយើងវ៉ៃយើងដេរ អាមេទ័ពកាលណោះមានអាត្រូវក្បាលកាំភ្លើងខ្វីក៏មាន ត្រូវស្វាយកាំភ្លើងក៏មានប៉ុនមិនមែនទូទៅវាអីចឹងទេ យូរៗទៅមាន១ ហើយម្ដងហើយវាលើករឿងហ្នឹងយកម៉ោនិយាយដើម្បីពញ្ញាក់អាស្មារតីយើងឲ្យមានកំហឹងមានអីទៅយើងអត់ដឹងទេ តាំងពីឆ្នាំៗនេះម៉ោវាលើកឈ្មោះនេះៗម៉ោអីចឹងទៅណាអូនឯងធ្លាប់នៅជាមួយវាអូនឯងដឹងស្រាប់ហើយតើវាធ្វើបាបប្អូនឯងយ៉ាងម៉េចសម្ដីវាល្អណាស់ ចរិតវាល្អណាស់ប៉ុនក្នុងពោះវាៗធ្វើបាបប្អូនឯងត្រឹមនេះៗម៉ោវានិយាយហូរហែរឲ្យយើងហ្នឹងស្ដាប់អីចឹងទៅ ប៉ុន្តែវានិយាយឲ្យយើងស្ដាប់ប្រហែលជា១ម៉ោងអីចឹងជិតមួយម៉ោងអីចឹងណា ហៃអីចឹងកុំឲ្យអាអ្នកមានឈ្មោះទៅសប្បាយចិត្តហួសហេតុអាអ្នកអត់ឈ្មោះទៅកុំតូចចិត្តណា អីចឹងវាចេះនិយាយអីចឹងហើយកាលហ្នឹងវាចាប់ខ្ញុំពាពណា ។ ខ្ញុំវាហៅឈ្មោះឲ្យចេញម៉ោតម្រង់ជួរ ។

សុជាៈ គ្នាពូពាពនាក់?

ធីៈ គ្នាច្រើនណាស់ ប៉ុនគេហៅទៅហ្នឹងតែពាពអ្នកហ្នឹងទេ ។ ហៅទៅពាពនាក់អ្នកណាមានឈ្មោះឲ្យចេញម៉ោតម្រង់ជួរម៉ោ អាណាអត់ឈ្មោះរំសាយទៅធ្វើការធម្មតាវិញទៅណា ហៃអ្នកណាមានឈ្មោះឡើងឡានទៅអំពេញទៅគឺថាកាលហ្នឹងអាផ្លូវទៅព្រៃសរក៏គេហៅថាស្រែដែរកន្ទែងហ្នឹង អំពេញទាល់តែម៉ោដល់ស្ពាតដល់អីបានគេហៅអំពេញកាលហ្នឹងដល់ឡើងឡានម៉ោអីចឹងហ្នឹងអើពួកខ្ញុំហ្នឹងអាខ្វះក៏សប្បាយចិត្តអាខ្វះក៏មិនដឹងខ្លួនឯងហ្នឹងវាមិនដឹងទៅយ៉ាងម៉េចទេណា ។ តែម៉ោបៃជន្សដឹងច្បាស់តែមិនមែនដឹងទូទៅទេ ម៉ាឡានដឹង២-៣នាក់ខ្ញុំក៏មិនដឹង២-៣នាក់ប៉ុនមានអ្នកដឹងទៀត ឲ្យតែឡានហ្នឹងទៅចាប់ហើយប៉ុន្តែវាចាំមើលឡានហ្នឹងទៅគឺវាចាំឈររោងចក្រណា រោងចក្រខាងលិចស៊ីងមានជ័យនៅឈរមុខរោងចក្រហ្នឹងចាំមើល ដល់ចាំមើលឡានហ្នឹងទៅតែ២-៣ម៉ោងឡានហ្នឹងមិនម៉ោវិញៗបានថាអឺ...ពួកហ្អែងនេះប្រឹងដល់អន្តាល់ទៀតហ្អា វានិយាយគ្នាវាប៉ុនយើងព្រួណា ឈរមើលចិញ្ចឹមថ្នល់មើលអ្នកគេចាប់...ហ្អែងប្រឹងដល់អន្តាល់ទៀត បដិវត្តន៍គេទៅ

ហើយប្រវត្តិសាស្ត្រគេទៅហើយហ្អែងប្រឹងខ្វាស់ដល់កាលទៀត ខ្វាស់ដៃបាក់ដៃ ខ្វាស់ជើងបាក់ជើងណា អាហ្នឹងអាអ្នករោងចក្រនិយាយប៉ុនអា ៗ អ្នកចាប់ទៅមិនមែននិយាយអីចឹងទៅប៉ុនអាអ្នករោងចក្រវា...កម្មកររោងចក្រឈរមើលគេដឹង ៗ ថាឡានហ្នឹងគេចាប់ហើយទទួលម៉ោដល់ហួសអាស្ពានស្ទឹងមានជ័យម៉ោកើតមានអាផ្លូវបត់អាផ្លូវហៅអូរបែកក្អមប៉ុនអាបត់ទៅខាងមុខអាសាលាទឹកល្អក់ហ្នឹងប៉ុនតែបត់ទៅបានគេឈប់ឡានត្រឹមហ្នឹងហៃដើរចូលប្រហែលម៉ារយម៉ែត្រដើរចូល អានេះដើរទេ ។ ហើយគេទ័ពទាំងស្រីទាំងប្រុសដើរចូលទៅក្នុងទាំងអស់ ហើយ អាម៉េត ប្រធានកងពលខ្ញុំហ្នឹងបានដល់តាអីចឹងទៅ អាម៉េត នៅអង្គុយពាក់វ៉ែនតាអីចឹងទៅឃើញពួកខ្ញុំដើរចូលហើយ ៗ ដើរចូលជួបបងអីចឹងទៅណាតំណាងអង្គការអីចឹងទៅណាខ្លះក៏និយាយទៅទ័ពដើរតាមមានអាវុធអីដើរតាមយើងទៅ ៗ អីចឹងទៅ អាម៉េត មានអ្នកចេញទទួលមុនគេថាអ៊ឺ...មុខជួរ ៗ ហ្នឹងគិតទៅដល់ងៃ...បានជួបខ្ញុំថាអ៊ឺ...អត់ទាន់បាយមែនហ្នឹងអូហ៍អីចឹងតើបានមុខជួរ ៗ គ្រប់គ្នាហ្នឹងហើយពួកយើងម៉ោ ១ ១ មិនទាន់នាំគ្នាស៊ីអស់ហើយ ៗ គ្នាម៉ោង ១២ ធ្វើការហត់នឿយហើយអីចឹងទៅដេញពួកវាទីណាត់ទីណែងដេញស្រី ៗ ថាទៅធ្វើបាយធ្វើអីទៅដេញស្រី ៗ ទៅធ្វើបាយឲ្យចេញផុតពីហ្នឹងទៅណា ។ ធ្វើបាយរាងអរតិចដែរនិយាយឲ្យឃើញទៅដល់អីចឹងពួកម៉ោតម្រង់ជួរម៉ោជុំគ្នាមានណានៅអីណាអីណៃទេគង់តែមានឡានឈប់នៅថ្នល់ដែរ ថ្នល់មុខសាលាទឹកល្អក់ នេះអីចឹងឈប់ដើរពីហ្នឹងទៅ ហ៊្អំម៉ោតម្រង់ជួរបាន អាម៉េត ហ្នឹងនិយាយហើយដើរទៅក្នុងបាត់ទៅនៅតាកូនចៅគ្នាប្រហែលជា៩ ០ នាក់នៅពេញហ្នឹងនៅព័ទ្ធជិតទាំងអស់ហើយយើងដើរទៅណាសិទ្ធតាតម្រង់ជួររាប់គ្នាគ្រប់គ្នាតឹងអស់បាន វាចាប់ភ្ជង់ឲ្យលើកដៃខ្លះមានដាប់អង្រឹងទៅខ្សែអង្រឹងក្រមា... ។

សុជាៈ ចុះពូគេចងទេ?

ធីៈ ចង អាហ្នឹងគេចងតែទាំងអស់គ្នាហ្នឹងណា... ។

សុជាៈ គេយកទៅណាទៅ?

ធីៈ ចងទៅគេអត់យកទៅណាទេ គេប្រានចូលអាបន្ទប់មួយហ្នឹងបន្ទប់ប្រហែលម៉ារយម៉ែត្រពីគ្នាសិទ្ធតាបន្ទប់ណា ដាក់ខ្នោះជើងឆ្អែតបានវាចាប់ស្រាយក្រមា អាក្រមា ដាប់ ៗ ចេះអាចងសេកហ្នឹងដាប់ម៉ាយប់បានចាប់ស្រាយបានដាក់ខ្នោះវាហៅទៅសួរនាំ ៗ អីវាហៅ

ម្នាក់ម្តងបានទៅសួរនាំអីចឹងទៅថា យើងពាក់ព័ន្ធចូលដៃចូលជើងតាំងពីកាល់ អ្នកណា អ្នកណែនាំអីចឹងគេសួរហូរហែរអីចឹងណា ។ ហែអុឺ...និយាយទៅមានអ្នកណាណែនាំ មានមេមានកើយណែនាំពីរឿងធ្វើការងារឲ្យយកចិត្តទុកដាក់អីចឹងមានតែអីចឹង ហើយ យើងហាត់កាំភ្លើងការពារដែនអាកាសត្រូវយកចិត្តទុកដាក់អាយុជីវិតប្រទេសយើងអីចឹង ផ្ញើលើយើងអីចឹងគេមិនមែនណែនាំឲ្យយើងក្បត់អានេះក្បត់អាណោះក្បត់បក្សយើង បក្សអីណា ក៏យើង... ។

ម៉េងទ្រី: ជាប់នៅហ្នឹងម៉ានខែ?

ធី: ៣ខែបើមិន៣ខែ៤ខែ ។

សុជា: អាហ្នឹងគេដាក់នៅណា គេដាក់នៅកន្លែងណា?

ធី: អូហ៍ នៅអា...ដំបូងគេមិនដាក់នៅគេហៅថាស-២២អាកន្លែង១វត្តចាស់នោះសុទ្ធតាគុក ទាំងអស់ ដល់ហើយបានប្រហែលជា៣-៤ខែបានគេបញ្ជូនម៉ោស-២១។ប្រហែលជា ២ខែបានគេបញ្ជូនទៅកន្លែងហ្នឹងវិញអាកន្លែងដែលទឹកល្អក់មិញហ្នឹងបានគេឲ្យឈប់ឲ្យចូល ឃុំខ្លួនអីទៀតណា គេលែង១ទៅក្នុងប្រហែលជាម៉ាគីឡូ៤ជ្រុងនៅចាំងស្មៅនៅបោស ប្រាសចេញដើរបោសក្នុងអំពេញយើងនេះមានគេឲ្យហើយអាអ្នកស្រាលដែលទើបរួច ហ្នឹងណាចេញបោសថ្នល់១ចាំងស្មៅចាំងអី ទៅជួយដឹកព្រែកដឹកប្រឡាយនឹងគេហ្នឹង គឺខ្ញុំបានទៅម៉ាងៃទេ ដល់ទៅម៉ាងៃហ្នឹងម៉ាអាទិត្យក្រោយបានគេថាខ្ញុំហ្នឹងកសាងខ្លួនបាន ហើយបានគេបញ្ជូនទៅកំពង់ឆ្នាំងព្រលានយន្តហោះកំពង់ឆ្នាំងណា ។

សុជា: លោកពូខ្ញុំនិយាយកាត់តិចពូកាលពូទៅស-២១ពូទៅបាន២ខែហ្អី?

ធី: បែបខ្ទង់ អត់ដឹងថា២ខែហ្នងទេ អាហ្នឹងស្មានទេ ស្មានខ្ទង់ប៉ុនហ្នឹង ។

សុជា: ពេលដែលគេយកទៅដល់ធ្វើម៉េចខ្លះចូលទៅស-២១ហ្នឹង?

ធី: បាទ! គេអត់សួរនាំអីទេ សួរនាំជាងគេតានៅ...វ៉ៃ ធ្វើបាប... ។

សុជា: ចុះដិះអីទៅនៅស-២១?

ធី: ឡានសុទ្ធតាឡាន ។

សុជា: ឡានអី?

ធី: កាលហ្នឹងដូចអាកាត់ម៉ាស៊ីន អាកង់៤ ។

សុជាៈ ម៉ានឡាន?

ធីៈ កាលទៅជាមួយខ្ញុំកាលហ្នឹងដូចម៉ាឡានទេ ។

សុជាៈ ម៉ាននាក់ទៅ?

ធីៈ កាលទៅបញ្ជូនទៅម៉ាសាៗប្រហែលចេញបើម៉ោពីនោះអាហ្នឹង៣៣នាក់ ប៉ុនអាបញ្ចេញនេះប្រហែលជា៥នាក់៦នាក់អីទេ ។

សុជាៈ ម៉ោជាមួយពូផ្ទាល់ប្រហែលម៉ាន?

ធីៈ ម៉ោប្រហែល៥ - ៦នាក់អីទេ ។

សុជាៈ ឡានហ្នឹងគេដាក់ម៉េចទៅឡាន?

ធីៈ អាកង់គ្រប់ជិតៗណា ឡានៗទាហានយើងហ្នឹងប៉ុន្តែអាទាហានកង់៤ ។

សុជាៈ មានចងទេខ្នោះ?

ធីៈ ដាក់អាតឹងអស់ហ្នឹង ។ អាខ្នោះដាក់ដៃអាជើងក៏មានៗខ្នោះដែរ ។

សុជាៈ ជើងជាប់លើឡានអីចឹង?

ធីៈ គេដាក់ខ្នោះខ្ពស់ត្រឹមនេះប៉ុនស្ទូកដែក ។

សុជាៈ អីចឹងមុខគេចងទេ?

ធីៈ អត់ចងទេ ។

សុជាៈ ជិះតាមផ្លូវណា?

ធីៈ អាផ្លូវមើលកាលហ្នឹងចេញម៉ោផ្លូវធំណា អាផ្លូវបណ្ដោយស្ទឹងមានជ័យបត់អាមុខពេទ្យចិនហ្នឹងបត់ទៅត្បូងហើយបានចូលពីមុខម៉ោអីចឹង ប៉ុន្តែមានរបងស័ង្កសីគេជិនទាន់ អាពតតាំងពីចិញ្ចើមថ្នល់ចូលម៉ោហើយខាងត្បូងតាំងពីរោងកុនបូកោយើងហ្នឹងក៏របងសង្កសីគេត្រឹមហ្នឹងដែរ ។

សុជាៈ ចុះដល់ពេលម៉ោដល់ហើយ?

ធីៈ បានវាដកខ្នោះជើងហ្នឹងឲ្យយើងចុះទៅ ប៉ុនកាលហ្នឹងខ្ញុំចាំវាមិនច្បាស់ទេ បានឲ្យយើងចូលទៅបន្ទប់ណា ដូចកាលហ្នឹងដូចម៉ាបន្ទប់ខ្លះក៏មានម្នាក់ខ្លះក៏មាន២នាក់គេចេះតែឲ្យចូលៗគេដាក់នៅហ្នឹងណាហើយក៏វាឈប់សួរឈប់នាំអីទៀតដែរ ។ បើខ្ញុំចាំប្រហែលជាម៉ាខែ២ខែ

យូរដែរ បានវាបញ្ជូនឲ្យទៅកន្លែងៗដែលម៉ោមិញនេះវិញ បានគេដោះខ្នោះដោះអីចេញគឹងអស់ ។

សុជាៈ ពូខ្ញុំចង់សួរតិចទៀតអ្នកដែលគេយកទៅម៉ាឡានកន្លែងស-២១ហ្នឹងណា ពូមានស្គាល់ឈ្មោះ គេ ស្គាល់មុខគេទេ?

ធីៈ អត់ស្គាល់ហ្នឹងចម្រុះហើយ ដល់អាកន្លែងហ្នឹងចម្រុះលែងស្គាល់ហើយ អ៊ឺ...ដល់អាកន្លែងទៅណាខ្ញុំអត់ស្គាល់ទេ ។

សុជាៈ នៅពេលទៅដល់កន្លែងស-២១ហ្នឹងពូមានឃើញទិដ្ឋភាពអីយ៉ាងម៉េចទេ?

ធីៈ អត់មានឃើញទេ យើងគ្រាន់តែចូលទៅហ្នឹង យើងដឹងថាគុកហើយកន្លែងហ្នឹងប៉ុនតែវាយើងអត់មានបានដើរអីទេ វានាំយើងចូលវីឡាហ្នឹងគឺឲ្យចូលកន្លែងណា គឺចូលកន្លែងនោះគឺវាចាក់សោរចាក់អីជិតហើយណា ។

សុជាៈ ពូចូលក្នុងបន្ទប់មួយណា?

ធីៈ ខ្ញុំអត់ចាំទេ ។

សុជាៈ ចុះអគារ?

ធីៈ ខ្ញុំក៏អត់ចាំដែរ ។

សុជាៈ ទទឹងថ្ងៃ ហែបណ្ដោយថ្ងៃ?

ធីៈ ខ្ញុំអត់ចាំទេ ។ ដឹងតែចូល...ហែខ្ញុំនិយាយសូម្បីតែទឹកល្អក់ណា បើសិនចូលប្រហែលជា ២-៣ខែអាហ្នឹងរោងគេធ្វើទេ អត់មានទះថ្មទេណាបើនៅៗដែលទួលស្លែងដាក់នៅទះថ្មប៉ុន្តែបើនៅទឹកល្អក់ ។

សុជាៈ ដាក់ទះថ្មហ្នឹងទះគេ...?

ធីៈ ទះល្វែងៗណា ប៉ិនល្វែងហ្នឹងមានបន្ទប់ខណ្ឌ ។

សុជាៈ បន្ទប់វាប៉ុនៗម៉ានប្រហែលជាម៉ានម៉ែត្រ?

ធីៈ ប្រហែលជាម៉ាម៉ែត្រកន្លះអីអស់ហើយ ។

សុជាៈ ក្នុងបន្ទប់មានអីខ្លះ?

ធីៈ បន្ទប់ហ្នឹងអាលីញទទេ ។

សុជាៈ ក្នុងបន្ទប់ហ្នឹងមានដាក់ខ្នោះទេ?

ធី៖ ក្នុងបន្ទប់ហ្នឹងអត់មានខ្នោះទេ គេចាប់ដោះចេញអស់ហើយ ។

សុជា៖ គេលែងទទេ?

ធី៖ អត់ទេ នៅៗតាដាក់ខ្នោះ...ប៉ុនចូលមុនដំបូងគេដាក់ខ្នោះជើងទៀតប៉ុនអាហ្នឹងមិនដឹងថាធ្ងន់ស្រាលអីយ៉ាងម៉េចទេ ប៉ុនក្រោយម៉ោខ្ញុំប្រហែលជា៤-៥ខែគេដោះអស់ៗនៅតែ ខ្នោះដៃទេ រួចទៅដឹកម៉ោនៅកន្លែងស-២២ហ្នឹងវិញ ។ ខ្ញុំនៅចាំមិត្តភក្តិខ្ញុំទះនៅក្រោយនោះប៉ុនអាឡូវវាមានប្រពន្ធនៅណោះ វាក៏អ្នកទោសដែរអ៊ី...វាអ្នកទោសអត់មានអ្នកទោសអីទេ កាលហ្នឹងវាដូចជាឈឺខួរក្បាលវាយ៉ាងម៉េចទេ វានៅចិញ្ចឹមជ្រូកអែបហ្នឹង វាឈ្មោះ អាខាន់ ខ្ញុំថាហ្អែងហ្នឹងដូចជា...ម៉េចក៏ហ្អែង...វាប្រធានខហើយគេចោទវាថាវាសតិអារម្មណ៍ក៏ឲ្យវា...ស្រុកនៅជាមួយគ្នាប៉ុនអាឡូវវានៅលើវត្តនោះ ប៉ុនវាអត់មានទោសមានពៃរ៍អីទេ ប៉ុនអាហ្នឹងគេចោទថាសតិអារម្មណ៍ម៉េចទេ គេដកឲ្យវាម៉ោចិញ្ចឹមជ្រូលទៅអាហ្នឹងវាស្គាល់អ្នកទោសច្រើនស្គាល់អ្នកៗយាមគុកស-២២ហ្នឹងច្រើន ហើយខ្ញុំស្គាល់ អាផាន់ៗហៅរ៉ែន ហ្នឹងក៏ដោយសារ អាផាន់ ហ្នឹងចេះឲ្យ...អ្នកយាមៗយាមហ្នឹងក៏គ្នាអត់ដែរប៉ុន្តែអាផាន់ ហ្នឹងវាអ្នកចិញ្ចឹមជ្រូកហើយកាលហ្នឹងជ្រូកពីអាពតខ្ញុំប្រាប់ប្អូនអើយល្អដាងយើង...ស៊ីតាអង្ករផ្ទរសល់យូរៗ ស្ករត្នោតយើងដែលធ្ញើសល់ពីឆ្នាំទៅអីវ៉ាន់ក៏គេដឹកយកឲ្យជ្រូកស៊ីដែរ ។

សុជា៖ ចុះដល់ពេលពូហូបបាយហូបទឹកអីហូបរបៀបម៉េចដែរ?

ធី៖ អត់មានដាក់ស្រួលទេ យើងស៊ីតាម៉ាចានចង្កឹះហ្នឹងៗ គឺគេញ៉ាំហើយស្រេច មិនដឹងគេញ៉ាំស្អីទេ ព្រោះវាអាងឹតណា ។ អីចឹងម៉ាងៃតាម៉ាពេលទេ ។

ម៉េងទ្រី៖ ពេលណា?

ធី៖ វាមានតែម៉ាពេលព្រឹកហ្នឹង តាម៉ាពេលព្រឹកហ្នឹងគឺដាក់ចោលប្រហែលជាម៉ោង១០ ។

ម៉េងទ្រី៖ ចុះបត់ដៃបត់ជើងអីធ្វើម៉េចទៅ?

ធី៖ គេដាក់កន្ថោរទុកអីឆ្នាំងអីឲ្យយើងបត់ដៃបត់ជើង ព្រលឹមមានគេអ្នកទោសស្រាលហ្នឹងគេអ្នកយកៗទៅ ។

សុជា៖ ចុះការយាមកាមនៅក្នុងគុកហ្នឹងយាមយ៉ាងម៉េច?

ធី៖ អត់ដឹង ព្រោះគេនៅយើងនៅក្នុងគុកហ្នឹង គេចាក់សោរតឹងអស់ដូចថាស្អែកឡើងគេយកទឹកម៉ាផ្តិលយកស្ទីយកម៉ោដាក់ឲ្យយើងហ្នឹងគឺគេប្រមូលអ្វីដែលចាស់ៗហ្នឹងយកចេញម៉ោ អាចាស់ៗដែលយើងបត់ដៃបត់ជើងហ្នឹងណាគេយកចេញម៉ោ ។

សុជា៖ ចុះអាអ្នកម៉ោប្រមូលហ្នឹងជាអ្នកទោសឬក៏យ៉ាងម៉េច?

ធី៖ ប្រហែលជាអ្នកទោសប៉ុន្តែទោសគេរួច ។

សុជា៖ ពាក់យ៉ាងម៉េច?

ធី៖ ពាក់ខ្មៅៗហ្នឹង ខោអាវពីអាពតមានតែខោអាវខ្មៅ ។

ម៉េងទ្រី៖ ចុះយើងមានដែលដូរខោអាវទេ?

ធី៖ យើងអត់ទេមានតែខោខ្លី ។ អត់មានខោអាវអីទេ ។

ម៉េងទ្រី៖ ចុះអ្នកនៅខាងស-២១?

ធី៖ ស-២១នៅសល់តែខោខ្លី ។ អត់មានខោអាវទេ ខោអាវគេដោះតាំងពីចូលអាស-២២ អា...ដូរទឹកល្អក់នោះគេដោះតាំងពីនោះរួចទៅហើយ ។

សុជា៖ ពេលដែលចូលម៉ោហ្នឹងម៉ានៃគេទុកយើងចោលទទេឬមួយក៏មានសួរនាំយើងខ្លះៗ?

ធី៖ បើសិនយើងម៉ោស-២១អត់សួរទេ បើនៅវ៉ៃយើងក៏នៅស-២២ដែរ អាហ្នឹងបើសិនវាសួរនាំវ៉ៃយើងក៏នៅណោះដែរ នៅអីស-២២ទឹកល្អក់ ។

សុជា៖ ចុះពេលគេដោះលែងគេធ្វើរបៀបម៉េចដំណើរការដោះលែង?

ធី៖ អ៊ឺ...តាមពិតអត់និយាយផង អត់មាននិយាយអីគឺងអស់ប៉ុន្តែគេឲ្យយើងឡើងឡានទៅស-២២ទៅដល់ណោះបានគេនិយាយ ។

សុជា៖ អ្នកណាគេអ្នកនាំយើងចេញពីបន្ទប់?

ធី៖ ពួកអ្នកនៅយាមហ្នឹង ។

សុជា៖ គេមានស្ពាយកាំភ្លើងស្ពាយអីទេ?

ធី៖ ស្ពាយៗស្ពាយសឹទ្ធតាកាំភ្លើងអាការតឹងអស់ពួកហ្នឹងឲ្យយើងចូលទៅដោះខ្នោះយើង ។

សុជា៖ ពេលពូចេញម៉ោចេញម្នាក់ឯងឬក៏ចេញទាំង៥នាក់?

ធី៖ អត់ទេ ចេញផ្សេងៗគ្នា ។ ពេលដាក់យើងក៏មិនមែនដាក់ជាមួយគ្នាដែរ អត់ដាក់ជាមួយគ្នាទេ ។

សុជាៈ ចេញពីស-២១ចេញម៉ាននាក់?

ធីៈ ខ្ញុំចាំប្រហែលជា...ប្រហែលជា៩០នាក់ ព្រោះទៅដល់នោះច្រើន ។

ម៉េងទ្រីៈ ខ្ញុំចង់និយាយថាចេញពីគុកដើរចេញទៅស-២១ជាមួយគ្នាណា ប៉ុន្មាននាក់ មិនមែនទៅដល់ស-២២ហើយ...?

ធីៈ អត់ទេ ខ្ញុំចាំថាពេលឡានដាក់យកទៅហ្នឹងណា ដែលចេញម៉ោក្រៅហ្នឹងណាដែលទាញ... ឡើងឡានហ្នឹងណា ប្រហែលជា៧-៨នាក់ ប៉ុនទៅដល់កន្លែងស-២២វិញណា ២ឡាន ។

ម៉េងទ្រីៈ ២ឡានហ្នឹងចេញម៉ោពីកន្លែងណាខ្លះ?

ធីៈ អ៊ឺ...ខ្ញុំស្មានទេ អាហ្នឹងចេញពីស-២១ ចេញគាខ្ញុំ៤-៥នាក់ហ្នឹងណា ប៉ុនទៅដល់នោះឃើញប្រហែលជា២ឡានហ្នឹងប្រហែលជាចេញពីហ្នឹងទៅ...ស្មានមើលព្រោះគ្រាន់តែល្ងឹល្ងឹអត់មានថាជីងស្អីជីងអីទេ មើលសក់ក្បាលនេះគឺគឺងអស់អត់ ហែខ្មៅឃ្មឹកទាំងអស់ហើយទៅដល់នោះខ្ញុំដេកលើឡានក៏ដេកដែរ ស្អីក៏ដេកដែរ ចង់អាណាវៃអាណាធាក់អីឡើងគាឡានហ្នឹងក៏អត់រួចដែរ ។

សុជាៈ ពូខ្ញុំចង់សួរពូបន្តិចពូៗពូមានស្គាល់ប្រធានគុកស-២១ទេ?

ធីៈ អត់ស្គាល់ទេ ។

សុជាៈ គេអត់មានណែនាំ និយាយអី ចុះប្រធានស-២២?

ធីៈ អាហ្នឹងបែប មានតែ អាម៉េត ហ្នឹងទេប្រធានធំជាងគេ ព្រោះគេស្គាល់ច្បាស់វានិយាយទៅប្រធានកងពល ។

សុជាៈ ម៉េត ហ្នឹងរាងរៅម៉េចដែរ?

ធីៈ ខ្ពស់ស្រឡះ ។

សុជាៈ ស ហែ ខ្មៅ?

ធីៈ មិនសទេ ស្រអែមៗ ។

សុជាៈ ចុះអ៊ឺ...ពេលដែលគេយកពូចេញម៉ោពីស-២១ហ្នឹងវិញ ៤-៥នាក់ហ្នឹងជាអ្នក...?

ធីៈ ព្រោះឡើងឡានជាមួយខ្ញុំ បែបខ្ទង់៤-៥នាក់ទេ មិនលើសពីហ្នឹងទេ ។

សុជាៈ ចុះអ្នក៤-៥នាក់ហ្នឹងជាអ្នកដែលទៅជាមួយគ្នា?

ធី៖ មិនមែនទេ ៗ ផ្សេងពីគ្នា ៗ អាជិះឡានទៅគឺដល់ពេលដាក់ហ្នឹងក៏ដាក់ផ្សេងពីគ្នាដែរ ដល់តែយើងឡើងឡានម៉ោក៏មានទីម៉ាប្រកកន្លែងហ្នឹងធំណាស់ ៗ

ម៉េងទ្រី៖ ពេលដែលពូចេញម៉ោពីស-២២ហ្នឹងទៀតទៅដល់កំពង់ឆ្នាំង?

ធី៖ ហ្នឹងហើយ ៗ

ម៉េងទ្រី៖ ពូមានបាននិយាយគ្នាថាអ្នកណាខ្លះដែលជាប់នៅស-២១ដូចពូ មានម៉ាននាក់?

ធី៖ អត់ ចាំមើលខ្ញុំនិយាយទម្រាំតែខ្ញុំទៅដល់កំពង់ឆ្នាំងហ្នឹងណាគេឲ្យខ្ញុំហ្នឹងក្រាលហ្នឹង ស៊ីបាយ ទឹកយើងចុះមុជទឹកគេលែងដាក់ខ្នោះលែងដាក់អីយើងប្រហែលជា២-៣ខែទៀតអីចឹងគេឲ្យយើងចេញធ្វើការម៉ាផែនៅខាងក្រៅ ហើយម៉ាអាទិត្យក្រោយម៉ោទៀតបានយើងគេថា យើងកសាងខ្លួនបានក៏ជួយធ្វើព្រលានយន្តហោះកំពង់ឆ្នាំង គេយកយើងម៉ោកំពង់ឆ្នាំងៗ ប៉ុនខ្ញុំធ្វើព្រលានយន្តហោះហ្នឹងបានប្រហែលជាអស់ហើយ៥ខែ...បានគេឲ្យយើងហ្នឹង ម៉ោនិយាយឲ្យយើងកាន់របបកាន់អីធ្វើជាទ័ពធ្វើអីហ្នឹង... ៗ

សុជា៖ ហើយពូទៅដល់អ៊ឺ...យកពូពីស-២២ទៅស-២១ហ្នឹងយកទៅពេលព្រឹកឬក៏ពេលថ្ងៃពេលទៅដល់ស-២១ណា?

ធី៖ អ៊ឺ...ប្រហែលម៉ោងអាហ្នឹងខ្ញុំស្មានទេណា មិនដឹងម៉ោងម៉ានទេ ប៉ុនព្រឹកប្រហែលថ្ងៃរះផុតចុងឈើអីហ្នឹង ៗ

សុជា៖ ក្នុងឆ្នាំណាដែរពូ?

ធី៖ ក្នុងឆ្នាំ៧៧ហ្នឹង ក្នុង៧៧ហ្នឹង ៗ

ម៉េងទ្រី៖ អូហ៏ ទៅដល់ឃើញគេធ្វើរបៀបម៉េច របងអីធ្វើរបៀបម៉េចគេឲ្យចូលរបៀបម៉េចអី?

ធី៖ អាពីក្រៅទៅ ពាសស័ង្កសីតឹងអស់ប៉ុនទៅដល់ក្នុងធម្មតាដូចទះយើងធម្មតា ផ្ទះថ្ម...រួចទៅគេឲ្យយើងនៅណា...អត់មានថាឲ្យឃើញមនុស្សហ្នឹងកុះករ មនុស្សនៅយាមតាមុខហ្នឹងទេ ៗ

ម៉េងទ្រី៖ អត់មានឃើញអ្នកភូមិអ្នកអីទេ?

ធី៖ អត់ឃើញទេ មិនដឹងអ្នកភូមិហ្នឹងនៅណាទេ ៗ

ម៉េងទ្រី៖ ពូពេលដើរចូលទៅស-២១ហ្នឹងពេលដើរទៅមានឃើញអគារម៉ានជាន់?

ធី៖ តាមផ្ទះថ្មល្វែងហ្នឹងគឺពេលខ្ញុំទៅហ្នឹងសឹទ្ធតាផ្ទះថ្មល្វែង១ចាស់ៗហ្នឹង... ៗ

សុជាៈ កាលហ្នឹងឆ្នាំឲ្យប្រាកដគឺឆ្នាំណា៧៧ឬ៧៦?

ធីៈ ឆ្នាំ៧៧ ។

សុជាៈ ៧៧?

ធីៈ ហ្នឹងហើយ៧៧ ។

សុជាៈ ដើមឆ្នាំឬក៏ចុងឆ្នាំ?

ធីៈ ប្រហែលជាដើមឆ្នាំបើមិនខែ៣ខែ៤ខ្ញុំវាមិនចាំច្បាស់ៗហើយ ។

សុជាៈ ជាប់នៅនោះរយៈពេលខ្លីទេហ្អី?

ធីៈ បើខ្ញុំប្ដូកគឺងអស់បើខ្ញុំនៅយូរជាងគេនៅ...នៅ...ទឹកល្អក់ ។

សុជាៈ ស-២២?

ធីៈ បាទ!

សុជាៈ ស-២១ប្រហែលម៉ាននៃពូ?

ធីៈ ខ្ញុំម៉ាខែទៅម៉ាខែកន្លះអីអស់ហើយ ស្មានណាសីងមិនដល់ព្រោះពេលហ្នឹងគឺទន់ខ្លួនគឺងអស់ដូចអត់ដឹងខ្លួនទេ ដឹងតែនៅ... ។

ម៉េងទ្រីៈ មានបានមុជទឹកមុជអីទេ?

ធីៈ អត់ទេ អត់ស្គាល់ជាតិទឹកទេ គឺអត់មានស្គាល់ជាតិទឹកទេ ។ ប៉ុន្តែនៅឃ្លាំងដាក់អីស៊ីហ្នឹង ។

សុជាៈ ម៉េចបានពូដឹងថា អាហ្នឹងស-២១?

ធីៈ ហ្អេ ស្គាល់តាលហូត នៅហ្នឹងគឺ...ដល់ទៅវាងមានកម្លាំងយើងនិយាយទៅយើងនិយាយទៅម៉ោពីស-២២វិញចាប់ដោះខ្នោះឲ្យយើងមុជទឹកមុជអីស៊ីបាយស៊ីអី គ្រាន់តែថាយើងមិនឆ្អែតម៉ាចានៗអីហោយើងចាំងស្មោចាំងអីរើសស្លឹកដូងសម្បកអាឡឹកដែលគេស៊ីចោលផ្លែល្ហុងខ្ចីដែលដើរលបបេះ លបលួចអីគេអីចឹងទៅណា អាហ្នឹងចាប់មានកម្លាំងហើយចាប់ដឹងហើយៗម៉ោដឹងជាងគេទៅកំពង់ឆ្នាំង ។

សុជាៈ ម៉េចបានដឹង?

ធីៈ ដឹងព្រោះពេលហ្នឹងពេលគេដាក់ឡានយើងក្រឡាប់ចុះក្រឡាប់ឡើងកាលយើងអត់ទាន់ជាប់ណាប៉ុន្តែដឹងថាកន្លែងហ្នឹងកន្លែងស-២១ដឹងព្រោះចេះយើងធ្លាប់ស្គាល់ដែរធ្លាប់...កាល

យើងគេមិនទាន់ចាប់មិនទាន់អីគេរើសក្តសី កាលហ្នឹងអត់មានរបងទេ គេបណ្តោសសក្តសីទេ អីចឹងកាលយើងអត់ទាន់ដាប់ដីអំពេញគេឲ្យយើងចូលយាមចូលអី កាលមិនទាន់កាន់កាំភ្លើងធំកាំភ្លើងអីនោះក៏គេឲ្យយើងចូលម៉ោកន្លែងហ្នឹងហៃកាលនៅជាទ័ពនៅជាអី អាទ័ពត្រឹមត្រូវគេនោះណា ហ្នឹងហើយ ។

ម៉េងទ្រីៈ ពេលដែលក្រោយម៉ោឆ្នាំ៧៩-៨០ពូបានទៅមើលកន្លែងទួលស្លែង?

ធីៈ ទៅមើលកន្លែងទួលស្លែង ។

ម៉េងទ្រីៈ ពូចាំច្បាស់ទេ កន្លែងដែលទៅមើលណា ហើយហ្នឹងកន្លែងដែលពូជាប់ជាកន្លែងតែមួយឬក៏ជាកន្លែងខុសគ្នាព្រោះពីមុនខ្មែរក្រហមឃុំមនុស្សមិនមែនឃុំតែនៅក្នុងក្រឡុកកន្លែងដែលពូទៅមើលឆ្នាំ៧៩-៨០ទេវាអាចឃុំ... ។

ធីៈ ខ្ញុំកាលដែលខ្ញុំទៅមើល អាហ្នឹងបែបវង្វេងទៀត អីចឹងអ៊ី...យើងក៏មិនដឹងថាកន្លែងនេះៗអីចឹងហើយសូម្បីតែអ្នកយាមពេលហ្នឹងណា ជូនដំណើរយើងពន្យល់យើងកន្លែងនេះកន្លែងណា ហើយអ្នកដែលស្គាល់ខ្ញុំ៧៩ណានៃហ្អែងចូលកន្លែងនេះព្រោះគាត់នៅជាទ័ពដែរណាអ៊ី...ដែលជាមួយយើងដែលចូលទៅលេងទៅមើលណាចុះយើងមិនចេះប្រាប់ថាហ្អែងចូលមើលទៅយ៉ាងម៉េចអីយ៉ាងម៉េចណា ដល់ចូលទៅនៃ អាល្វែងនេះហ្អែងនៅអានេះ ។

ម៉េងទ្រីៈ ម៉េចបានគេដឹង?

ធីៈ អាអ្នកដែលៗដូចថាវាចេះនាំ កាល៧៩ដូចទ័ពនាំយើងទៅមើលទៅអីដែរដែលយើងសុំគេចូលទៅមើលហ្នឹងណា ។ អីចឹងក៏គេព្រោះទ័ពខ្លះវានៅ...ព្រោះខ្លះក៏ធ្វើទ័ពម៉ោលហូតហ្នឹង ៧៩ក៏នៅទ័ពនៅអំពេញដែរអាទ័ពអាពតណា ។ អីចឹងខ្លះក៏នៅធ្វើជាមួយអ៊ី... វៀតណាមអី... ។

ម៉េងទ្រីៈ ចុះពូធ្លាប់ពូមានភ្ញាក់ទេ បន្ទប់នេះយើងនៅបន្ទប់នេះមិនមែនទេ?

ធីៈ សូម្បីតែខ្ញុំអត់ដឹតថាបន្ទប់នេះដែរ ។

ម៉េងទ្រីៈ វាអាចមិនមែនជាកន្លែងដែលពូទៅទេ ព្រោះជាប់ស-២១ក្នុងឆ្នាំ៧៧ ហើយនិងកន្លែងដែលពូទៅក្នុងឆ្នាំ៨០វាអាចខុសគ្នា ។

ធីៈ ខុសគ្នាៗ ។

ម៉េងទ្រី៖ មិនមែនដាក់កន្លែងពូទៅក្នុងឆ្នាំ៨០ទេ?

ធី៖ គ្រាន់តែយើងដឹងថាផ្លូវចូលផ្លូវហ្នឹងព្រោះសំណាក់ៗអាពត អត់ដោះតែងអស់អាសម្បកក្រៅណា ប៉ុន្តែគ្រាន់ថាខាងក្នុងយើងអត់បានដើរទៅមើលទេ...។

ម៉េងទ្រី៖ បើតាមខ្ញុំចាំ បើយើងចូលទៅឆ្នាំ៨០ គេឲ្យយើងចូលទៅមើលជារបៀបសាលាណា?

ធី៖ ហ្នឹងហើយ ។

ម៉េងទ្រី៖ សាលាវាមាន៤អគារណា ហើយអគារមួយៗមាន៣ៗជាន់ ហើយពេលដែលពូចូលជាប់ឆ្នាំ៧៧ពូមើលឃើញអគារហ្នឹងមាន៣ជាន់ប៉ុកនិយាយឲ្យខ្លីទៅ៧៧ហើយនិង៨០ហ្នឹងជាកន្លែងតែ១ឬជាកន្លែងខុសគ្នា?

ធី៖ តាមៗមើលទៅខ្ញុំប្រហែលជាវង្វេង ប៉ុន្តែម៉ោឃើញច្បាស់ខ្ញុំចូលដូចថា៨១-៨២នេះខ្ញុំចូល៨១-៨២នេះណា អីចឹងខ្ញុំស្គាល់ច្បាស់ត្រឹមម៉ាចូល៨១-៨២នេះ ប៉ុន្តែមិនដឹងថាយើងហ្នឹងជាប់នៅបន្ទប់ណា មិនដឹងថាជាប់នៅបន្ទប់ណា ។

ម៉េងទ្រី៖ ពូដឹងច្បាស់ថាពូជាប់នៅពេលដែលពូចូលទៅហ្នឹងចូលទៅកន្លែងហ្នឹងហើយ ប៉ុន្តែអត់ដឹងនៅបន្ទប់ណា ឬមួយពូអាចជាប់នៅខាងក្រៅកន្លែងពូចូលទៅហ្នឹង ។

ធី៖ តាមពិតតាមខ្ញុំចូលទៅដូចអាកន្លែងមិនមែនជាកន្លែងគុកទេ ព្រោះអាកន្លែងខ្ញុំចូលទៅមើលនោះនៅក្នុងនោះហៃខ្ញុំដែលគេដាក់ឡានចូលនោះគឺចូលរាក់ៗជាងអា...ចាំមើលណា របស់វានៅមុខដល់របស់វានៅមុខអ៊ី...ចូលម៉ោមិនមានអាខ្សែប្រឡាយទឹកៗស្អុយមួយ ។ អីចឹងអ៊ី...នៅក្នុងហ្នឹងណា គេឲ្យចូលមើលនៅក្នុងហ្នឹងទៅទៀត ប៉ុន្តែវាបង្ហាំងតាំងពីក្រៅនោះបើអាម្តុំដែលឡានដាក់ៗស្អីនោះអាបាញ់ទឹក...ឡានទឹក ហើយដើងហ្នឹងសិទ្ធគុកបើនិយាយឲ្យចំសិទ្ធគុកហើយគុកតឹងអស់ ។

ម៉េងទ្រី៖ អីចឹងពូជាប់នៅខាងក្រៅនោះទេ?

ធី៖ ប្រហែលជានៅខាងក្រៅ អត់ចូលទៅក្នុងទេ ។

ម៉េងទ្រី៖ ប៉ុន្តែឆ្លងកាត់របងស័ង្កសីអីហើយ?

ធី៖ ហើយៗ ហៃខ្ញុំនិយាយអាស-២២ក៏ខ្ញុំទៅមើលអត់ចូលទៀត ។

ម៉េងទ្រី៖ បាទ!

ធី៖ ព្រោះបើអ្នកស្រុកយើងគោរពកន្លែងហ្នឹង ៗអាហ្នឹងធ្វើឃ្លាំងគេធ្វើក្រោលណាៗ រុសអាតួផ្ទះថ្ម មួយៗទេ អាផ្ទះធំមួយៗទេ ក្រៅពីហ្នឹងរុសអស់ទៀត ៗ កាលហ្នឹងស្គាល់កន្លែងហ្នឹងច្បាស់ ព្រោះកាលហ្នឹងកាលយើងអត់ទាន់ដាប់ក៏យើងធ្លាប់ដើរកាត់កាលនៅជាទ័ព ក៏ខ្ញុំអ្នកហាត់កាំភ្លើងធំៗមិញហ្នឹងណា គឺថាអត់បានដើរតាមថ្នល់ទេ ដើរផ្លូវកាត់ព្រោះម៉ាក្រុមហ្នឹងគេហៅកងពល កងវរៈ១៣៦ហាត់នៅខាងជើងសាលាទឹកល្អក់ហ្នឹង មានម៉ាក្រុមហាត់កាំភ្លើងធំនៅហ្នឹងគេដាក់នៅហ្នឹងម៉ាក្រុម ហើយខ្ញុំគេដាក់នៅខាងលិចអាគុកហ្នឹង ខាងលិចអាស-២២ហ្នឹង ប្រហែលជាដីកន្ទះគីឡូពីដើមមានផ្ទះដប៉ុនណាផ្ទះដប៉ុនហ្នឹងម្ដុំ យើងដាក់អែបផ្ទះដប៉ុនហ្នឹង ទៅខាងជើងប៉ុស្ដិ៍វិទ្យុប្រហែលជា...៥-៦០០ម៉ែត្រ ៗ

ម៉េងទ្រី៖ ពូអ៊ឹ...សំណួរប្រហែលជាសំណួរចុងក្រោយខ្ញុំហើយ ពូគិតថាហេតុអីបានជាខ្មែរក្រហមឈ្នះ ហើយចុងក្រោយហេតុអីបានជាខ្មែរក្រហមចាញ់ តាមពូយល់?

ធី៖ ខ្ញុំយល់ចេះ ដូចខ្ញុំប្រាប់ប្អូនឯងមកពីសូម្បីតែខ្ញុំណា ក៏មានកំហឹងដែរអីចឹងបើប្អូនមួយចំនួនទៀតក៏មានកំហឹងដែរមិនមែនអត់កំហឹងទេ ប៉ុនយើងគ្រាន់តែនិយាយថាវា...មិនកើតហើយពេលហ្នឹងគឺជាពេលវ៉ៃយួនទៀត ប្អូនឯងតាមដានមើលបើពេលហ្នឹងគេហៅទៅវ៉ៃនៅ ប៉ុនមិនមែនតាម៉ាផ្លូវហ្នឹងទេណា ផ្លូវតាកែវក៏វ៉ៃ គិរីវង្សកោះអណ្ដែតនេះ គឺចូល...ដល់ពេលចាប់យួនប្រានម៉ោវិញណា ប្រានចូលម៉ោៗទាន់ៗដាន់តឹងអស់ ៗ តាមពិតគឺថាទ័ពម៉ាភាគខាងស្វាយរៀង ខាងព្រៃវែង ខាងបូព៌ា...សឹងអស់ហើយព្រោះអាអ្នកចាប់ម៉ោណេះក៏ងាប់ទៅ អាណាដែលចាប់មិនទាន់ហ្នឹងដែលប្រាសទៅណោះទៅណា ៗ ហើយសូម្បីអាអ្នកក្នុងស្រុកហ្នឹងរដ្ឋធានីអ្នកនៅជុំវិញសូម្បីប្អូនឯងស្គាល់បើមានស្គាល់គេដែល...យន្តហោះកំពង់ឆ្នាំង ១០គីឡូប្អូនជ្រុងធំជាងអាពោធិចិនតុងទៀត សួរថាទ័ព...ទាំងអស់មិនមែនប្រជាជនទេ គឺទ័ពតឹងអស់ដែលនៅធ្វើព្រលានហ្នឹង ហើយសួរថាព្រលានហ្នឹងអ្នកណាដែលអ្នកធ្វើទ័ពហ្នឹងត្រឹមត្រូវសឹទ្ធអ្នកមានទោសតឹងអស់ ហើយប្អូនអើយ ទ័ពកាលហ្នឹងដែលនៅធ្វើព្រលានហ្នឹងមិនមែនទ័ពជាងម៉ាស៊ីនអីដូចយើងទេ សឹទ្ធតែគាស់គល់ត្នោតក៏ដោយដៃស្អីគឺថា វេទនាហួសៗហេតុពេកហៃខ្ញុំនិយាយធ្វើនយោបាយឲ្យទៅវ៉ៃយួនទៀត ប៉ុនធម្មតាទេ ហេតុការណ៏ ហេតុតែចង់សុខចង់រួចខ្លួនចេះតែធ្វើទៅ ប៉ុនវា **ចៃដន្យអាពេលយួនវ៉ៃចូលម៉ោវិញនេះមានមេក្រូស្រែកឲ្យដាក់អាវុធដាក់អីចឹង**

**ណា ហើយមិនមែនយួនស្រែកទេ ខ្មែរអ្នកស្រែកហើយដល់តែមានពេលខ្លះមានទ័ពខ្មែរដើរជាមួយយួនអី ក៏គេនិយាយម៉ោហូរហែរទៅ ហៃអានិយាយហ្នឹងពិតជាមានអ្នកក្នុងនោះក៏វាអស់ទឹកចិត្តអ៊ឺ...និយាយឲ្យចំទៅវាមិនខុសប្លែកពី...វាថាឥតន័យក៏ក្មេងល្ងក់អូសកាំភ្លើងអត់ទាន់ផុតពីដីម៉ោដឹកនាំ...។**

សុជាៈ ចុះពូខ្ញុំចង់សួរពូ ពេលវៃជាមួយវៀតណាមពូមានឃើញសកម្មភាពអីខ្លះដែរ ដែលចូលទៅដល់ដី...?

ធីៈ ខ្ញុំនិយាយករចុះវៀតណាមត្ខឹងខ្មែរយើងថា អាក្រក់...គ្រាន់តែគេគ្មានទៅចាប់រំលោភអីគេទេ អត់មានទេ បុិនវាកតែបាញ់គ្រាន់តែផ្ទុះក៏ដុតចោលដែរខ្ញុំនិយាយវៃចូលត្រឹមម៉ានខ្ទេចត្រឹមហ្នឹង ។

សុជាៈ ចុះមានបាញ់ប្រជាជនស្លូតត្រង់អីទេ?

ធីៈ ថា...ប្រជាជនក៏វាបាញ់ដែរឲ្យតែប្រជាជនរត់មិនទាន់ក៏វាបាញ់គឹងអស់ដែរ ។ ហៃដល់តែឃើញយួនចូលៗម៉ោឯងវិញណាបើជាខ្មែរយើងអ្នកអត់ម៉ោផ្ទុះលីដែកប្រហោងទៅហ្នឹងវិញ និយាយពីខ្មែរយើងនែ៎ សីទ្ធតាពួកម៉ាកខ្ញុំហើយ ឲ្យតែអ៊ឺ...ឲ្យទ័ពហ្នឹងឲ្យតែអ្នកឯងហ៊ានតែតដៃចុះចូលក៏បាញ់មិនចុះចូលក៏បាញ់ចោលដែរម៉ាឆាវមុនដំបូងណា មានតែយួនទេ អ្នកឃាត់ ។

សុជាៈ ចុះកាលៗវៃចូលវៀតណាមណា មានបញ្ហាពីថ្នាក់លើទៅថាឲ្យសម្លាប់ខ្លាំងទេដូចសម្លាប់ជនស្លូតត្រង់ទេ?

ធីៈ អ៊ឺ...អានេះចេះ តាមពិតខ្មែរយើងវៃចូលយួនហ្នឹងដូចបរន្តភ្លើងកំហឹង អើកាលហ្នឹងវា...ណែនាំរឿងខ្មែរ ខ្សែអ៊ុងដីខ្មែរទៅអស់យួនយ៉ាងម៉េច វាចេះតែណែនាំអីចឹងហើយអាចរិតខ្មែរយើងហ្នឹងដូចជាមានកំហឹងជាមួយយួនហ្នឹងទៀតណា ដូចជាមានកំហឹងអីចឹងមិនបាច់មេឃាត់ទេ ទោះជាមេមិនឃាត់ទៀត ហៃ...ខ្ញុំឃើញយួនអ្នកដែលវៃចូលម៉ោហ្នឹងទ័ពយួនច្រើនជាងទ័ពខ្មែរទៅទៀតដូចថា ទ័ពយើងមានតែ១យួនមានដល់ទៅដប់ម៉ាហឹកហ្នឹងណាសូម្បីវៃបើចែកមុខសញ្ញាគ្នាវៃក៏វៃអត់ទាន់ខ្មែរដែរយួនវៃនោះ ខ្មែរយើងវៃខ្លាំងណាស់ តែដល់ក្រោយម៉ោហើយខ្ញុំចាំកាលហ្នឹងវៃដល់ម្តុំនេះឈប់ឲ្យទ័ពខ្មែរយើងវៃ ម្តុំ...

ជិតដល់កំពង់ឆ្នាំង ឲ្យខ្មែរអ្នកបញ្ជូនឈ្លើយ គេហៅពួកអាពតចុះចូល គេចាប់បានហ្នឹងណា សូម្បី...បញ្ជូន១០ក៏លបបាញ់ចោលអស់៥ ដែរខ្មែរយើងនោះ ។

សុជាៈ បាញ់គ្នាឯង?

ធីៈ បាញ់តែគ្នាឯងហ្នឹង ។

សុជាៈ ចុះពូកាលវ៉ៃនៅវៀតណាមពូនៅក្នុងកងពលវរអីដែរ?

ធីៈ កាលហ្នឹងដូចចាប់បន្ទំណា នៅចម្រុះកងពលគេរៀបរួចទៅហើយ ។

សុជាៈ គ្មានកងពលទេ?

ធីៈ អ៊ឺ...ស្អីៗ គេរៀបចំទៅហើយ ទៅវ៉ៃពួកខ្ញុំទៅហ្នឹងហាក់ដូចជា...ចាប់បន្ទំណា ទៅមានកងអីគេ ត្រឹមត្រូវប៉ុនដូចថា យើងទៅដូចលក្ខណៈចាប់បន្ទំណា ។

សុជាៈ ចុះអត់ស្គាល់មេដឹកនាំទេ?

ធីៈ ហ្អេ អារឿងមេដឹកនាំធំអត់ស្គាល់ទេ ប៉ុនគ្នាឯងហ្នឹងស្គាល់ៗ អាពេលទៅជាមួយហ្នឹងទៅ ២០-៣០នាក់ ១០០-២០០ដែលគ្នាយើងហ្នឹង ។

សុជាៈ ពូទៅកន្លែងណា ក្នុងខេត្តណា?

ធីៈ អត់ចាំទេ ។ ដឹងតាស្វាយរៀងហែចូលទៅដីយួននោះ អត់មានតឹងមានផ្ទះយួនដុតអស់ហើយ ។

សុជាៈ ខេត្តណាដែលនៅចំមុខស្វាយរៀងហ្នឹងខេត្តណា?

ធីៈ អ៊ឺ...គេហៅ តិញនិញ ហ្អី?

សុជាៈ តិញនិញ?

ធីៈ បាទ!

សុជាៈ ចុះពូអ៊ឺ...ខ្ញុំនិយាយបកម៉ោក្រោយវិញកាលសម័យ ប៉ុល ពត ពូមានស្គាល់ថ្នាក់ដឹកនាំ ប៉ុល ពត ធំៗណាមួយដែរ?

ធីៈ អារឿងស្គាល់ដែលជជែកជាមួយគ្នាវាអត់ទេ ប៉ុន្តែស្គាល់ជាងគេ...អាពតក៏អត់ស្គាល់ដែរ ស្គាល់ជាងគេតា ខៀវ សំផន ហ្នឹងហ្នង ហើយស្គាល់ជាងគេស្គាល់ សុន សេន ហ្នឹងហ្នងនិយាយឲ្យចំ ហើយបន្ទាប់ហ្នឹងកងពល ម៉េត, តាលវ៉ៃ ហ្នឹងអនុកងពលហ្នឹងណា ស្គាល់តែប៉ុនហ្នឹង ហើយ សុន សេន រដ្ឋមន្ត្រីក្រសួងការពារប្រទេសហ្នឹងណា ហើយ

ដួន ជឿន មួយទៀត ដួន ជឿន រដ្ឋមន្ត្រីក្រសួងសុខាភិបាលហ្នឹងហើយស្គាល់ ហើយក្រៅពីហ្នឹងអត់ស្គាល់ទេ។

សុជាៈ ចុះ អៀង សារី?

ធីៈ អត់។ ពុកែឈ្មោះពុកែសម្ងេងពុកែអីហ្នឹង។

សុជាៈ ចុះ ស្គាល់ ខៀវ សំផន ថ្នាក់ជាអីដែរ?

ធីៈ ខៀវ សំផន ប្រធានរដ្ឋ ឋានៈប្រធានរដ្ឋ។

សុជាៈ ចុះមានដែលប្រជុំនយោបាយអីទេ?

ធីៈ ប្រជុំនៅស្តាតនេះឃើញតែពួក អាម៉េត ពួកតាលវ៉ៃ ដែលជាប្រធានកងពល ហើយបន្ទាប់មានតែរដ្ឋមន្ត្រីក្រសួងការពារប្រទេស សុន សេន ប៉ុន សុន សេន គេមិនមែនហៅ សុន សេន ទេគេហៅ តាខៀវ។ ខ្ញុំពុតាខៀវៗ សូម្បីអ្នកកាន់កម្មវិធី...។

សុជាៈ ឆ្នាំណាដែលគេប្រជុំនៅស្តាតហ្នឹង?

ធីៈ ខ្ញុំមិនចាំទេកាលហ្នឹងខ្ទង់បែកហើយ៤-៥ខែ ៧-៨ខែអីហ្នឹងដែលគេប្រមូលទ័ពអីចូលទៅអំពេញអីហ្នឹងណា រឿងចាំខែច្បាស់ខ្ញុំមិនចាំទេ ប៉ុន្តែប្រហែលជាអស់យូរហើយប្រហែលជា៥-៦ខែ។

សុជាៈ ចុះពូអ៊ី...ឌុច អីប្តូក៏ តាម៉ុក អីពូដែលស្គាល់ទេ?

ធីៈ អត់ស្គាល់ទៀត ពុតាឈ្មោះហ្នឹង។

សុជាៈ ចុះ តាម៉ុក?

ធីៈ តាម៉ុក ពុតាឈ្មោះដែរ ប្រធានភូមិភាគនិរតី តាម៉ុកហ្នឹង ដូចខ្ញុំពុដូចប្រធានភូមិភាគពិសេស តា វ៉ន វ៉េត អីចឹងហៃប្រធានភូមិភាគបូព៌ាដែលតាអី តា សោ ភឹម អីចឹងប្រធានភូមិភាគឧត្តរ កុយ ធួន ហៅ ធុច ហ្នឹងហើយភូមិភាគពាយ័ព្យ **អាចាច** ប្តូយ៉ាត ដឹងតាពុដែរ តាឈ្មោះដែរប៉ុនមិនដឹងមុខមាត់គេយ៉ាងម៉េចទេ។

សុជាៈ ចុះពូអ៊ី...ម៉ោដល់រាល់ថ្ងៃនេះពូមានដឹងរឿងរ៉ាវតុលាការកាត់ទោសមេដឹកនាំខ្មែរក្រហមទេ?

ធីៈ ខ្ញុំហ្នឹងវា...ចេះតែពុកាសែ្សត ពុវិទ្យុអីគេនិយាយចេះតែពុដែរហ្នឹងណា ក៏ប៉ុន្តែចេះតែនឹកឆ្ងល់ ប្តូមួយក៏គេដាក់ តាម៉ុក ហ្នឹងមិនព្រមចូលចែដន្យបានធម្មតាតាឈ្លើយសឹក ព្រោះ

ហៃគាត់ធំស្រាប់ផងណា គាត់សមាជិកមជ្ឈិមសមាជិកមជ្ឈិមបក្សហើយកាលពីសង្គ្រាម ៥ឆ្នាំ គាត់ប្រធានភូមិភាគកាលពីហ្នឹងម៉ោចប់សង្គ្រាមហ្នឹងទៀតក៏គាត់នៅតែខំ ហើយម៉ោដល់អាឡូវមិនដឹងយ៉ាងម៉េច ហើយសមគេចូលអស់ហើយៗគាត់អត់ចូល ប៉ុន្តែគ្រាន់តាខ្ញុំស្មែងយល់ដោយខ្លួនឯងបើសិន តាម៉ុក ហ្នឹងតូចជាងអ្នកទាំងអស់ហ្នឹងបើសិនតាខៀវ ហៅ សុន សេន ហ្នឹងទើបនឹងងាប់ហ្នឹងត្រូវ ហើយ ខៀវ សំផន ហ្នឹងក៏ចាត់ទុកគាត់អ្នកធំចាស់ហើយហ្នឹង ហើយ អៀង សារី នោះកាលសម័យហ្នឹងអ្នកណាមិនដឹងថា អៀង សារី អ៊ី...សូម្បីគេនិយាយរៀមច្បងអ្នកធំអី...មាន តាប៉ុល ពត, មាន ខៀវ សំផន, មាន អៀង សារី ហ្នឹងក៏គេតែងតែនិយាយថា អ្នកហ្នឹងធំជាងគេ ហើយហៃវាមិនខុសប្លែកអ្នកក្នុងស្រុកយើងនិយាយអ្នកក្នុងស្រុកវិញអ្នកធំជាងគេ ពីអតីតមានតា ហេង សំរិន, តា...។

ម៉េងទ្រី: ប៉ុន្តែប្រហែលជាតាមខ្ញុំយល់ក្នុងច្បាប់នេះមិនមែនបានអ្នកដែលជាប់ដាក់គុក២នាក់ហ្នឹងទេ ដែលត្រូវកាត់ទោសវានៅមានលើសពីហ្នឹងទៅទៀត ក្នុងច្បាប់ខ្មែរក្រហមណា។ ក្រែងលហ៏មានបងប្អូនយើងខ្លះគាត់យល់ថា ប្រហែលជាតុលាការកាត់ទោសដូចអ្នកឃើញនៅខាងមុខទេ ប៉ុន្តែតាមច្បាប់របស់ខ្មែរក្រហមណា មានការកាត់ទោសលើសពី២នាក់ហ្នឹងថែមទៀត។

ធី: បាទ!

សុជា: ព្រោះក្នុងមាត្រាទី១គេបានចែងថា មេដឹកនាំដែលទទួលខុសត្រូវខ្ពស់បំផុតក្នុងសម័យខ្មែរក្រហមពី៧៥ដល់៧៩អីចឹងប្រហែលជាគេមានលីសឈ្មោះរបស់គេសម្រាប់ដែលត្រូវគេយកម៉ោកាត់ទោសហ្នឹងហើយ ព្រោះក្នុងច្បាប់ហ្នឹងគេបានចែងហើយណា។

ធី: ខ្ញុំយល់បេះ ខ្ញុំមិនមែនយល់ថា ទៅកាត់ទោស តាម៉ុក ទេកាត់ទោសសង្គមហ្នឹងថ្នាក់ដឹកនាំហ្នឹង ថាបើកាត់ទោស តាម៉ុក ហ្នឹងហ្នងព្រោះ តាម៉ុក ហ្នឹងមានគេធំជាងគាត់៤-១០ ស្លូនទៅទៀត ព្រោះ តាម៉ុក គ្មានសិទ្ធសម្រេចក្នុងកិច្ចការអីថ្នាក់គាត់មេទ័ពតូចតាចដែរហ្នឹង។

ម៉េងទ្រី: អីចឹងពូចង់និយាយថា...បើសិនជាកាត់ទោសតែ តាម៉ុក និង ឌុច អាហ្នឹងមិនមែនជាការកាត់ទោសនៃការធ្វើខុសនៃរបបខ្មែរក្រហមទេ?

ធីៈ ហ្នឹងហើយ ។

ម៉េងទ្រីៈ ទាល់តែមានការកាត់ទោសឲ្យច្រើនលើសពីហ្នឹង?

ធីៈ លើសពីហ្នឹង ។

ម៉េងទ្រីៈ អ្នកធំជាងហ្នឹងទៀត?

ធីៈ ធំជាងហ្នឹងទៀត ។

ម៉េងទ្រីៈ បានការកាត់ទោសហ្នឹងពូអាចហៅថា ការកាត់ទោសរបបខ្មែរក្រហមបាន?

ធីៈ បាទ! ព្រោះការកាត់ទោសហ្នឹងក៏ តាម៉ុក ហ្នឹងថ្នាក់ទូចដែរប៉ុនគ្រាន់ថា គេចូលស្រុកចូលទេសសារភាពអស់ ខ្ញុំហៅថា សារភាពអីចឹងហើយណា ។

សុជាៈ បាទ!

ធីៈ ដោយខ្លែកគាត់អត់ចូល ហៃលហូតដល់គេចាប់បានទៀតអាហ្នឹងជាទោសកំហុសមានលក្ខណៈវាធ្ងន់ជាងអ្នកដែលចូល ។

សុជាៈ ចុះពូគិតថាកាត់ទោសការមានតុលាការហ្នឹងវាអាចមានយុត្តិធម៌ដល់...?

ធីៈ អ៊ឹ...ខ្ញុំមិនៗដឹងទេ ខ្ញុំវាមិនយល់អីជ្រៅដល់ថ្នាក់ហ្នឹងទេ ប៉ុន្តែបើខ្ញុំនិយាយឲ្យចំ ព្រះករុណាហ្នឹងក៏គាត់ដាក់ៗធនដែរខ្ញុំនិយាយម៉ាម៉ាត់ដែលខ្ញុំចូលទ័ពចូលអីក៏ដោយសារព្រះករុណា ខ្ញុំអត់ស្គាល់អាពត អីជង ស្គាល់ ហ៊ូ យន់ អីហ្នឹងប៉ុនថៃដន្យក្រោយម៉ោមានឈ្មោះ ប៉ុល ពត អីហ្នឹង ហើយព្រះករុណាក៏គាត់ ខ្ញុំពូច្បាស់ណាស់ព្រោះខ្ញុំនៅទ័ព ខ្ញុំទៅការពារគាត់ទៅដល់ព្រលានយន្តហោះពោធិចិនតុងហ្នឹងទៀត ទៅការពារគាត់ ហើយក្រោយម៉ោម៉ានខែគាត់សុំចូលនិវត្តន៍សុំចូលអីហ្នឹងខ្ញុំមិនដឹងប៉ុន្តែអ៊ីៗគាត់មានសារគាំទ្រដឹងផ្ទៃក្នុងគ្រាន់តែគាត់មិនដើរសិទ្ធិសេរីភាពដូចសព្វថ្ងៃនេះមែន ប៉ុន្តែអ៊ីៗហ្នឹងគាត់ជាថ្នាក់កំពូលនៅផ្ទៃក្នុងហ្នឹងដែរ ព្រោះពួកស្តេចហ្នឹង ខ្ញុំហ្នឹងហើយនៅយាមនៅហ្នឹងស្លៀកសារុងសូត្រនៅដើរអីមើលបន្លែអីប្លុចដ៏ៗកាលហ្នឹងមានទៅមើលរោងចក្រតម្បាញនៅពោធិចិនតុងសព្វថ្ងៃនេះ នៅតាំងពីជំនាន់អាពតនោះខ្ញុំឃើញគាត់ទៅទស្សនកិច្ចខ្ញុំទៅយាមៗថ្នល់យាមអីលើកថ្នល់លើកផ្កាអីជំនួសគេឲ្យយកទៅធ្វើប្រជាជន កាលហ្នឹងគេមិនឲ្យទ័ពធ្វើប្រជាជនអីយកពួករោងចក្រ... ។

សុជាៈ ស្លៀកពាក់ផ្សេងហ្នឹប្លុមួយក៏នៅតែខ្មោងដែល?

ធី៖	ស្តេចអត់មានស្លៀកពាក់ខ្មៅអីទេ ។

សុជាៈ	អត់ទេ នៅពេលពួកយើងទៅទទួលស្តេច?

ធី៖	អត់ទេ ទៅទទួលស្តេចចេះខ្ញុំនិយាយទៅកាលហ្នឹងដូច៧៥ ហើយនេះ ចង់ចូល៧៦ បែបខ្ទង់៧៦ ហើយតែអារឿងទ័ពហ្នឹងដែនស្លៀកពាក់ទ័ព អាអាវលែង១ មានខោអាវខ្មៅហើយណា ទ័ពហ្នឹងមានខោអាវស៊ីមុលីស៊ីអីហ្នឹងខោអាវម៉ូតចិននោះ ប៉ុនបើសម្រាមខោអាវអីខោអាវខ្មៅ ដាឌិប១ ខ្មៅ ហើយបើដល់ពេលហ្នឹងខោអាវដូចម៉ៅពីចិនហើយខោអាវពណ៌អាចម៍សេះអីចឹងខោអាវហ្នឹងហើយ ហែដល់គាធ្វើជាប្រជាជនអីហ្នឹងមានអាខោអាវសយើងផង មានអាស្ទឹ១ផងណា ទទួលមានបាច់ផ្កាមានអាធ្វើទ័ពផ្សេងទៅធ្វើកម្មករផ្សេងទៅ ធ្វើប្រជាជន តាមដែនគេ ប៉ុនគ្រាន់មិនបានប្រជាជនពីស្រុកពីទេសទៅទទួលទេ ប៉ុនអាអ្នកធ្វើហ្នឹងធ្វើជំនួស ជាខែលមួយក្លែងបន្ទំស្តេចក៏មិនដឹង ប៉ុន្តែ... ។

សុជាៈ	ចុះពូអ៊ឺ...ខ្ញុំចង់សួរពូបន្តិចក្រោយទៅក្រែងលហ៏...ពូឈ្មោះអីដែរ?

ធី៖	ខ្ញុំ ស្រេង ធី ។

សុជាៈ	ស្រេង ធី ។ អាយុប៉ុន្មានដែរ?

ធី៖	អាឡូវហ្នឹងហ្អី?

សុជាៈ	បាទ!

ធី៖	៤៧ ហើយអាឡូវនេះ ។

សុជាៈ	ឪពុកពូឈ្មោះអីដែរពូ?

ធី៖	កាំង ស្រេង ។

សុជាៈ	ចុះម្តាយ?

ធី៖	ម្តាយខ្ញុំ ហាក់ ឡោ ប៉ុនស្លាប់តាំងពីឆ្នាំណា ខ្ញុំអាយុ៥ឆ្នាំគាត់ស្លាប់ ។

សុជាៈ	ចុះឪពុកគាត់នៅរស់អត់?

ធី៖	ឪពុកខ្ញុំនៅ ។

សុជាៈ	ចុះមានបងប្អូនម៉ាននាក់ដែរ?

ធី៖	ម្នាក់ឯង ។ ម្នាក់ឯងគត់ ។

សុជាៈ	តែម្នាក់ឯងអីចឹងហ្នងប្តូក៏មានស្លាប់?

ធី៖ ដឹងត្តីម៉ោមានតែម្នាក់ឯងអីចឹងហ្នង ។

សុជា៖ ចុះអ៊ុ...ស្រុកកំណើតកើតជានៅឯណា?

ធី៖ ខ្ញុំដឹងត្តីម៉ោផ្ទះខ្ញុំនៅខាងជើងរោងចក្រនេះ ប៉ុននៅអាការខ្ពស់ដូចគ្នាទេណា ។ បើនិយាយទៅខ្ញុំដាក់ស្រុកកំណើតតាភូមិព្រែកខ្សេវគាលហូតហ្នឹង ។

សុជា៖ ចុះឥឡូវនៅភូមិអីដែរ?

ធី៖ ភូមិព្រែកខ្សេវ ឃុំរការខ្ពស់ ។

សុជា៖ ចុះអ៊ុ...ពូកើតជានៅក្នុងឆ្នាំណាដែរ?

ធី៖ ឆ្នាំ៥៥ ។

សុជា៖ ៥៥ហ្អី?

ធី៖ បាទ!

សុជា៖ ខែអីថ្ងៃអីចាំទេ?

ធី៖ អត់ចាំទេ ។

សុជា៖ ចុះពូមានក្នុងសម័យ ប៉ុល ពត ពូមានឃើញអ៊ីមានដឹងឬក៏ឃើញមានការសម្លាប់មនុស្សមានការធ្វើទារុណកម្មមនុស្សទេ?

ធី៖ អារឿងធ្វើទារុណកម្មដូចអ្នកទោសដូចមើលមិនឃើញដែរក៏ប៉ុន្តែអារបៀបធ្វើៗដូចវា បើនិយាយឲ្យចំទៅណា ខ្ញុំអត់បានឃើញអ្នកស្រុកទេ ខ្ញុំនិយាយពីខ្លួនខ្ញុំម្នាក់ កាលហ្នឹងធ្វើការមែនសូម្បីតែទ័ពហ្នឹងយើងកុំនិយាយប្រជាជនគេថាចេះ គេថា...យើងកាលនៅសង្គ្រាមប្រជាជនយើងអ្នកចិញ្ចឹមបាយយើងឲ្យខំធ្វើស្រែចិញ្ចឹមយើង អាឡូវយើងចប់សង្គ្រាមដងយើងដៃមួយយើងកាន់អាវុធ ដៃមួយរួមចំណែកធ្វើស្រែចិញ្ចឹមខ្លួនយើងផងជួយរួមចំណែកកសាងផ្ទះស្រែញ៉ុនេះអាស្រែញ៉ុ...អាកន្លែងខាងលិចអាថ្នល់ជាតិលេខ៣អាកន្លែងដែលពួកខ្ញុំអ្នកធ្វើស្រែដែលបែកហ្នឹងហើយ ។

សុជា៖ ចុះកាលទៅកំពង់ឆ្នាំងមានដឹងថាមានការសម្លាប់មនុស្សអីទេ?

ធី៖ អាហ្នឹង អាឃើញផ្ទាល់ភ្នែកហ្នង ប៉ុនអារឿងឃើញសម្លាប់គេហ្នឹងវាអត់ឃើញទេ ក៏ប៉ុន្តែឃើញដឹកទៅសម្លាប់ ហើយដែលក្រោយម៉ោទៀតខ្ញុំទៅដល់ៗកន្លែងសម្លាប់ហ្នឹងទៀត ។

*សុជាៈ* *នៅកន្លែងណា?*

*ធីៈ* *អ៊ឺ...អាហ្នឹងទៅក៏រហ៏មិនឃើញដែរ តាមពិតទៅខាងលិចរមាសណាៗទៅដល់អាជើងភ្នំជ្រាវហ្នឹងមិនដឹងហៅស្អីទេ អាជ្រាវហ្នឹងមានផ្លូវម៉ោខាងជើងប៉ុនមានផ្លូវគេទៅបុកអមលាំងៗដូចក្បាលទឹក ហ្នឹងហើយគេហៅក្បាលទឹក ព្រោះសម្លាប់ម្ដុំហ្នឹងទៅអីចឹងនៅខាងឆ្វេងដៃ ប៉ុនអាផ្លូវបត់អីចេះនៅផ្លូវ អត់មានផ្លូវអាទេះទេណា ដើរចូល...គេហៅជើងភ្នំព្រៃដូង់ព្រៃវែងហ្នឹងហ្នង ។*

*ម៉េងទ្រីៈ* *សម្លាប់ហ្នឹងក្នុងឆ្នាំណា?*

*ធីៈ* *បើនិយាយទៅខ្ញុំចាំច្បាស់ គឺថា គេរើសពួកខ្ញុំ...គេអត់ឲ្យពួកហ្នឹងទៅវ៉ៃទេ ឆ្នាំ៧៧-៧៨ ហ្នឹង គឺព្រោះ... ។*

*សុជាៈ* *ពួកហ្នឹងម៉ោពីណាកាលហ្នឹង?*

*ធីៈ* *ពួកនៅស្វាយរៀង ព្រៃវែង ព្រោះទ័ពរបស់យើងពួកនោះជាប់ទាំងអស់ ។*

*សុជាៈ* *ប្រហែលជាម៉ាននាក់ដែរ?*

*ធីៈ* *ខ្ញុំស្មានរឿងសម្លាប់មិនដឹងម៉ាននាក់ទេ ប៉ុនទ័ពកាលហ្នឹងរាប់ម៉ឺននាក់នោះៗមិនតិចទេ ។*

*ម៉េងទ្រីៈ* *ចង់និយាយថា ការសម្លាប់មនុស្សនៅហ្នឹងរាប់ម៉ឺននាក់ឬក៏...?*

*ធីៈ* *រឿងសម្លាប់មិនដឹងគ្រប់រាប់ម៉ឺនទេ ប៉ុននៅកំពង់ឆ្នាំង... ។*

*ម៉េងទ្រីៈ* *យកចេញម៉ោពីស្វាយរៀងហ្អី?*

*ធីៈ* *វាទៅដាក់កន្លែងហ្នឹងមិនមែនអ្នកស្វាយរៀងតែងអស់ទេ វាគ្រប់ខេត្តទូទាំងប្រទេស ។*

*ម៉េងទ្រីៈ* *យកចេញពីកន្លែង...?*

*ធីៈ* *អ៊ឺ...ចេះអ្នកមានទោសស្រាលៗម៉ានណាខេត្តណាៗក៏បញ្ជូនម៉ោហ្នឹងនិយាយឲ្យចំ តាំងពីភូមិភាគនិរតីក៏មានបញ្ជូនម៉ោហ្នឹងដែរព្រោះសឹទ្ធតាអ្នកមានទោស គ្រាន់តែតិចហើយច្រើនណាបើយើងស្មានច្រើនជាងគេប្រហែលជា ខាងស្វាយរៀង ព្រៃវែង កំពង់ចាម ហើយមើលច្រើនជាងគេ... ។*

## ភាគទី៣

*សុជាៈ* *បាទ!*

ធីៈ ហែដល់អីចឹងគេអត់ឲ្យទៅទេ និយាយឲ្យចំទៅណា ហែអ្នកណាគេឲ្យទៅៗ ។

ម៉េងទ្រីៈ មុខសញ្ញាគេ?

ធីៈ ហ្នឹងហើយ ព្រោះនៅជាមួយវានៅកងជាមួយគ្នាចម្រុះផ្ទាល់ពួកហ្នឹងអត់មាននេះទេ ចម្រុះផ្ទាល់អត់មាននេះទេ ខ្ញុំនៅជើងទាហានខាងលិច ។ គេហៅស្អីវាភ្លេចហើយ...ខ្ញុំភ្លេចឈ្មោះ ប៉ុន្តែខ្ញុំស្គាល់ច្បាស់ ហើយដល់គេឲ្យទៅជួយប្រូតអីចឹងក៏គេមានឈ្មោះមានអីឲ្យទៅដែរគេមិនមែនចេះតែអាងកងជាមួយគ្នាចេះតែហៅទៅទេណាគេហៅថាឲ្យពួកហ្នឹងទៅដែរ ហើយពួកខ្ញុំហ្នឹងអាខ្លះវាអត់យកទៅវ៉ៃតែហេតុតែចង់ទៅពេកណារត់គោងឡានហើយគោងឡាន២០-៣០គីឡូ...។ តាហ៊ានតែយកទៅជ្រុលងាប់ហើយអាអ្នកទៅនោះព្រោះយកទៅម្ដង៥ឡាន៧ឡានមិនមែនទៅតិចណាទៅម្ដង៦គ្រឿងណាម៉ាឡានៗណា ប៉ុន្តែខ្ញុំអត់សុំគេទៅទេ គេថាចាំក្រោយ ។

ម៉េងទ្រីៈ គេយកទៅហ្នឹងដឹកឆ្ងាយពីកន្លែងក្បាលទឹកហៃនិងកន្លែងវាលកប៉ាល់ហោះនៅឆ្ងាយពីគ្នាច្រើនទេ?

ធីៈ ឆ្ងាយ ។

ម៉េងទ្រីៈ ឆ្ងាយហ្អី គេសម្លាប់ដោយប្រើកាំភ្លើងឬក៏...?

ធីៈ អត់កាំភ្លើងទេដៃត្បូងចបៗ ។

ម៉េងទ្រីៈ បើសិនជាប្រើកាំភ្លើងយើងអាចឮទេ?

ធីៈ យើងអាចឮ ។ ខ្ញុំប្រាប់គ្រាន់តែកាំភ្លើងផ្ទុះម៉ាភ៉ាវណាក៏វាឈប់យកទៅដែរ ។ ផ្ទុះម៉ាភ៉ាវដោយសារអីចេះ អាចុងក្រោយម៉ោពីអាមិត្តភក្តិទេដូចថាឱ្យបប្រាប់បែកការណ៍ត្រឹមហ្នឹងប៉ុនបើវាបាញ់ងាប់មួយ២ដែរ ។

ម៉េងទ្រីៈ ឌុបយកទៅលហួត?

ធីៈ ឌុបយកទៅលហួត ។

ម៉េងទ្រីៈ អីចឹងពួកអ្នកសល់ៗហ្នឹងរស់ទៅ?

ធីៈ រស់ទៅហើយខ្លះក៏គេឲ្យទៅវ៉ៃយួនខ្លះក៏ទៅ ស្លាប់ពេលហ្នឹងទៀត អាសល់ម៉ាន ខ្លះក៏ធ្វើការម៉ោទល់សព្វថ្ងៃហ្នឹង ខ្លះក៏ឈប់ម៉ោអីចឹងទៅណា ។

សុជាៈ ចុះពូមានអ៊ីចង់បន្ថែមទៀតនូវអ៊ីដែលខ្ញុំអត់ទាន់បានសួរទេ?

ធី៖ ខ្ញុំគ្មានអ៊ីចង់បន្ថែមទៀតទេ គ្រាន់តែថាអីចេះខ្ញុំជាទ័ពដល់ពេលប្អូនៗសម័យអាឡូវជាទ័ពដូចជាពិការដូចជាអត់ដូចថា ខ្ញុំឃើញអ្នកទ័ពមិនសូវមានលុយដូចបប្ចូរដូចគេទេ របស់ប្រើប្រាស់ ក៏មិនសូវមានសមរម្យនឹងគេអើទ័ពមេៗឃើញសមហើយ ប៉ុនភាគច្រើន គឺអត់សមសុំទានក៏ច្រើនអ្នកខ្វត់ខ្សោយក៏ច្រើនសូមឲ្យសណ្ដានចិត្តមេកើយណា ជួយជ្រុមជ្រែងលើកពួកហ្នឹងផង ហើយកុំបន្ទាប់បន្ថោសត្បិតតែខុសឆ្គងអីក៏ដោយឲ្យស្ដាប់ឲ្យយល់ព្រោះ...ឆាកជីវិតគ្នាក៏ៗបញ្ចប់ត្រឹមហ្នឹងដែរ ។ អីចឹងបានថាគ្រប់គណបក្សណា ដែលអ្នកចេះដឹងចេះអីក៏ដោយខ្ញុំមិនហ៊ានថាយ៉ាងម៉េចទេណា ថាធ្វើម៉េចឲ្យជួយពួកហ្នឹងថា បើមិនបាន...ហ្នឹងហើយអ្នកដែលសល់រូបភាពពីសង្គ្រាមយ៉ាងនេះយ៉ាងនោះអីចឹងណា ព្រោះខ្ញុំឃើញខ្ញុំជិះម៉ូតូទៅវេទនាមែនទែន អាខ្លះក៏ដើងគ្នាស្មើទៅក៏អត់ អាខ្លះក៏ពិការអីចឹងទៅសូមឲ្យៗជួយគ្នា ជួយលើកថែគ្នាអវយវ ទ្រុឌទ្រោមកាយវិការទ្រុឌទ្រោមកក៏ដោយសារជាតិសង្គ្រាមហ្នឹងដែរ អីចឹងអាណិតគ្នា ហើយឈប់អ៊ី...បន្ទាប់បន្ថោសហើយឈប់ដាក់កំហុសលើអ្នកនេះអ្នកនោះយើងនិយាយទៅហេតុតែប្រទេសវាមានសង្គ្រាមបានទៅថ្នាក់ហ្នឹងហើយការយល់ដឹងរៀនសូត្រយ៉ាងម៉េចៗគ្នាវាអត់ចេះដូចគេទេ អីចឹងបានថា សុំអង្វរឲ្យបងប្អូនដែលអ្នកមានអ៊ី...ដែលគេហៅថាសេចក្ដីស្នេហាជាតិនោះខ្ញុំក៏វាអត់យល់ពាក្យថាមានគំនិតស្នេហាជាតិដែរជ្រៅដល់ណាទេ ប៉ុន្តែថាឲ្យមានគំនិតស្នេហាជាតិឲ្យចេះសណ្ដោសពួកហ្នឹងផងបើយើងនិយាយទៅបើខ្ញុំយកអាពាក្យថាល្ងង់ ហេតុតែគ្នាចាញ់បោកសង្គ្រាមក៏មិនដឹងទេ ប៉ុនខ្ញុំសុំទោសចុះថ្វីត្បិតតែពាក្យក្នុងភាសាខ្ញុំនិយាយណាក៏ៗមិនដឹងយ៉ាងម៉េចដែរព្រោះខ្ញុំមិនដែលឃើញអាអ្នកលីដែកប្រហោងហ្នឹងវាហាំៗសោះ ឃើញអាអ្នកដែលខ្លះឃើញម៉ោអាចផ្គូតឆ្អេងជិះមិនទាន់បានម៉ាឆ្នាំផងគេទំនើបៗណា ។ អីចឹងដល់សួរទៅគេសិទ្ធទេអ្នកស្នេហាជាតិដែរអ្នកធ្វើការដែរ ហ្នឹងហើយខ្ញុំមិនហ៊ានថាម៉េចទេប៉ុនគ្រាន់ជួយថា បើប្អូនបាននាំពាក្យជួយអង្វរៗគេហ្នឹងទៅ ។

ម៉េងទ្រី៖ បាទ! អរគុណៗពូច្រើន ។

ធី៖ ខ្ញុំសុំតែមានពាក្យប៉ុណ្ណឹងទេ ។

សុជា៖ បាទ! អរគុណពូច្រើន ។

ធី៖ បាទ!